សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មករា ឆ្នាំ ២០១៩

# លីអាហូណា




យ៉ូហាន ៖ សាវក អ្នកទទួលវិវរណៈ
សាក្សីផ្ទាល់ភ្នែក ទំព័រ ១៨

រឿងអំពីភាពជាសិស្សរបស់ម៉ារា ទំព័រ ១២

សេចក្តីជំនឿដើម្បីព្យាយាម ទល់នឹង សេចក្តីជំនឿដើម្បីធ្វើ ទំព័រ ២៤

យ៉ូសែប ស្មីធ ៖ សិស្សនៃក្រឹត្យវិន័យរបស់ព្រះ និងមនុស្ស ទំព័រ ២៨


ច្បាប់ចេញផ្សាយថ្មីនាខែនេះ

សូមចែកចាយ
ផ្នែកកុមារ
នៅក្នុងទស្សនាវដ្ដី ប្រិយមិត្ត ថ្មី
ជាមួយកុមារ ។

សាសនាចក្រ
នៅទីនេះ

# ទីក្រុងតូក្យូ ប្រទេសជប៉ុន





នៅឯទីបញ្ចុះសពយ៉ាណាកានៅទីក្រុងតូក្យូ ប្រទេសជប៉ុន គ្រួសារមួយនៃពួកបរិសុទ្ធថ្ងៃចុងក្រោយឈ្មោះសេនតូស បានទៅជួបគ្នាក្នុងពិធីរំឭកខួបគ្រួសាររបស់ពួកគេ ។ សម្រាប់ពួកគេ កន្លែងនេះគឺជាកន្លែងចងចាំ ដែលកាន់តែពិសិដ្ឋដោយសារចំណេះដឹងរបស់ពួកគេអំពីដំណឹងល្អដែលថា ក្រុមគ្រួសារអាចរស់នៅជាមួយគ្នាជារៀងរហូត ។

ការគោរពដល់ក្រុមគ្រួសារ និងជីដូនជីតាបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌ជប៉ុន ហើយពួកបរិសុទ្ធថ្ងៃចុងក្រោយជាជនជាតិជប៉ុនរីករាយ ដែលឥឡូវនេះប្រទេសរបស់ពួកគេមានពរដោយមានព្រះវិហារបរិសុទ្ធបី ៖ តូក្យូ ( ព្រះវិហារបរិសុទ្ធទីមួយនៅអាស៊ី បានឧទ្ទិសឆ្លងក្នុងឆ្នាំ ១៩៨០ ហើយបច្ចុប្បន្ននេះកំពុងជួសជុល ), ហ្វូកៅកា ( បានឧទ្ទិសឆ្លងនៅក្នុងឆ្នាំ ២០០០ ) និង សាបប៉ូរ៉ូ ( បានឧទ្ទិសឆ្លងនៅក្នុងឆ្នាំ ២០១៦ ) ។ ប្រទេសជប៉ុនក៏ជាទីតាំងនៃមជ្ឈមណ្ឌលពង្សប្រវត្តិ អិល. ឌី. អេស ទាំង ៦៤ ផងដែរ ។

ពួកអ្នកផ្សព្វផ្សាយសាសនាដំបូងគេបានទៅដល់ប្រទេសជប៉ុននៅក្នុងឆ្នាំ ១៩០១ ដែលដឹកនាំដោយអែលឌើរ ហ៊ីប៊ើរ ចេ ក្រាន្ត ( ១៨៥៦–១៩៤៥ ) ដែលកាលនោះគឺជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយក្រោយមកក្លាយជាប្រធានទីប្រាំពីរនៃសាសនាចក្រ ។ សព្វថ្ងៃនេះមានសមាជិកជិត ១៣០០០០ នាក់នៅក្នុងប្រទេសជប៉ុនក្នុងចំណោម ២៦១ ក្រុមជំនុំ ។

- ការបកប្រែព្រះគម្ពីរមរមនដំបូងជាភាសាជប៉ុនចំណាយពេលប្រាំឆ្នាំ ហើយបានបញ្ចប់នៅក្នុងឆ្នាំ ១៩០៩ ។ កំណែបកប្រែត្រូវបានបោះពុម្ពនៅក្នុងឆ្នាំ ១៩៥៧ ។

- សាលាប្រជុំ អិល. ឌី. អេស. ដំបូងគេនៅអាស៊ីត្រូវបានឧទ្ទិសឆ្លងនៅក្នុងប្រទេសជប៉ុនក្នុងឆ្នាំ ១៩៦៤ ។

- អ្នកមានសិទ្ធិអំណាចទូទៅមកពីពូជពង្សជនជាតិជប៉ុន រួមមាន អែនឌី រ៉ាយ គូម៉ាស៊ូ ( ១៩២៣–២០១១ ) កើតនៅរដ្ឋហាវ៉ៃ; សាម ខេ ស៊្រីមម៉ាប៊ូគូ្ល ( ១៩២៥-២០១៥), កើតនៅរដ្ឋហាវ៉ៃ, យ៉ូស៊្រីហ៊ីកូ គីគូឈី ដែលលាលែងពីតំណែង គ័ឈី អោយ៉ាម៉្ពី ដែលលាលែងពីដំណែង, តាកាស៊្រី វ៉ាដា និង កាស៊្រូហ៊ីកូ យ៉ាម៉ាស្សាតា ។



# ភាពជាសិស្ស

ពិភពលោកដែលយើងរស់នៅនេះ ហាក់ដូចជាត្រូវបានរៀបចំឡើងដើម្បីសាកល្បងការលះបង់របស់យើងចំពោះភាពជាសិស្ស ។ នៅពេលយើងសិក្សាព្រះគម្ពីរសញ្ញាថ្មីឆ្នាំនេះ យើងអាចទទួលបានការបំផុសគំនិតតាមរយៈការបង្រៀន និងគំរូរបស់ព្រះយេស៊ូវ និងពួកសិស្សរបស់ទ្រង់ ដែលព្យាយាមទាំងរៀនពីទ្រង់ និងប្រែកាន់តែដូចលោកថៅហ្វាយរបស់ពួកគេ ។

ក្នុងនាមជាគ្រូបង្រៀនព្រះគម្ពីរសញ្ញាថ្មីនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ សហការីរបស់ខ្ញុំឈ្មោះ ហ្គេយី ស្រ្ដាធើន និងខ្ញុំបានចែកចាយគំនិតមួយចំនួននៅក្នុងបញ្ហានេះ អំពីគំរូនៃភាពជាសិស្សដែលយើងអាចរៀនពីម៉ារាមាតារបស់ព្រះយេស៊ូវ ( ទំព័រ ១២ ) និង យ៉ូហានសំណព្វ ( ទំព័រ ១៨ ) ។ បុគ្គលទាំងពីរនាក់នេះគឺនៅក្នុងចំណោមសាក្សីដ៏អស្ចារ្យបំផុតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ក្រៅពីព្រះជាព្រះវរបិតាទ្រង់ផ្ទាល់ គ្មានបុគ្គលណាទៀតដែលបានស្គាល់ព្រះយេស៊ូវច្បាស់ដូចមាតារបស់ទ្រង់ឡើយ ថាទ្រង់គឺពិតជាព្រះរាជបុត្រារបស់ព្រះ ហើយយ៉ូហានត្រូវបានរាប់ទៅក្នុងចំណោមពួកសាវកដើមទាំងដប់ពីរ ហើយបង្ហាញថា គឺជាមិត្តភក្តិជិតស្និទ្ធម្នាក់របស់ព្រះអម្ចាស់ ។

ភក្ដីភាពនៃពួកសិស្សទាំងនេះ និងសិស្សផ្សេងទៀតបង្រៀនយើងអំពីរបៀបដែលយើងអាចក្លាយជាសិស្សសំណព្វរបស់ព្រះយេស៊ូវគ្រីស្ទដោយខ្លួនយើង ហើយរក្សាភាពជាសិស្សរបស់យើង ទោះជាមានឧបសគ្គក្នុងពិភពលោកនេះក្ដី ។

នៅពេលយើងសិក្សាព្រះគម្ពីរសញ្ញាថ្មីប្រកបដោយការអធិស្ឋាន នោះយើងពុំគ្រាន់តែអាចដឹងកាន់តែច្រើន *អំពី* ព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះទេ យើងថែមទាំង *ស្គាល់ ទ្រង់កាន់តែច្បាស់ទៀតផង ( សូមមើល* យ៉ូហាន ១៧:៣ ) ។

ដោយស្មោះស្ម័គ្រ
អ៊ីរិក ឌី ហាន់ស្វែន







**បេសកកម្មដ៏មហាអស្ចារ្យរបស់ព្យាការី យ៉ូសែប ស្ម៊ីធ**
*ប្រធាន ដាល្លិន អេក អូក*
២៨





**យ៉ូហាន ៖ សិស្សដែលព្រះយេស៊ូវស្រឡាញ់**
*អ៊ីរិក ឌី ហាន់ស្វែន*
១៨



**ម៉ារាមាតារបស់ព្រះយេស៊ូវ**
*ហ្គេយី ស្រ្ដាធើន*
១២









**គោលការណ៍នៃការងារបម្រើ ៖ គោលបំណងដែលនឹងផ្លាស់ប្ដូរការងារបម្រើរបស់យើង**
៨

៥ **និមិត្តរូបនៅក្នុងគម្ពីរសញ្ញាថ្មី** ⏱
យើងអាចរកឃើញអត្ថន័យនៅក្នុងវត្ថុនានា វប្បធម៌ ប្រវត្តិសាស្ត្រ និងទីកន្លែងនានានៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

៦ **ការបង្ហាញអំពីសេចក្ដីជំនឿ:** ⏱
**ផុន ផាន—ទីក្រុងភ្នំពេញ ប្រទេសកម្ពុជា**
នៅថ្ងៃបន្ទាប់ពីភ្លើងឆេះផ្ទះ យើងបានលុតជង្គង់អធិស្ឋាន ហើយទូលសូមព្រះអម្ចាស់ឲ្យបង្ហាញយើងអំពីវិធី និងប្រទានពរឲ្យយើងអាចស្វែងរកផ្ទះថ្មីមួយ ។

៨ **គោលការណ៍នៃការងារបម្រើ:**
**គោលបំណងដែលនឹងផ្លាស់ប្ដូរការងារបម្រើរបស់យើង**
មានអ្វីៗជាច្រើនដែលយើងអាចធ្វើដើម្បីនាំមនុស្សមកកាន់ព្រះគ្រីស្ទ នៅពេលយើងផ្ដល់ការងារបម្រើ ។

១២ **ម៉ារាមាតារបស់ព្រះយេស៊ូវ**
*ដោយ ហ្គេយី ស្ត្រាធើន*
មានអ្វីៗជាច្រើនដែលយើងអាចរៀនពីគំរូរបស់ម៉ារាស្ដីពីសេចក្ដីជំនឿ និងការលះបង់ ។

១៨ **យ៉ូហាន ៖ សិស្សដែលព្រះយេស៊ូវស្រឡាញ់**
*ដោយ អ៊ីរិក ឌី ហាន់ស្សែន*
ដូចជាសាវកយ៉ូហានដែរ យើងអាចក្លាយជាសិស្សសំណព្វរបស់ព្រះយេស៊ូវគ្រីស្ទ ។

២៤ **សេចក្ដីជំនឿពីរកម្រិត**
*ដោយ អែលឌើរ វិលហ្វត ដបុលយូ អាន់ឌើរសិន*
សេចក្ដីជំនឿគឺ លើសពីការគ្រាន់តែធ្វើសកម្មភាពទៅទៀត ៖ វាគឺជាការសម្របឆន្ទៈរបស់យើងទៅនឹងព្រះទ័យរបស់ព្រះ ។

២៨ **បេសកកម្មដ៏មហាអស្ចារ្យរបស់ព្យាការី យ៉ូសែប ស្ម៊ីធ**
*ដោយប្រធាន ដាល្លិន អេក អូក*
សាក្សី និងឯកសារស្របច្បាប់ពីដើមជួយយើងឲ្យយល់ពីបុគ្គលិកលក្ខណៈរបស់យ៉ូសែប និងសមត្ថភាពរបស់លោកដើម្បីសម្រេចកិច្ចការនៅក្នុងជីវិតរបស់លោក ។

៣៨ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ** ⏱
សាសនាគន់ការីធ្លាក់ចុះពីចុងឈើ ទទួលទានបន្ទូលព្រះភ្លាមៗ ការស្វែងរកប្រាក់ ឡកម្តៅផ្ទះ យើងដំណើរការដោយសារសេចក្ដីជំនឿ ។


⏱ ការអានខ្លីៗ



**នៅលើក្របមុខ**
*អាហារយប់ថ្ងៃចុងក្រោយ*
ដោយ ខាល ហៃនរិច ប្លូច

## កថាកណ្ឌ


**យុវមជ្ឈិមវ័យ**
៤២
ការថែទាំសុខភាពផ្លូវចិត្ត និងអារម្មណ៍របស់យើងគឺជា**ការរក្សាតុល្យភាព និងអំណរនៃជីវិត**ដ៏សំខាន់ ។ សូមមើលអត្ថបទខែនេះស្ដីពីភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត ។





**យុវវ័យ**
៥០
សូមរៀនរបៀបយល់ពីតម្លៃរបស់អ្នក ហើយ**រីកចម្រើនដូចជាព្រះអង្គសង្គ្រោះនៅក្នុងផ្នែកដ៏សំខាន់ទាំងបួន ។** សូមស្វែងរកពីរបៀបដែលការបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកចំពោះព្រះវរបិតាសួគ៌នឹងធ្វើឲ្យអ្នករីករាយ នៅពេលអ្នក**សិក្សាបារចនាម៉ូតផលឆ្នាំ ២០១៩ ៖**

**កុមារ**
**ផ្នែករបស់កុមារគឺជាមានទស្សនាវដ្ដីផ្ទាល់របស់វាគឺទស្សនាវដ្ដី *ប្រិយមិត្ត* !** យើងសង្ឃឹមថាការណ៍នេះនឹងផ្ដល់សិទ្ធិយ៉ាងច្រើនដល់កុមារដើម្បីរៀនពីដំណើររឿងដែលស្ថាបនាសេចក្ដីជំនឿដែលរៀបចំឡើងសម្រាប់តែពួកគេប៉ុណ្ណោះ ។ ប្រសិនបើអ្នកគ្មានកុមារនៅក្នុងគេហដ្ឋានរបស់អ្នក សូមឲ្យទស្សនាវដ្ដី *ប្រិយមិត្ត* ថ្មីដល់កុមារម្នាក់នៅក្នុងវួដ សាខា ឬអ្នកនៅជិតខាងរបស់អ្នក ។




liahona.lds.org facebook.com/liahona បណ្ណាល័យដំណឹងល្អ

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.lds.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- រកមើលអត្ថបទដែលមានតែលើឌីជីថល ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬផ្ដល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក, ស្ដាប់ ឬបោះពុម្ពអត្ថបទដែលអ្នកចូលចិត្ត ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

សូមអ៊ីម៉ែលសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ldschurch.org ។

សូមដាក់បញ្ជូនរឿងដែលបំផុសឲ្យមានសេចក្ដីជំនឿទាំងឡាយរបស់អ្នកទៅ អ៊ីម៉ែល liahona.lds.org ឬផ្ញើសំបុត្រទៅកាន់ ៖
*Liahona*, floor 23
50 E. North Temple Street
Salt Lake City, UT 84150-0023, USA

## អត្ថបទដែលមានលក្ខណៈសម្រាប់តែឌីជីថលប៉ុណ្ណោះ



**របៀប ១៤ យ៉ាង ដើម្បីធ្វើឲ្យសុខភាពផ្លូវចិត្តរបស់អ្នកត្រឡប់មកលើផ្លូវវិញ**
*ដោយ ហ៊ីស្សេ ជេ ចនសុន*
ចំណុចគន្លឹះទាំងនេះអាចជួយអ្នកឲ្យទទួលអារម្មណ៍ដូចជាខ្លួនអ្នកម្ដងទៀត ។



**ការស្វែងរកអ្នកមានវិជ្ជាជីវៈខាងសុខភាពផ្លូវចិត្ត ដែលត្រឹមត្រូវសម្រាប់អ្នក**
*ដោយ ខេរីន ស្មើរ៉េត្ត*
ប្រសិនបើអ្នកកំពុងគិតអំពីការទៅជួបអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្ត ចំណុចគន្លឹះនេះអាចជួយអ្នកឲ្យដឹងពីចំណុចចាប់ផ្ដើម !

**ខែ មករា ឆ្នាំ ២០១៩ វ៉ុល ១៨ លេខ ១**
**លីអាហូណា ១៨៦០១ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌេល ជី រេនឡាន់, ជើរិត ដប្លុយ ហ្គង, អូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** ហ៊ូហ្គូ អ៊ី ម៉ាទីណេស្ស

**អ្នកប្រឹក្សា ៖** ប្រេអិន ខេ អាស្តុន, រ៉ាន់ដល ខេ បែណិត, ប៊ែកឃី ក្រាវិន, អែតវើត ឌូប, សារ៉ុន អ៊ូប៊ែង, គ្រីស្ទីណា ប៊ី ហ្វ្រានកូ, រ៉ាន់ឌី ឌី ហ្វាំង, ដូណាល អិល ហលស្ត្រម, អ៊ែរិច ដុបយូ កូពីឆ្កេ, លីន ជី រ៉ូប៊ីន

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** ហ្វ្រានសឹស្កា អូស្តុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ខែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ៊ីតុន, ឡូរី ហ្វូលើរ, ហ្គាប៊ែត អេច ហ្គាហ្វ, ឡារ៉ែន ជតទើរ ហ្គាន, ចន រ៉ាយអិន ជិនសិន, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ឺដុក, សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាក់ខេល វូដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន

**នាយកផ្នែកសិល្បៈ ៖** ថេដ អ័រ ភីធើរសុន

**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនធ្វី, ស៊ី ឃីមប៊ល បុត, ចូម៉ាស ឆាល, ចូស្វ៊ា ដេននីស ដេវីឌ ហ្គ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កុត អិម ម៉ូយ, អ៊ីមីលី ឆៀកូ ប៉ើមីងតុន, ម៉ាក ដ័ប្លុយយូ រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ នីកូល វ៉ែកឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍

**ផលិតកម្ម ៖** អ៊ីរ៉ា ហ្វែន អាឌៀ, ជូលី ប៊ឺដេត, ចូម៉ាស ជី ខ្រូនីន, ប្រាយអែន ដ័ប្លុយយូ ហ្គីជី, ជីននី ជេ នីលសុន, ឌើរិក រីឆាដសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាឃើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona*, Rm. ២៤២០, ៥០ E. North Temple St., Salt Lake City, UT ៨៤១៥០–០០២៤, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាម៉ៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវ៉េ, ប៉ូឡូញ, ព័រទុយហ្គាល, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© ២០១៩ by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** January ២០១៩ Vol. ១៨ No. ១. LIAHONA (USPS ៣១១-៤៨០) Cambodian (ISSN ១៥៣៨-៤៥៣៥) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, ៥០ E. North Temple St., Salt Lake City, UT ៨៤១៥០. USA subscription price is $១០.០០ per year; Canada, $១២.០០ plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address *must* be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: ១-៨០០-៥៣៧-៥៩៧១. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds .org. (Canada Post Information: Publication Agreement #៤០០១៧៤៣១)

POSTMASTER: Send all UAA to CFS (see DMM ៥០៧.១.៥.២). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box ២៦៣៦៨, Salt Lake City, UT ៨៤១២៦-០៣៦៨, USA.

# និមិត្តរូបនៅក្នុងគម្ពីរសញ្ញាថ្មី

ក្រៅពីការបង្រៀននេះ
យើងអាចរកឃើញអត្ថន័យ
នៅក្នុងវត្ថុនានា វប្បធម៌
ប្រវត្តិសាស្ត្រ និងទីកន្លែងនានា
នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

**ភ្នំ ៖** « ភ្នំពុំងាយស្រួលនឹងឡើងឡើយ ។ តាំងពីមុនរហូតដល់ឥឡូវនេះ ព្រះអម្ចាស់បានហៅពួកសិស្សរបស់ទ្រង់ឲ្យឡើងភ្នំ ដើម្បីគូសបញ្ជាក់អំពីឥទ្ធិពលនៃកិច្ចខិតខំ និងការគោរពប្រតិបត្តិ ។ ទ្រង់នឹងសុំរឿងនេះពីអ្នកទាំងដោយប្រៀបធៀប និងដោយពិតប្រាកដផងដែរ » ។



**អូលីវ ៖** « ព្រះយេស៊ូវបានយាងទៅកាន់ជើងភ្នំដើមអូលីវ ដើម្បីបំពេញផ្នែកដំបូងនៃដង្វាយធួន ។ ទ្រង់បានធ្វើកិច្ចការនេះនៅក្នុងសួនច្បារគែតសេម៉ានី ។ ពាក្យ *គែតសេម៉ានី* មកពីពាក្យដើមពីរនៃភាសាហេព្រើរ ៖ ពាក្យ *gath* មានន័យថា ‹ សង្កត់ › និងពាក្យ *shemen* មានន័យថា ‹ ប្រេង › ជាពិសេសប្រេងអូលីវ ។

« នៅទីនោះ អូលីវត្រូវបានសង្កត់ដោយទម្ងន់នៃរង្វង់កង់ថ្មដ៏ធ្ងន់ដើម្បីច្របាច់ប្រេងដ៏មានតម្លៃចេញពីផ្លែអូលីវ ។ ដូច្នេះព្រះគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានីគឺពិតជាត្រូវបានសង្កត់នៅក្រោមទម្ងន់នៃអំពើបាបរបស់ពិភពលោក ។ ទ្រង់បានស្រក់ដំណក់ឈាមធំៗ—‹ ប្រេង › នៃព្រះជន្មរបស់ទ្រង់—ដែលចេញមកពីគ្រប់រន្ធញើស ។ ( សូមមើល លូកា ២២:៤៤; គ. និង ស. ១៩:១៨ ) » ។





**ទឹក ៖** « ទន្លេយ័រដាន់គឺជាទីកន្លែងដែលព្រះយេស៊ូវបានជ្រើសរើសសម្រាប់ពិធីបុណ្យជ្រមុជទឹករបស់ទ្រង់ដោយយ៉ូហាន ដើម្បី ‹ សម្រេចតាមគ្រប់ទាំងសេចក្ដីសុចរិត › [ ម៉ាថាយ ៣:១៥ ] ។ តើវាចាំបាច់ដែរឬទេដែលពិធីបរិសុទ្ធដ៏ពិសិដ្ឋនេះត្រូវបានធ្វើឡើងនៅក្នុងទឹកទន្លេដ៏ស្រស់បំព្រងដែលរាក់បំផុតនៅលើភពផែនដីនេះ ។ តើទ្រង់អាចជ្រើសយកកន្លែងដែលប្រសើរជាងនេះដើម្បីធ្វើជានិមិត្តរូបនៃការបន្ទាបខ្លួនដ៏ជ្រាលជ្រៅដែលទ្រង់បានយាងទៅ និងមកពីកន្លែងដែលទ្រង់បានមានព្រះជន្មរស់ឡើងវិញដែរឬទេ ? »



**ភ្នំលលាដ៏ក្បាល ៖** « ជាកន្លែងដែលការឆ្កាងកើតឡើងនៅលើទួលមួយហៅថា កាល់កូថា ( ភាសាហេព្រើរ ) ឬ កាល់វ៉ារី ( ឡាតាំង ) មានន័យថា ‹ លលាដ៏ក្បាល › ។ លលាដ៏ក្បាលជានិមិត្តរូបនៃសេចក្ដីស្លាប់ ។ នៅកន្លែងដូច្នេះ ការពលិកម្មដ៏ធួនត្រូវបានបំពេញ ។ នៅលើឈើឆ្កាង ព្រះអង្គសង្គ្រោះនៃពិភពលោកត្រូវបានលើកព្យួររហូតដល់សុគតនៅក្នុងភាពដ៏សំខាន់បំផុតនៃភាពសំខាន់ៗទាំងអស់—គឺការទទួលស្គាល់ និងភាពពិតប្រាកដនៃព្រះចេស្ដាឈ្នះលើសេចក្ដីស្លាប់របស់ព្រះអម្ចាស់ » ។



*បានដកស្រង់ចេញមកពី រ័សុល អិម ណិលសុន « In This Holy Land »* Tambuli, *ខែ កុម្ភៈ ឆ្នាំ ១៩៩១ ទំព័រ ១៣, ១៧, ១៨ ។*

រូបភាពមកពី GETTY IMAGES

# ផុន ផាន

*ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*



*នៅពេលភ្លើងឆេះផ្ទះរបស់ផាន គាត់អាចគ្រាន់តែជួយសង្គ្រោះចៅទាំងបីរបស់គាត់ប៉ុណ្ណោះ ។ អ្វីៗគ្រប់យ៉ាងត្រូវបានឆេះហ្មត់ទៅជាផេះ ។ ផានបានខឹងសម្បារនឹងអ្នកជិតខាងដែលបង្កឲ្យមានភ្លើងឆេះ ។ នៅពេលកំហឹងរបស់គាត់បានរាលដាលដល់គ្រួសារ និងអ្នកជិតខាងរបស់គាត់ នោះផានបានដឹងថា គាត់ត្រូវតែមានការអភ័យទោស ។*

**ឡេសលី នីលសុន ជាងថតរូប**



ខ្ញុំបានដឹងថា អ្នកជិតខាងខ្ញុំក៏ក្រីក្រដូចជាខ្ញុំផងដែរ ។ គាត់គ្មានចេតនាធ្វើឲ្យមានភ្លើងឆេះផ្ទះឡើយ ! ប្រសិនបើខ្ញុំចង់ឲ្យគាត់សងការខូចខាតនេះ នោះគាត់នឹងមានការលំបាកណាស់ ហើយខ្ញុំនឹងនៅតែមានអារម្មណ៍ស្អប់ខ្ពើមដដែល ។ ខ្ញុំបានចាំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ថា យើងគួរតែស្រឡាញ់អ្នកជិតខាងរបស់យើង ។ ខ្ញុំបានទទួលអារម្មណ៍ថា ខ្ញុំគួរតែអភ័ទោស ។

នៅពេលខ្ញុំបានសម្រេចចិត្តអភ័យទោស នោះខ្ញុំបានទទួលអារម្មណ៍សុខសាន្ត ។

អ្នកជិតខាងរបស់ខ្ញុំនោះមានចិត្តរីករាយ នៅពេលខ្ញុំបានអភ័យទោសឲ្យគាត់ ។ គ្រួសាររបស់ខ្ញុំមានភាពរីករាយជាងមុនផងដែរ ។ ពេលខ្ញុំឃើញដូច្នេះ ខ្ញុំក៏មានចិត្តរីករាយដែរ ។

សមាជិក និងអ្នកជិតខាងបានបរិច្ចាគអ្វីៗដែលពួកគេអាចធ្វើបាន ដើម្បីជួយគ្រួសាររបស់ខ្ញុំ ។ ខ្ញុំបានទទួលអង្ករជាច្រើន ហើយបានចែកវាជាមួយមនុស្សដទៃទៀត ។ ពួកគេបានសួរខ្ញុំថា ហេតុអ្វីខ្ញុំឲ្យគេ ពេលខ្ញុំកំពុងស្ថិតក្នុងស្ថានភាពយ៉ាប់យ៉ឺនបែបនេះ ។ ខ្ញុំបានប្រាប់ពួកគេថា នៅពេលខ្ញុំបម្រើមនុស្សដទៃ នោះខ្ញុំបម្រើព្រះអម្ចាស់ហើយ ។ ខ្ញុំចង់ថ្វាយទៅទ្រង់ ដោយសារទ្រង់បានសម្ដែងអព្ភូតហេតុជាច្រើនក្នុងជីវិតរបស់ខ្ញុំ ។ យើងមានផ្ទះដ៏ស្រស់ស្អាតមួយ ស្អាតជាងផ្ទះចាស់ដែលឆេះនោះទៅទៀត ។

**ស្វែងរកបន្ថែមទៀត**

អែលឌើរ ឡារី ជេ អ៊ីខូ ហក បង្រៀនអំពីរបៀបដែលការអភ័យទោស ជួយអ្នកឲ្យបន្តឆ្ពោះទៅមុខ ហើយនាំភាពសុខសាន្តមកកាន់ជីវិតរបស់អ្នក ។ សូមអានសារលិខិតរបស់លោកនៅគេហទំព័រ **lds.org/go/1196** ។

ស្វែងរកការបង្ហាញអំពីសេចក្ដីជំនឿបន្ថែមទៀតនៅគេហទំព័រ **lds.org/go/18** ។







# គោលការណ៍នៃការងារបម្រើ

# គោលបំណងដែលនឹងផ្លាស់ប្ដូរការងារបម្រើរបស់យើង

*ខណៈដែលមានគោលបំណងជាច្រើនសម្រាប់ការងារបម្រើ នោះការខិតខំរបស់យើងនៅក្នុងការងារបម្រើគួរត្រូវបានដឹកនាំដោយបំណងប្រាថ្នាមួយ ដើម្បីជួយមនុស្សដទៃទៀតឲ្យសម្រេចបានការប្រែចិត្តជឿផ្ទាល់ខ្លួនមួយដែលស៊ីជម្រៅ ហើយប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះ ។*

នៅពេលយើងស្រឡាញ់មនុស្សដទៃដូចជាព្រះអង្គសង្គ្រោះ នោះយើងចង់ជួយពួកគេដូចជាទ្រង់ដែរ ។ ក្នុងនាមជាអ្នកគង្វាលល្អ ទ្រង់គឺជាគំរូដ៏ល្អបំផុតនៃការងារបម្រើដ៏មានន័យ ។

ដើម្បីធ្វើឲ្យការងារបម្រើរបស់យើងបានដូចជាទ្រង់ វាគឺជារឿងដ៏សំខាន់ដែលត្រូវចងចាំថា ការខិតខំរបស់ទ្រង់ដើម្បីស្រឡាញ់ លើកស្ទួយ ហើយប្រទានពរ មាននូវគោលដៅដ៏ខ្ពស់មួយលើសពីការបំពេញតាមសេចក្ដីត្រូវការភ្លាមៗទៅទៀត ។ ប្រាកដណាស់ ទ្រង់ជ្រាបពីសេចក្ដីត្រូវការប្រចាំថ្ងៃរបស់ពួកគេ ហើយមានសេចក្ដីមេត្តាករុណាចំពោះការរងទុក្ខបច្ចុប្បន្នរបស់ពួកគេ ។ ដូច្នេះ ទ្រង់បានព្យាបាល អភ័យទោស ហើយបានបង្រៀន ។ ប៉ុន្តែ ទ្រង់សព្វព្រះទ័យចង់ធ្វើលើសពីការមើលថែដល់សេចក្ដីស្រេកឃ្លានៅថ្ងៃនោះទៅទៀត ( សូមមើលយ៉ូហាន ៤:១៣–១៤ ) ។ ទ្រង់សព្វព្រះទ័យឲ្យមនុស្សដែលនៅជុំវិញទ្រង់ដើរតាមទ្រង់ ( សូមមើលលូកា ១៨:២២, យ៉ូហាន ២១:២២ ) ស្គាល់ទ្រង់ ( សូមមើលយ៉ូហាន ១០:១៤, គោលលទ្ធិ និង សេចក្ដីសញ្ញា ១៣២:២២–២៤ ) ហើយឈានដល់សក្ដានុពលដ៏ទេវភាពរបស់ពួកគេ ( សូមមើលម៉ាថាយ ៥:៤៨ ) ។ រឿងនេះក៏ដូចគ្នានៅសព្វថ្ងៃនេះដែរ ( សូមមើលគោលលទ្ធិ និង សេចក្ដីសញ្ញា ៦៧:១៣ ) ។



មានវិធីរាប់មិនអស់ដែលយើងអាចជួយផ្ដល់ពរជ័យដល់មនុស្សដទៃ ប៉ុន្តែនៅពេលគោលដៅចុងបញ្ចប់នៃការងារបម្រើរបស់យើងគឺដើម្បីជួយមនុស្សដទៃឲ្យមកស្គាល់ព្រះអង្គសង្គ្រោះ ហើយប្រែក្លាយកាន់តែដូចជាទ្រង់ នោះយើងនឹងខិតខំធ្វើការឆ្ពោះទៅរកថ្ងៃដែលយើងពុំចាំបាច់ត្រូវបង្រៀនអ្នកជិតខាងរបស់យើងឲ្យស្គាល់ព្រះអម្ចាស់ដោយសារយើងទាំងអស់គ្នានឹងស្គាល់ទ្រង់ ( សូមមើលយេរេមា ៣១:៣៤ ) ។

ទឹករស់ដោយ ស៊ីម៉ុន ឌី



### ការផ្ដោតសំខាន់របស់ព្រះអង្គសង្គ្រោះគឺលើសពីសេចក្ដីត្រូវការភ្លាមៗ

- មានមនុស្សមួយចំនួនបានខិតខំនាំមិត្តរបស់ពួកគេទៅឯព្រះយេស៊ូវដើម្បីបានជាពីជំងឺខ្វិន ។ នៅទីបញ្ចប់ ព្រះអង្គសង្គ្រោះបានព្យាបាលបុរសនោះ ប៉ុន្តែទ្រង់ក៏សព្វព្រះទ័យចង់អភ័យទោសដល់គាត់ឲ្យរួចផុតពីអំពើបាបរបស់គាត់ផងដែរ ( សូមមើល លូកា ៥:១៨–២៦ ) ។
- នៅពេលមនុស្សនាំយកស្ត្រីដែលប្រព្រឹត្តអំពើកំផឹតមកឯព្រះអង្គសង្គ្រោះ នោះការដកយកការផ្ដន្ទាទោសរបស់ទ្រង់បានសង្គ្រោះដល់ជីវិតនាងខាងរូបកាយ ។ ប៉ុន្តែទ្រង់ក៏សព្វព្រះទ័យចង់សង្គ្រោះនាងខាងវិញ្ញាណផងដែរ ដោយមានបន្ទូលប្រាប់នាងឲ្យ « អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ » ( សូមមើល យ៉ូហាន ៨:២–១១ ) ។
- ម៉ារា និង ម៉ាថា បានឲ្យគេនាំពាក្យទៅទូលព្រះយេស៊ូវ ដោយសូមឲ្យទ្រង់យាងមកព្យាបាលមិត្តរបស់ទ្រង់គឺ ឡាសារ ។ ព្រះយេស៊ូវដែលបានព្យាបាលមនុស្សដទៃរាប់មិនអស់ បានព្យារពេលការយាងទៅដល់របស់ទ្រង់ រហូតទាល់តែឡាសារបានស្លាប់ទៅ ។ ព្រះយេស៊ូវបានជ្រាបពីអ្វីដែលគ្រួសារនោះចង់បាន ប៉ុន្តែដោយការធ្វើឲ្យឡាសាររស់ពីស្លាប់មកវិញ នោះទ្រង់បានពង្រឹងដល់ទីបន្ទាល់របស់ពួកគេអំពីភាពជាព្រះរបស់ទ្រង់ ( សូមមើលយ៉ូហាន ១១:២១–២៧ ) ។

តើមានឧទាហរណ៍អ្វីផ្សេងទៀតដែលអ្នកអាចបន្ថែមក្នុងបញ្ជីនេះ ?

### តើយើងអាចធ្វើអ្វីខ្លះ ?

ប្រសិនបើគោលបំណងរបស់យើងគឺដើម្បីជួយមនុស្សដទៃឲ្យប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះ នោះវានឹងផ្លាស់ប្ដូររបៀបដែលយើងធ្វើការងារបម្រើ ។ នេះគឺជាវិធីមួយចំនួនដែលការយល់ដឹងនេះអាចដឹកនាំការខិតខំរបស់យើងដើម្បីធ្វើការងារបម្រើ ។

***យោបល់ទី ១ ៖ តភ្ជាប់ការបម្រើជាមួយនឹងព្រះអង្គសង្គ្រោះ***

រាល់ការខិតខំរបស់យើងដើម្បីធ្វើកិច្ចការល្អមានតម្លៃខ្លាំងណាស់ ប៉ុន្តែយើងអាចរកមើលឱកាសដើម្បីពង្រីកការបម្រើរបស់យើងដោយតភ្ជាប់វាជាមួយនឹងព្រះអង្គសង្គ្រោះ ។ ឧទាហរណ៍ ប្រសិនបើគ្រួសារដែលយើងផ្ដល់ការងារបម្រើមានជំងឺ អាហារមួយពេលប្រហែលជាមានប្រយោជន៍ ប៉ុន្តែការបង្ហាសេចក្ដីស្រឡាញ់ដ៏សាមញ្ញរបស់អ្នកអាចមានកាន់តែច្រើន តាមរយៈទីបន្ទាល់របស់អ្នកអំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះមានចំពោះពួកគេ ។ ជំនួយរបស់អ្នកសម្រាប់ការមើលថែទីធ្លាស្មៅនឹងទទួលបានការអរគុណ ប៉ុន្តែវាប្រហែលជាកាន់តែមានន័យទៀតជាមួយនឹងការផ្ដល់ឲ្យនូវការប្រសិទ្ធពរបព្វជិតភាពមួយ ។

អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « មនុស្សម្នាក់ដែលមានចិត្តល្អអាចជួយមនុស្សម្នាក់ប៉ះកង់ឡាន នាំមិត្តរួមបន្ទប់ទៅជួបវេជ្ជបណ្ឌិត ទទួលអាហារថ្ងៃត្រង់ជាមួយនឹងមនុស្សម្នាក់ដែលសោកសៅ ឬញញឹម ហើយនិយាយពាក្យសួស្ដីដែលធ្វើឲ្យគាត់មានភាពរីករាយ ។

« ប៉ុន្តែអ្នកធ្វើតាមបទបញ្ញត្តិទីមួយនឹងធ្វើបន្ថែមពីលើសកម្មភាពដ៏សំខាន់នៃការបម្រើទាំងនេះដោយឯកឯង » ។[1]

អត្ថបទ « គោលការណ៍នៃការងារបម្រើ » មានគោលបំណងជួយយើងឲ្យមើលថែគ្នាទៅវិញទៅមក—ពុំមែនយកវាទៅចែកចាយជាសារលិខិតនៅពេលទៅសួរទុក្ខឡើយ ។ នៅពេលយើងស្គាល់អស់អ្នកដែលយើងបម្រើ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិតយើងឲ្យដឹងអំពីសារលិខិតអ្វីខ្លះដែលពួកគេអាចត្រូវការបន្ថែមពីលើការមើលថែ និងសេចក្ដីមេត្តាករុណារបស់យើង ។

*យោបល់ទី ២ ៖ ផ្ដោតលើផ្លូវនៃសេចក្ដីសញ្ញា*

កាលប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ជាលើកដំបូងទៅកាន់សមាជិក ក្នុងនាមជាប្រធានសាសនាចក្រ លោកបានមានប្រសាសន៍ថា « សូមបន្តនៅលើផ្លូវនៃសេចក្ដីសញ្ញា » ។ ការធ្វើ និងការរក្សាសេចក្ដីសញ្ញា« នឹងបើកទ្វារទៅកាន់ពរជ័យ និងឯកសិទ្ធិខាងវិញ្ញាណទាំងអស់ ដែលមាន » ។[២]

ក្នុងនាមជាពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងបានជ្រមុជទឹក បានបញ្ជាក់ ហើយបានទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ សមាជិកបុរសសក្ដិសមទទួលបព្វជិតភាព ។ យើងទៅព្រះវិហារបរិសុទ្ធសម្រាប់អំណោយទានពិសិដ្ឋរបស់យើង ហើយដើម្បីផ្សារភ្ជាប់ជាមួយគ្នាជាគ្រួសារៀងរហូត ។ ពិធីបរិសុទ្ធនៃការសង្គ្រោះទាំងនេះ និងសេចក្ដីសញ្ញាដែលពាក់ព័ន្ធគឺចាំបាច់ចំពោះយើងឲ្យប្រែក្លាយដូចជាទ្រង់ ដើម្បីយើងអាចនៅជាមួយនឹងទ្រង់ ។

យើងអាចមានតួនាទីដ៏សំខាន់មួយដើម្បីដើរតួនៅក្នុងការជួយមនុស្សដទៃនៅតាមផ្លូវនោះ នៅពេលយើងជួយពួកគេរក្សាសេចក្ដីសញ្ញារបស់ពួកគេ ហើយរៀបចំខ្លួនធ្វើសេចក្ដីសញ្ញានាពេលអនាគត ។[៣] តើអ្នកអាចជួយបុគ្គលម្នាក់ៗ ឬក្រុមគ្រួសារដែលអ្នកប្រើឲ្យទទួលពិធីបរិសុទ្ធបន្ទាប់ដែលពួកគេត្រូវការដោយរបៀបណា ? ការណ៍នេះអាចមានន័យថា ការជួយរៀបចំខ្លួនឪពុកម្នាក់ឲ្យជ្រមុជទឹកកូនស្រីរបស់គាត់ ការពន្យល់ពីពរជ័យនៃសេចក្ដីសញ្ញាបន្ទាប់ដែលត្រូវធ្វើ ឬការចែកចាយវិធីដើម្បីមានបទពិសោធន៍មួយកាន់តែមានន័យ ដោយរំឭកសេចក្ដីសញ្ញារបស់យើងកាលទទួលទានសាក្រាម៉ង់ ។





*យោបល់ទី ៣ ៖ អញ្ជើញ ហើយលើកទឹកចិត្ត*

នៅពេលសមរម្យ សូមប្រឹក្សាអំពីការប្រែចិត្តជឿ និងការខិតខំរបស់ពួកគេឲ្យក្លាយកាន់តែដូចជាព្រះគ្រីស្ទជាមួយនឹងមនុស្សដែលអ្នកមើលថែ ។ ចូរប្រាប់ឲ្យពួកគេដឹងពីកម្លាំងដែលអ្នកឃើញពួកគេមាន ហើយស្ញើចសរសើរដល់ពួកគេ ។ សូមស្វែងរកចំណុចដែលពួកគេគិតថាពួកគេអាចកែលម្អ ហើយពិភាក្សាពីរបៀបដែលអ្នកអាចជួយ ។ ( សម្រាប់យោបល់បន្ថែមស្ដីពីការប្រឹក្សារួមគ្នាជាមួយនឹងមនុស្សដែលអ្នកផ្ដល់ការងារបម្រើ សូមមើល « Counsel about Their Needs » *Liahona,* ខែ កញ្ញា ឆ្នាំ ២០១៨ ទំព័រ ៦–៩ ) ។

សូមកុំខ្លាចដើម្បីអញ្ជើញពួកគេឲ្យធ្វើតាមព្រះអង្គសង្គ្រោះ ហើយអញ្ញាតឲ្យទ្រង់ជួយពួកគេឈានទៅដល់សក្ដានុពលដ៏ទេវភាពរបស់ពួកគេ ។ ការអញ្ជើញនេះអាចការផ្លាស់ប្ដូរជីវិត នៅពេលវារួមផ្សំនឹងការបង្ហាញពីភាពជឿជាក់របស់អ្នកចំពោះពួកគេ និងសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ។

ព្រះគ្រីស្ទ និងអ្នកមានវ័យក្មេង ដោយ ហាញ់ ហ្វមែន

**១. ចែកចាយ ។** ចូរទៀងត្រង់ ហើយក្លាហាន នៅពេលចែកចាយពីរបៀបដែលព្រះអង្គសង្គ្រោះបានជួយអ្នក នៅពេលអ្នកបានព្យាយាមខិតទៅជិតទ្រង់ តាមរយៈការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ទោះជាមានឧបសគ្គក្ដី ។

**២. សូមសន្យានូវពរជ័យ ។** មនុស្សត្រូវការហេតុផលពិតប្រាកដមួយដើម្បីផ្លាស់ប្ដូរ ដែលសំខាន់ជាងហេតុផលមិនផ្លាស់ប្ដូរ ។ ការពន្យល់ពីពរជ័យដែលទាក់ទងនឹងទង្វើមួយអាចផ្ដល់ការលើកទឹកចិត្តដ៏មានអនុភាព ( សូមមើលគោលលទ្ធិ និង សេចក្ដីសញ្ញាណ ១៣០:២០–២១ ) ។

**របៀបប្រាំមួយយ៉ាងដែលយើងអាចជួយមនុស្សដទៃឲ្យរីកចម្រើនឆ្ពោះទៅរកព្រះគ្រីស្ទ**

ខាងក្រោមនេះគឺជាយោបល់ដើម្បីគាំទ្រដល់មនុស្សដទៃ នៅក្នុងការធ្វើឲ្យជីវិតប្រសើរឡើង ហើយរីកចម្រើននៅលើផ្លូវនៃសេចក្ដីសញ្ញា ។ ( សូមមើល *ប្រកាសដំណឹងល្អរបស់យើង* ជំពូកទី ១១ សម្រាប់គំនិតបន្ថែមទៀត ) ។

**៣. អញ្ជើញ ។** ការរស់នៅតាមគោលការណ៍មួយនៃដំណឹងល្អនាំមកនូវទីបន្ទាល់មួយដែលពិត ( សូមមើលយ៉ូហាន ៧:១៧ ) ហើយវាដឹកនាំទៅរកការប្រែចិត្តជឿដ៏មុតមាំ ។[៤] រាល់ឥទ្ធិពលចំពោះគ្នាទៅវិញទៅមក ស្ទើរតែអាចដាក់បញ្ចូលនៅក្នុងការអញ្ជើញដ៏សាមញ្ញមួយដើម្បីធ្វើរឿងមួយដែលនឹងជួយពួកគេឲ្យរីកចម្រើន ។

**៤. ដាក់ផែនការជាមួយគ្នា ។** តើអ្វីទៅដែលចាំបាច់ត្រូវកើតឡើងចំពោះពួកគេ ដើម្បីរក្សាការតាំងចិត្តរបស់ពួកគេដើម្បីផ្លាស់ប្ដូរប្រកបដោយភាពជោគជ័យ ? តើអ្នកអាចជួយដោយរបៀបណា ? តើវាមានពេលវេលាកំណត់ដែរឬទេ ?

**៥. គាំទ្រ ។** ប្រសិនបើអាចធ្វើបាន សូមបង្កើតបណ្ដាញគាំទ្រមនុស្សមួយដែលវាអាចជួយបុគ្គលនោះឲ្យបន្តទទួលបានការលើកទឹកចិត្ត ហើយមានជោគជ័យ ។ យើងទាំងអស់គ្នាត្រូវការអ្នកគាំទ្រម្នាក់ ។

**៦. តាមដាន ។** សូមចែកចាយការរីកចម្រើនជាទៀងទាត់ ។ សូមបន្តផ្ដោតទៅលើផែនការនោះ ប៉ុន្តែសូមកែសម្រួលវា ប្រសិនបើចាំបាច់ ។ ចូរមានចិត្តអត់ធ្មត់ តស៊ូ ហើយលើកទឹកចិត្ត ។ ការផ្លាស់ប្ដូរអាចត្រូវការពេលវេលា ។



**ការអញ្ជើញឲ្យអនុវត្ត**

សូមពិចារណាពីវិធីដែលការខិតខំរបស់អ្នកដើម្បីផ្ដល់ការងារបម្រើ—ទោះតូច ឬធំក្ដី—អាចជួយមនុស្សដទៃឲ្យពង្រឹងការប្រែចិត្តជឿរបស់ពួកគេ ហើយប្រែក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះ ។

**សូមចែកចាយបទពិសោធន៍របស់អ្នក**

សូមផ្ញើមកកាន់យើងនូវបទពិសោធន៍របស់អ្នក នៅពេលអ្នកបានផ្ដល់ការងារបម្រើដល់មនុស្សដទៃ ឬទទួលបានការងារបម្រើ ។ សូមចូលទៅ liahona.lds.org ហើយចុចលើ « Submit an Article or Feedback » ។ ■

**កំណត់ចំណាំ**

១. នែល អិល អាន់ឌើរសិន « A Holier Approach to Ministering » ( Brigham Young University devotional ថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០១៨ ) ទំព័រ ៣, speeches.byu.edu ។
២. រ័សុល អិម ណិលសុន « As We Go Forward Together » *Liahona,* ខែ មេសា ឆ្នាំ ២០១៨ ទំព័រ ៧ ។
៣. សូមមើល ហិនរី ប៊ី អាវរិង « Daughters in the Covenant » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ១២៥–២៨ ។
៤. សូមមើល ដាវីឌ អេ បែដណា « ចិត្តជឿចំពោះព្រះអម្ចាស់ » *Liahona*, ខែ វិច្ឆិកា ឆ្នាំ ២០១២, ១០៦–១០៩ ។



*ម៉ារានាងរក្សាទុករឿងទាំងនោះ* ដោយ ហាវើត លីយ៉ុន

# ម៉ារា
## មាតារបស់ព្រះយេស៊ូវ

រឿងរបស់ម៉ារាគឺជាការរំឭកមិនចប់មិនហើយអំពីតម្លៃ
និងពរជ័យនៃភាពជាសិស្ស ។

**ដោយ ហ្គេយី ស្ត្រាធើន**
អនុសាស្ត្រាចារ្យនៃព្រះគម្ពីរពីបុរាណ សាកលវិទ្យាល័យព្រិកហាំ យ៉ង់

ម៉ារាមាតារបស់ព្រះយេស៊ូវគឺជាស្ត្រីម្នាក់នៃស្ត្រីពីរបីនាក់ដែលបានលើកឡើងនៅក្នុងព្រះគម្ពីរ ហើយគឺជាស្ត្រីតែម្នាក់គត់ដែលត្រូវបានព្យាករអំពីជីវិត និងការងារបម្រើ ប្រមាណជារាប់សតវត្សរ៍ពីមុនកំណើតរបស់គាត់ ( សូមមើល នីហ្វៃទី ១ ១១:១៥, ១៨; ម៉ូសាយ ៣:៨; អាលម៉ា ៧:១០ ) ។[១] អ្នកសរសេរព្រះគម្ពីរសញ្ញាថ្មីដូចជា ម៉ាថាយ, ម៉ាកុស, លូកា និង យ៉ូហាន ផ្តល់ការបង្ហាញដោយសង្ខេបអំពីជីវិត និងការងារបម្រើរបស់គាត់ ដោយសារពួកគេផ្តោតចិត្តទុកដាក់ផ្ទាល់ទៅលើព្រះអង្គសង្គ្រោះតែម្តង ។ ប៉ុន្តែព្រះវិហារគ្រិស្តសាសនាជំនាន់ដើមបានដាក់ងារដល់ម៉ារាថា *theotokos* ជា « អ្នកពរពោះ ឬមាតារបស់ព្រះ »[២] គឺជាការរំឭកនៃផ្នែកដ៏សំខាន់នៃតួនាទីរបស់គាត់នៅក្នុងផែនការរបស់ព្រះវរបិតា ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី ( ឆ្នាំ ១៩១៥–១៩៨៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានសរសេរថា ៖ « តើយើងអាចនិយាយដោយការគោរពដ៏ខ្លាំងអំពីគាត់ ដែលព្រះអម្ចាស់បានប្រទានពរលើសអស់ពីស្ត្រីទាំងអស់បានទេ ? មានព្រះគ្រីស្ទតែមួយអង្គគត់ ហើយមានម៉ារាតែម្នាក់គត់ ។ បុគ្គលម្នាក់ៗជាអ្នកមានត្រកូលខ្ពស់ និងអស្ចារ្យនៅក្នុង [ ជីវិតមុនឆាកជីវិតនេះ ] ហើយម្នាក់ៗត្រូវបានតែងតាំងពីមុនលោកិយនេះឲ្យផ្តល់ការងារបម្រើដែលគាត់បានធ្វើ ។ យើងពុំអាចទប់មិនគិតបានទេថា ព្រះវរបិតានឹងជ្រើសរើសវិញ្ញាណស្ត្រីដ៏អស្ចារ្យដើម្បីធ្វើជាមាតារបស់ព្រះរាជបុត្រាទ្រង់ ក៏ដូចជាទ្រង់បានជ្រើសរើសវិញ្ញាណបុរសដូចជាទ្រង់ឲ្យធ្វើជាព្រះអង្គសង្គ្រោះឡើយ ។ . . . យើងគួរតែ . . . គោរពម៉ារាដោយការផ្តល់តម្លៃត្រឹមត្រូវនោះដែលជារបស់គាត់ » ។[៣]

ដំណើររឿងរបស់លូកាគឺជារឿងស្តីពីការប្រកាសប្រាប់ដល់ម៉ារា ( សូមមើល លូកា ១:២៦–៥៦ ) ដែលផ្តល់ជាការបង្ហាញដល់យើង ដើម្បីមានអំណរគុណកាន់តែខ្លាំងដល់យុវនារីដ៏អស្ចារ្យនេះ ។ តាមរយៈទំនាក់ទំនងរបស់គាត់ជាមួយនឹងទេវតាកាព្រីយ៉ែល និង អេលីសាបិត នោះយើងឃើញយុវនារីម្នាក់ព្យាយាមស្វែងយល់ និងយល់ដឹងអំពីការហៅដ៏ពិសេសរបស់គាត់មកពីព្រះ ។ ការហៅដ៏ធំធេងនោះត្រូវតែមានទម្ងន់ធ្ងន់ធ្ងរណាស់លើបុគ្គលម្នាក់ដែលនៅក្មេង ប៉ុន្តែគាត់បានត្រៀមរួចជាស្រេចដើម្បីចុះចូលឆន្ទៈរបស់គាត់ទៅនឹងព្រះទ័យរបស់ព្រះវរបិតា ។ រឿងរបស់គាត់រំឭកយើងថា ព្រះស្គាល់បុត្រាបុត្រីទាំងអស់របស់ទ្រង់ ហើយទ្រង់ហៅបុរស និងស្ត្រីសាមញ្ញៗ ដើម្បីចូលរួមក្នុងការជួយស្ថាបនានគររបស់ទ្រង់ក្នុងរបៀបដ៏អស្ចារ្យ ។ គាត់បានក្លាយជាសិស្សដំបូងគេរបស់ព្រះយេស៊ូវ ហេតុដូច្នោះហើយ គាត់គឺជាគំរូមួយសម្រាប់មនុស្សទាំងអស់ដែលជ្រើសរើសធ្វើតាមទ្រង់ ។

### ណាសារ៉ែត ៖ ផ្ទះរបស់ម៉ារា

ជាអកុសល ព្រះគម្ពីរសញ្ញាថ្មីពុំប្រាប់យើងអំពីឪពុកម្តាយរបស់ម៉ារា កំណើតរបស់គាត់ ឬអ្វីៗផ្សេងទៀតអំពីជីវិតគាត់នៅណាសារ៉ែតឡើយ ។ លូកាពិពណ៌នាពីភូមិណាសារ៉ែតថាជា *រដ្ឋ* មួយដែលអាចបកប្រែថា ជាទីក្រុង ឬជីប្រជុំជន ប៉ុន្តែវាពុំមែនជាទីកន្លែងដ៏ធំដុំទេ ។ នៅក្រៅព្រះគម្ពីរសញ្ញាថ្មី ណាសារ៉ែតពុំត្រូវបានលើកឡើងនៅក្នុងអត្ថបទណាឡើយ រហូតដល់ចុងសតវត្សរ៍ទីពីរនៃគ្រិស្តសករាជ ។

យើងដឹងច្បាស់ថា ណាសារ៉ែតមានទីតាំងនៅលើទួលមួយ ក្នុងវាលទំនាបកាលីឡេ មើលទៅឃើញជ្រលងភ្នំយេរៀលដែលមានដីដ៏មានជីជាតិ ចម្ងាយ ១០៥ គីឡូម៉ែត្រនៅភាគខាងជើងនៃទីក្រុងយេរូសាឡិម ។ បុរាណវត្ថុវិទ្យាបង្ហាញថា នៅសតវត្សរ៍ទីមួយណាសារ៉ែត

គឺមានលក្ខណៈជាភូមិមួយ ជាជាងជាទីក្រុង ឬទីប្រជុំជន ដែលមានប្រជាជនប្រហែលជា ៤០០–៥០០ នាក់ ។[៤] ជាមួយនឹងការមិនរាប់បញ្ចូលមួយចំនួន ប្រជាជនភាគច្រើននៅទូទាំងស្រុកកាលីឡេបានពុះពារណាស់ក្នុងការរស់នៅដោយប្រកបរបរជា កម្មករ ចិញ្ចឹមបសុសត្វនេសាទត្រី ហើយជាកសិករ ដើម្បីស្វែងរកអាហារសម្រាប់គ្រួសាររបស់ពួកគេ និងបង់ពន្ធ ។ ភូមិនេះគ្មានបន្ទាយការពារទេ គ្មានភស្តុតាងណាដែលបង្ហាញថា វាមានផ្លូវចាក់ស៊ីម៉ង់ត៍ ឬសំណង់ធំៗឡើយ ហើយវាក៏គ្មានការប្រើប្រាស់វត្ថុល្អប្រណិតនានាដូចជា ថ្មម៉ាប រូបគំនូរ ឬគំនូរជាប់នឹងជញ្ជាំងនៅក្នុងអគារនានា ឬផ្ទះនានាមានសម្ភារល្អៗដែលបាននាំចូលពីទីណាឡើយ ។[៥] ផ្ទះនៅក្នុងសតវត្សរ៍ទីមួយចំនួនពីរដែលត្រូវបានគាស់កកាយរកឃើញ គឺជាផ្ទះដែលពុំមានទំហំធំឡើយ ដែលមានបន្ទប់ពីរ ដំបូលប្រក់ស្បូវ និងទីធ្លាមុខផ្ទះតូចមួយ ។[៦] ទំនៀមទម្លាប់នៃការបញ្ចុះសព និងបំណែកចុចថ្មកំបោរមួយចំនួនបង្ហាញថា ប្រជាជនគឺជាពួកសាសន៍យូដាជាជាងពួកសាសន៍ដទៃ ។

ទោះបីជាគំហើញទាំងនេះពុំជាប់ទាក់ទងផ្ទាល់ទៅនឹងម៉ារា ឬគ្រួសាររបស់គាត់ក្តី គំហើញទាំងនេះផ្តល់គំនិតមួយដល់យើងអំពីលក្ខណៈនៃជីវិតរបស់គាត់នៅភូមិណាសារ៉ែត ៖ ជាក្មេងស្រីស្រុកស្រែរស់នៅក្នុងភូមិជនបទមួយ ឆ្ងាយពីមជ្ឈមណ្ឌលសាសនានៃទីក្រុងយេរូសាឡិមជាទីក្រុងដែលមានព្រះវិហារបរិសុទ្ធ ពួកសង្ឃអភិជន និងទ្រព្យសម្បត្តិស្តុកស្តម្ភ ។ ទោះបីគាត់នៅក្មេងក្តី គាត់បានធ្វើការជាមួយម្តាយគាត់ និងស្ត្រីដទៃទៀតក្នុងភូមិ ត្បាញក្រណាត់ ចម្អិនអាហារ រកឧស ដងទឹកពីអាង ឬអណ្តូងក្នុងភូមិ ហើយធ្វើការនៅក្នុងវាលស្រែ—ធ្វើអ្វីៗទាំងអស់ដើម្បីជួយចិញ្ចឹមគ្រួសារគាត់ពីមួយថ្ងៃទៅមួយថ្ងៃ ។

## ការហៅរបស់ម៉ារា

រឿងរបស់ម៉ារានៅក្នុងគម្ពីរលូកាបើកបង្ហាញអំពីការបង្ហាញព្រះកាយរបស់ទេវតាកាព្រីយ៉ែល ជាទេវតាដដែលនោះដែលបានបង្ហាញកាយកាលពីមុនដល់សាការីនៅក្នុងព្រះវិហារបរិសុទ្ធ ( សូមមើល លូកា ១:១១, ១៩, ២៦ ) ។ នៅពេលទេវតាកាព្រីយ៉ែលបង្ហាញព្រះកាយ ម៉ារាគឺជាយុវនារីម្នាក់ដែលត្រូវបានគេស្តីដណ្តឹងឲ្យរៀបការនឹងយ៉ូសែប ( សូមមើល លូកា ១:២៧ ) ។ ទោះបីជាយើងពុំដឹងថា ម៉ារាមានអាយុប៉ុន្មាននៅគ្រានោះក្តី នៅសម័យបុរាណការរៀបចំសម្រាប់កិច្ចសន្យាអាពាហ៍ពិពាហ៍នេះអាចធ្វើបាន ទោះពីមុនពេញវ័យក្តី ។ ការបង្ហាញព្រះកាយ និងការប្រកាសរបស់កាព្រីយ៉ែលថា ម៉ារាដែល « ប្រកបដោយព្រះគុណ » ថា « ព្រះអម្ចាស់ទ្រង់គង់នៅជាមួយនឹងនាង » ថា « ក្នុងបណ្តាពួកស្រីៗ នាងជាស្ត្រីមានពរពិត » ហើយយោងតាមការបកប្រែរបស់យ៉ូសែប ស្ម៊ីធ នៃ លូកា ១:២៨ នាងគឺជា « ស្ត្រីដ៏ជម្រើស » ( សូមមើលផងដែរ អាលម៉ា ៧:១០ ) ត្រូវតែបណ្តាលឲ្យមានប្រតិកម្មនៃការភាន់ច្រឡំដ៏ច្របូកច្របល់ និងភ័យខ្លាចដល់ម៉ារា ។ យើងអាចគ្រាន់តែស្រមៃឃើញគំនិតនានាដែលអាចកើតមានក្នុងចិត្តរបស់គាត់នៅគ្រានោះ ប៉ុន្តែគំនិតនោះអាចរួមមាននូវសំណួរដូចជា « ហេតុអ្វីព្រះចាត់ទុកខ្ញុំថា ‹ ក្នុងបណ្តាពួកស្រីៗ ខ្ញុំជាស្ត្រីមានពរពិត › ? » « ហេតុអ្វី ‹ ព្រះសព្វព្រះទ័យនឹងខ្ញុំ › ហើយតើវាមានន័យយ៉ាងណា ? » « ហេតុអ្វីព្រះបញ្ជូនកាព្រីយ៉ែលមកខ្ញុំ ម្តេចមិនទៅរកស្ត្រីផ្សេងទៀតនៅក្នុងភូមិណាសារ៉ែត ឬក្នុងទីក្រុងយេរូសាឡិមទៅ ? » ប្រាកដណាស់ គាត់គឺជាពូជពង្សដាវីឌ ( សូមមើល លូកា ១:៣២; រ៉ូម ១:៣ ) ប៉ុន្តែរឿងនោះវាពុំសូវមានន័យអ្វីទេនៅក្រោមការត្រួតត្រារបស់ពួករ៉ូម ។ លើសពីនោះទៅទៀត នាងគ្រាន់តែជាក្មេងស្រីម្នាក់មកពីគ្រួសារកសិករដែលរស់នៅក្នុងភូមិតូចមួយប៉ុណ្ណោះ ។ ដូចណាថាណែលបានសួរពេលក្រោយមកទៀតថា « តើមានអ្វីដ៏ល្អអាចចេញពីណាសារ៉ែតមកបានឬទេ ? » ( យ៉ូហាន ១:៤៦ ) ។

កាព្រីយ៉ែលពុំឆ្លើយគ្រប់សំណួរទាំងអស់ដែលម៉ារាអាចមានក្នុងគំនិត និងចិត្តរបស់គាត់ឡើយ ។ ផ្ទុយទៅវិញ ទ្រង់បន្តសារលិខិតរបស់ទ្រង់ថា ៖ ម៉ារានឹងពរពោះ ប៉ុន្តែពុំមែនជាកូនធម្មតានោះទេ ។ កូនរបស់គាត់នឹងត្រូវបានហៅថា « ព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត » ហើយនឹងទទួល « រាជ្យនៃហ្លួងដាវីឌជាឰយុកោទ្រង់ » ( សូមមើល លូកា ១:៣២–៣៣ ) ។ ម្យ៉ាងទៀត ទេវតាកាព្រីយ៉ែលបានមានបន្ទូលប្រាប់ទៅម៉ារាថា កូនរបស់គាត់គឺជា ព្រះរាជបុត្រានៃព្រះ និងជាព្រះមែស៊ីដែលបានសន្យា ។ ប្រសិនបើម៉ារាមានការភាន់ច្រឡំ ហើយភ័យខ្លាចនៅចំពោះការប្រកាសនេះ នោះយើងគ្រាន់តែអាចស្រមៃឃើញពីស្ថានភាពតានតឹងផ្នែកផ្លូវចិត្តរបស់គាត់បន្ទាប់ពីរឿងនោះប៉ុណ្ណោះ ។

ចូរពិចារណាអំពីគោលការណ៍មួយដែលផ្នែកនេះក្នុងរឿងរបស់ម៉ារាបង្រៀនអំពីភាពជាសិស្ស ។ ផែនការរបស់ព្រះសម្រាប់ម៉ារាពុំមែនជាអ្វីដែលគាត់បានសូមធ្វើឡើយ ! កាព្រីយ៉ែលបានបង្ហាញព្រះកាយដល់សាការី ដោយសារលោក និងអេលីសាបិត បានអធិស្ឋានទូលសូមអព្ភូតហេតុឲ្យមានកូនមួយ ប៉ុន្តែកាព្រីយ៉ែលបានយាងមកជួបម៉ារាក្នុងកាលៈទេសៈមួយផ្សេងពីនោះខ្លាំងណាស់ ៖ ពុំមែនដើម្បីបំពេញតាមការទូលសូមអង្វរឡើយ ប៉ុន្តែប្រកាសប្រាប់អំពីព្រះទ័យរបស់ព្រះសម្រាប់គាត់វិញ ។ ជាមួយនឹងការរង់ចាំដើម្បីរៀបអាពាហ៍ពិពាហ៍ ម៉ារាប្រហែលជាបានគិតអំពីលទ្ធភាពនៃការមានកូននៅពេលខាងមុខជាក់ជាមិនខានឡើយ ។ ប៉ុន្តែទោះបីជាមានរលកមួយនៃការរំពឹងទុករបស់ព្រះនៅក្នុងពួកសាសន៍យូដានៅក្នុងសតវត្សរ៍ទីមួយក្តី តើម៉ារានឹងគិតថាគឺជានាងដែលជាក្មេងស្រីស្រុកស្រែមកពីភូមិណាសារ៉ែតឬ ដែលនឹងក្លាយជាមាតានៃព្រះមែស៊ីនោះ ? ប្រហែលជាអត់ទេ ។ រឿងសំខាន់នោះគឺថា ការហៅនៃភាពជាសិស្សជារឿយៗ តម្រូវឲ្យមានការផ្លាស់ប្តូរផែនការជីវិតផ្ទាល់ខ្លួនរបស់យើង ។

លូកាផ្តោតកំណត់ត្រារបស់គាត់ទៅលើការប្រកាសរបស់កាព្រីយ៉ែល ហើយបន្ទាប់មកអេលីសាបិត ។ ប៉ុន្តែមានឱកាសបីដង នៅពេលម៉ារាបង្ហាញពីគំនិត និងអារម្មណ៍របស់គាត់ ។

## សំណួរដែលបំផុសគំនិត

ដំបូងគឺសំណួររបស់គាត់ទៅកាន់កាព្រីយ៉ែល « ខ្ញុំមិនស្គាល់ប្រុសណាផង ដូច្នេះតើធ្វើដូចម្តេចនឹងឲ្យការនេះសម្រេចបាន ? » ( លូកា ១:៣៤ ) ។ សំណួររបស់គាត់គឺជាសំណួរដ៏មានហេតុផលមួយនៅក្នុងកាលៈទេសៈនោះ ។ វារំឭកអ្នកអានអំពីសំណួររបស់សាការីថា



*ការប្រកាសប្រាប់ដំណឹងអំពីកំណើត ដោយ យ៉ូសែប ប្រ៊ីកឃី*

*ទេវតាកាព្រីយ៉ែលបានបង្ហាញព្រះកាយដល់ម៉ារាជាមួយនឹងសារលិខិតដ៏អស្ចារ្យដែលថា « ក្នុងបណ្ដាពួកស្រីៗ នាងជាស្ត្រីមានពរពិត » ហើយថាគាត់នឹងមានគភ៌ដែលជាព្រះរាជបុត្រានៃព្រះ ។*

« តើខ្ញុំនឹងដឹងសេចក្ដីនោះបានដោយសារអ្វី ? [ ឧទាហរណ៍ ថា អេលីសាបិតនឹងបង្កើតកូនប្រុសមួយ ] » ( ខទី ១៨ ) ។ សំណួររបស់គាត់បង្ហាញមន្ទិលសង្ស័យអំពីការឆ្លើយតបរបស់កាព្រីយ៉ែលទៅនឹងការអធិស្ឋាន ដែលសាការីបានទូលសូមទៅព្រះដោយផ្ទាល់ ប៉ុន្តែសំណួររបស់ម៉ារាវិញ ស្វែងរកការបញ្ជាក់អំពីការប្រកាសព្រះទ័យរបស់ព្រះសម្រាប់នាង ។ នៅពេលមានការអញ្ជើញរបស់ព្រះឲ្យពួកសិស្សលើកកម្ពស់ និងប្ដូរចេញពីភាពស្រណុកសុខស្រួលរបស់ពួកគេ នោះសំណួរនឹងកើតមានចៀសមិនរួច ហើយសំណួរដែលបំផុសគំនិតដឹកនាំទៅរកវិវរណៈ ។

ចម្លើយរបស់កាព្រីយ៉ែលទៅនឹងសំណួររបស់ម៉ារាមានបីផ្នែក ៖

១. ទីមួយ ទ្រង់ប្រាប់ម៉ារាថា « ព្រះវិញ្ញាណបរិសុទ្ធនឹងយាងមកសណ្ឋិតលើនាង » ( ខទី ៣៥ ) ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះចេស្ដាដែលពួកសិស្សនៅគ្រប់ជំនាន់ទាំងអស់ត្រូវបានលើកតម្កើងការហៅរបស់ពួកគេ ។ ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានបង្រៀនថា « ចូរចាំថា កិច្ចការងារនេះ គឺពុំមែនជារបស់អ្នក និងខ្ញុំតែឯងនោះទេ ។ វាគឺជាកិច្ចការរបស់ព្រះអម្ចាស់ ហើយនៅពេលយើងស្ថិតនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ យើងនឹងទទួលបានជំនួយពីព្រះអម្ចាស់ ។ ចូរចាំថា អ្នកដែលព្រះអម្ចាស់បានហៅ ព្រះអម្ចាស់នឹងធ្វើឲ្យគេសមនឹងកិច្ចការនោះ » ។[៧] បន្ទាប់មក ទេវតាកាព្រីយ៉ែលផ្ដល់ព័ត៌មានជាក់លាក់ដល់ម៉ារាអំពីស្ថានភាពរបស់គាត់ថា ៖ « ហើយព្រះចេស្ដានៃព្រះដ៏ខ្ពស់បំផុត នឹងមកគ្របបាំងនាងដោយស្រមោល[៨] ហេតុដូច្នេះ បុត្របរិសុទ្ធដែលនឹងប្រសូតមកនោះ ត្រូវហៅថាជាព្រះរាជបុត្រានៃព្រះ » ( ខទី ៣៥ ) ។

២. ទីពីរ កាព្រីយ៉ែលប្រាប់ម៉ារាអំពីអេលីសាបិត ជាមនុស្សម្នាក់ដែលកំពុងមានបទពិសោធន៍ស្រដៀងគ្នា ទោះជាមិនមែនជាការពរពោះដោយអព្ភូតហេតុដូចគ្នាក្ដី ( សូមមើល ខទី ៣៦ ) ។ ការពរពោះរបស់អេលីសាបិតគឺជាទីសម្គាល់មួយដល់ម៉ារាថា គាត់ពុំឯកោឡើយ យ៉ាងហោចណាស់មានមនុស្សម្នាក់ទៀតដែលមានអារម្មណ៍មួយចំនួនដែលគាត់នឹងមានផងដែរ ។

៣. ទីបី កាព្រីយ៉ែលប្រកាសយ៉ាងច្បាស់ថា « ដ្បិតការអ្វីដែលព្រះទ្រង់ធ្វើពុំបាននោះគ្មានសោះឡើយ » ( ខទី ៣៧ ) ។ ព្រះបានធ្វើកិច្ចការដែលពុំអាចធ្វើទៅបាន នៅពេលអេលីសាបិតមានទម្ងន់ ។[៩] ការប្រកាសរបស់កាព្រីយ៉ែលគឺជាការរំឭកមួយដល់ពួកសិស្សនៅគ្រប់ជំនាន់ថា នៅពេលយើងឆ្លើយតបចំពោះការអញ្ជើញរបស់ព្រះ នោះអព្ភូតហេតុអាចកើតមានឡើង ។



*រឿងរបស់ម៉ារា និងអេលីសាបិត គឺត្រូវបានវេញត្របាញ់បញ្ចូលគ្នា តាមរយៈសេចក្ដីស្រឡាញ់ និងការគាំទ្រគ្នាទៅវិញទៅមកក្នុងគ្រាដែលត្រូវការគ្នា ។*

## ឆន្ទៈរបស់ពួកសិស្ស

នៅក្នុងចិត្តខ្ញុំ ការឆ្លើយតបលើកទីពីររបស់ម៉ារានៅក្នុងការសរុបរឿងខ្លីៗអំពីការតាំងចិត្ត និងទស្សនវិស័យនៃសិស្សម្នាក់ ៖ « មើល ខ្ញុំនេះជាអ្នកបម្រើរបស់ព្រះអម្ចាស់ ដូច្នេះសូមឲ្យបានសម្រេចដូចពាក្យលោកចុះ » ( លូកា ១:៣៨ ) ។ ពាក្យ « អ្នកបម្រើ » បង្ហាញថា ម៉ារាបានជ្រើសរើសទទួលយកការហៅដែលព្រះបានប្រទានដល់គាត់ ។ សេចក្ដីថ្លែងនេះគឺជារបស់ម៉ារាស្ដីពីអ្វីដែលកូនរបស់គាត់នឹងនិយាយនៅក្នុងសួនច្បារគែតសេម៉ានី « កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ » ( លូកា ២២:៤២ ) ។ វាហាក់ដូចជាច្បាស់ណាស់ថា នៅត្រង់ចំណុចនេះនៅក្នុងដំណើររបស់គាត់ គាត់អាចយល់នូវអ្វីៗទាំងអស់ដែលត្រូវបានតម្រូវពីគាត់—ក្រោយមកស៊ីម៉ូនព្យាករទៅកាន់គាត់ថា « នឹងមានដាវចាក់ទំលុះព្រលឹងនាងដែរ » ( លូកា ២:៣៥ )—ទោះជាយ៉ាងណាក្ដី ម៉ារាជ្រើសរើសបន្តឆ្ពោះទៅមុខដោយសេចក្ដីជំនឿ ។

« រួចទេវតាក៏ថយចេញពីនាងបាត់ទៅ » ( លូកា ១:៣៨ ) ។ នៅពេលកាព្រីយ៉ែលចាកចេញទៅ ម៉ារានៅតែម្នាក់ឯង ។ ទោះវាជារឿងមួយដែលសិស្សម្នាក់ត្រូវបានប្រកាសប្រាប់ដូចជារឿងរបស់គាត់នៅក្នុងវត្តមានរបស់សារទូតនៃព្រះក្ដី តើគាត់ត្រូវធ្វើអ្វីខ្លះក្នុងពេលដែលទេវតាបានយាងចេញទៅបាត់នោះ ? តើគាត់ពន្យល់បទពិសោធន៍នេះដល់ឪពុកម្ដាយ ឬដល់យ៉ូសែបដោយរបៀបណា ? តើវាមានតម្លៃអ្វីដល់គាត់ ប្រសិនបើពួកគាត់ ឬប្រជាជននៅណាសារ៉ែតពុំព្រមជឿគាត់នោះ ? ការរស់នៅរបស់នាងដែលមានអាយុបានមួយភាគបួននៃជីវិតនៅក្នុងសាណារ៉ែតនោះ អាចប្រែជាលំបាកដល់នាង ។

ដូច្នេះគាត់បានរំឭកអំពីផ្នែកទីពីរនៃចម្លើយរបស់កាព្រីយ៉ែលទៅនឹងសំណួរ និងដំណើររបស់គាត់ទៅផ្ទះអេលីសាបិត ។ សារជាថ្មីម្ដងទៀត រឿងបើកចំហរពីររបស់លូកាគឺវេញត្របាញ់ចូលគ្នា ។ មិនយូរប៉ុន្មានបន្ទាប់ពីម៉ារាជម្រាបសួរអេលីសាបិត « នោះកូនក៏បម្រះនៅក្នុងផ្ទៃ រួចគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ ៖ ក៏បន្លឺសំឡេងយ៉ាងខ្លាំងថា ក្នុងបណ្ដាពួកស្រីៗ គឺនាងហើយ ជាស្ត្រីមានពរពិត ព្រមទាំងកូននៅក្នុងផ្ទៃនាងផង » ( លូកា ១:៤១–៤២ ) ។ ការស្វាគមន៍របស់គាត់ដែលដឹកនាំដោយព្រះវិញ្ញាណ បានបញ្ជាក់ដល់អ្វីដែលកាព្រីយ៉ែលធ្លាប់បានប្រកាសអំពីពររបស់ម៉ារាដែលមានក្នុងបណ្ដាពួកស្រីៗ ។ ឥឡូវម៉ារាមានសាក្សីទីពីរអំពីការហៅរបស់គាត់ ប៉ុន្តែវាកើតឡើងបាន បន្ទាប់ពីគាត់មានឆន្ទៈទទួលយកការហៅនោះប៉ុណ្ណោះ ។

ដំណើររឿងរបស់ម៉ារា និង អេលីសាបិតគឺជាការរំឭកមួយអំពីទិដ្ឋភាពចម្បងពីរនៅក្នុងជីវិតនៃពួកសិស្សសម័យទំនើបនេះ ។ វាជាការរំឭកអំពីតម្លៃជានិមិត្តរូបដ៏អស្ចារ្យនៃដួងចិត្តរបស់សមាគមសង្គ្រោះនៅជុំវិញពិភពលោក ៖ ស្ត្រីដែលមានអាយុខុសៗគ្នា និងស្ថិតនៅក្នុងដំណាក់កាលជីវិតផ្សេងៗគ្នា បានរួមគ្នាគាំទ្រ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមកនៅក្នុងគ្រាខ្វះខាត ។ វាក៏ជាការរំឭកមួយផងដែរថា ព្រះពុំបោះបង់អស់អ្នកដែលទ្រង់បានហៅនៅក្នុងគ្រាខ្វះខាតរបស់ពួកគេឡើយ ប៉ុន្តែជារឿយៗទ្រង់ឆ្លើយតបដោយការឱបក្រសោបពួកគេនៅក្នុងរង្វង់ដៃរបស់មនុស្សដទៃ ជាអ្នកដែលទ្រង់បានហៅផងដែរ ។

## ការសរសើរតម្កើង

ការបង្ហាញចុងក្រោយរបស់ម៉ារាត្រូវបានគេស្គាល់ថាជាការសរសើរតម្កើង ហើយវាគឺជាការបង្ហាញរបស់គាត់អំពីអំណរនៅក្នុងការឆ្លើយតបចំពោះការប្រកាសរបស់

*ការជួបគ្នារវាងម៉ារា និងអេលីសាបិត ដោយ ខាល ហ្វៀនរិច ប្លុច*

អេលីសាបិត ។ គាត់បង្ហាញអំពីអារម្មណ៍របស់គាត់ស្ដីពីអ្វីដែលបានកើតឡើងក្នុងជីវិតរបស់គាត់ និងឆ្លុះបញ្ចាំងអំពីការយល់ថ្មីដែលគាត់ដឹងអំពីតួនាទីរបស់គាត់នៅក្នុងផែនការរបស់ព្រះ ។ ដំបូង និងមុនគេបង្អស់ គាត់មានអារម្មណ៍លើកតម្កើង សរសើរ ហើយសរសើរតម្កើងព្រះរបស់គាត់ ដែលគាត់រីករាយដូចជាព្រះអង្គសង្គ្រោះរបស់គាត់ ( សូមមើល លូកា ១:៤៦–៤៧ ) ។ គាត់ឃើញនៅក្នុងបទពិសោធន៍របស់គាត់នូវសេចក្ដីមេត្តាករុណាឥតឈប់ឈររបស់ព្រះ ទាំងនៅក្នុងការពិតដែលទ្រង់បានជ្រើសរើសនរណាម្នាក់ដែលមាន « សណ្ឋានទាបថោក » ដូចជាគាត់ ( សូមមើល ខទី ៤៨–៥០ ) និងនៅក្នុងភាពពិតដែលថា ទ្រង់បានជ្រើសរើសគាត់ឲ្យដើរតួយ៉ាងសំខាន់មួយនៅក្នុងការបំពេញសេចក្ដីសញ្ញាអ័ប្រាហាំ ( សូមមើល ខទី ៥៤–៥៥ ) ។

« ម៉ារាក៏នៅជាមួយនឹង [ អេលីសាបិត ] ប្រហែលជា៣ ខែទើបត្រឡប់ទៅផ្ទះខ្លួនវិញ » ( ខទី ៥៦ ) ។ ឥឡូវម៉ារាបានរៀបចំខ្លួនកាន់តែច្រើនដើម្បីបំពេញការហៅមកពីព្រះរបស់គាត់ ។

## គំរូរបស់ម៉ារាសម្រាប់យើង

ពួកសិស្សសម័យទំនើបគឺមិនដូចគ្នានឹងរឿងរបស់ម៉ារាឡើយ ទាំងតាមរយៈវប្បធម៌ និងទាំងរយៈពេល ២០០០ ឆ្នាំនេះ ។ ទោះជាយ៉ាងណាក៏ដោយ រឿងរបស់ម៉ារាគឺជាការរំឭកមិនចប់មិនហើយអំពីតម្លៃនៃភាពជាសិស្ស ។ ព្រះរំពឹងឲ្យអ្នកដើរតាមទ្រង់បោះជំហានឆ្ពោះទៅតាមការអញ្ជើញដែលទ្រង់ប្រទានដល់ពួកគេ ។ ប្រធាន រ័សុល អិម ណិលសុន រំឭកយើងថា « ព្រះបានសុំឲ្យបុត្រាបុត្រីក្នុងសេចក្ដីសញ្ញារបស់ទ្រង់ធ្វើកិច្ចការលំបាកៗជានិច្ច » ។[10] ម៉ារាត្រូវបានរាប់បញ្ចូល ហើយយើងក៏ត្រូវបានរាប់បញ្ចូលផងដែរ ។ ការអញ្ជើញរបស់យើងគឺ ការមានសេចក្ដីជំនឿដើម្បីចុះចូលឆន្ទៈរបស់យើងទៅនឹងព្រះទ័យទ្រង់ ដើម្បីទទួលយកការហៅរបស់ទ្រង់ដោយសេចក្ដីជំនឿថា ព្រះវិញ្ញាណរបស់ទ្រង់នឹងតម្កើងយើងក្នុងការបម្រើរបស់ទ្រង់ ។ បូនី អេច ខ័រដុន ប្រធានយុវនារីទូទៅ ក៏រំឭកយើងថា « យើងអាចធ្វើកិច្ចការលំបាកៗបាន » ហើយក្រោយមកគាត់បន្ថែមទៀតថា « ប៉ុន្តែយើងក៏អាចធ្វើវាដោយអំណរផងដែរ » ។[11]

ក្នុងនាមជាសិស្សសម័យទំនើប តើអ្វីទៅគឺជាការសរសើរតម្កើងរបស់យើង ? តើយើងអាចបង្ហាញភាពរីករាយនៅក្នុងព្រះរបស់យើងដោយរបៀបណា ? តើយើងនឹងបង្ហាញការសរសើរតម្កើងអំពីសេចក្ដីមេត្តារបស់ទ្រង់នៅក្នុងជីវិតរបស់យើងយ៉ាងដូចម្ដេច ? តើយើងនឹងរកឃើញរបៀបនានា ដើម្បីសាទរដល់ផ្នែករបស់យើងនៅក្នុងការបំពេញនូវសេចក្ដីសញ្ញានៃអ័ប្រាហាំនៅក្នុងជំនាន់របស់យើងដោយរបៀបណា ? ទាំងនេះប្រហែលគ្រាន់តែជាវិធីមួយចំនួនដែលយើងអាចរៀនពីរឿងដ៏អស្ចារ្យរបស់ម៉ារាស្ដីពីភាពជាសិស្ស ។ ■

**កំណត់ចំណាំ**

១. ម៉ាថាយក៏យល់ផងដែរថា ម៉ារាគឺជាការបំពេញការព្យាករបស់អេសាយអំពីនាងព្រហ្មចារីយម្នាក់ដែលនឹងបង្កើតបុត្រមួយមានឈ្មោះថាអេម៉ាញូអែល ( សូមមើល អេសាយ ៧:១៤ ) ។ ការដកស្រង់របស់លោកអំពី « នាងព្រហ្មចារីយ » គឺកើតនៅសតវត្សរ៍ទីពីរនៃគ្រិស្ដសករាជនៃការបកប្រែភាសាក្រិកអំពីអេសាយ ដែលត្រូវបានប្រើដោយពួកគ្រិស្ដសាសនិកជំនាន់ដើម និងត្រូវបានប្រើនៅក្នុងកំណែស្ដេចជេមស៍នៃ អេសាយ ៧:១៤ ។
២. នៅក្នុងព្រះគម្ពីរមរមនដែលបានបោះពុម្ពឆ្នាំ ១៨៣០ នីហ្វៃទី ១ ១១:១៨ ក៏បានពិពណ៌នាអំពីម៉ារាថាជា « មាតារបស់ព្រះ » ដែរ ។
៣. ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *Mortal Messiah* ៤ វ៉ុល ( ឆ្នាំ ១៩៨១ ) , ១:៣២៦–២៧ លេខយោង ៤ ។
៤. សូមមើល James E. Strange, “Nazareth,” *Anchor Bible Dictionary,* 4:1050; Jonathan L. Reed, *Archaeology and the Galilean Jesus: A Re-examination of the Evidence* ( ឆ្នាំ ២០០២ ) ទំព័រ ១៣១ ។
៥. សូមមើល Reed *Archaeology and the Galilean Jesus* ទំព័រ ១៣១ ។
៦. សូមមើល Ken Dark « Has Jesus’ Nazareth House Been Found ? » *Biblical Archaeology Review* វ៉ុលទី ៤១, លេខ ២ ( ខែមីនា/មេសា ឆ្នាំ ២០១៥ ) ទំព័រ ៥៤–៦៣ សូមមើលផងដែរ Ken Dark « Early Roman-Period Nazareth and the Sisters of Nazareth Convent » The Antiquities Journal វ៉ុលទី ៩២ ( ឆ្នាំ ២០១២ ) ទំព័រ ៣៧–៦៤ ។
៧. ថូម៉ាស អេស. ម៉ន់សុន « Duty Calls » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៤៤ ។
៨. ពាក្យភាសាក្រិកដែលបានបកប្រែថា « គ្របបាំង » ( episkiazō ) គឺជាពាក្យដូចគ្នាដែលបានប្រើនៅក្នុងការបកប្រែជាភាសាក្រិកនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដើម្បីពិពណ៌នាអំពីពពកបាំងដែលចុះមកលើរោងឧបោសថ នៅពេលវាគ្របបាំងទាំងស្រុង ។ វាបានពិពណ៌នាអំពីសិរីល្អរបស់ព្រះអម្ចាស់ ។
៩. ព្រះអម្ចាស់បានមានបន្ទូលដូច្នេះទៅអ័ប្រាហាំ នៅពេលលោក និងសារ៉ាបានដឹងថា ពួកគាត់នឹងមានកូនម្នាក់នៅក្នុងវ័យចំណាស់របស់ពួកគេ ( សូមមើល លោកុប្បត្តិ ១៨:១៤; រ៉ូម ៤:១៩–២១ ) ។
១០. រ័សុល អិម ណិលសុន « Stand as True Millennials » *Liahona,* ខែ តុលា ឆ្នាំ ២០១៦ ទំព័រ ៤៩ ។
១១. « បូនី អេច ខ័រដុន ៖ ប្រធានយុវនារីទូទៅ » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១២៩ ។



នៅក្នុងដៃរបស់ម្ដាយ ដោយ ស៊ីមុន ឌើវី

# យ៉ូហាន
## សិស្សដែលព្រះយេស៊ូវស្រឡាញ់

ការសរសេរនៃព្រះគម្ពីរសញ្ញាថ្មីដែលមានទាក់ទងជាមួយនឹងយ៉ូហានសំណព្វបង្ហាញថា លោកគឺជាគ្រូបង្រៀន និងជាគំរូសម្រាប់ភាពជាសិស្សផ្ទាល់ខ្លួនយើងផង ។

**ដោយ អ៊ីរិក ឌី ហាន់ស្មេន**
សាស្ត្រាចារ្យនៃព្រះគម្ពីរបុរាណ នៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់

បន្ទាប់ពីពេត្រុស នោះយ៉ូហានគឺប្រហែលមានគេស្គាល់ច្បាស់ថា ជាសាវកដំបូងរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោក និងយ៉ាកុបជាបងប្រុសរបស់លោក បាននៅជាមួយពេត្រុសនៅក្នុងគ្រាសំខាន់ៗបំផុតមួយចំនួននៃការងារបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងជីវិតរមែងស្លាប់នេះ ហើយលោកត្រូវបានគេលើកឡើងនៅក្នុងគម្ពីរប្រាំផ្សេងៗគ្នានៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។[១] ភាពស្និទ្ធស្នាលផ្ទាល់របស់លោកចំពោះព្រះអម្ចាស់ត្រូវបានប្រាប់តាមរយៈ យ៉ូហាន ១៣:២៣ ៖ « មានសិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់ គាត់អង្គុយនៅតុផ្អែកលើព្រះឱរាទ្រង់ » ។ ពេញក្នុងប្រវត្តិសាស្ត្រ គំនូរពួកគ្រិស្តសាសនិកបានបង្ហាញអំពីរូបភាពនេះ ជារូបភាពដែលយ៉ូហានវ័យក្មេងសម្រាកលើព្រះហស្តរបស់ព្រះអង្គសង្គ្រោះ ។ នេះគឺជាងារពិសេសដើមរបស់លោកយ៉ូហានសំណព្វ ប៉ុន្តែសាក្សី និងបេសកកម្មរបស់លោកបើកសម្តែងទិដ្ឋភាពទូទៅអំពីភាពជាសិស្ស ដែលយើងទាំងអស់គ្នាអាចចែកចាយបាន ។

### យ៉ូហានកូនសេបេដេ

ឈ្មោះជាភាសាហេព្រើររបស់យ៉ូហានគឺ *Yohanan* មានន័យថា « ព្រះមានសេចក្តីមេត្តាករុណា » ។ ព័ត៌មានលម្អិតបំផុតដែលយើងដឹងអំពីលោកមាននៅក្នុងដំណឹងល្អបីដំបូង ដែលប្រាប់អំពីរឿងនៃការងារបម្រើក្នុងជីវិតរមែងស្លាប់របស់ព្រះអង្គសង្គ្រោះយ៉ាងច្រើនមកពីទស្សនវិស័យដូចគ្នា ។ គម្ពីរទាំងនោះយល់ស្របថា យ៉ូហានគឺជាកូនរបស់អ្នកនេសាទត្រីដ៏មានស្តុកស្តម្ភម្នាក់នៅស្រុកកាលីឡេឈ្មោះសេបេដេ ដែលមានសំពៅផ្ទាល់ខ្លួនគាត់ ហើយអាចជួលកម្មករធ្វើការប្រចាំថ្ងៃ ដើម្បីជួយគាត់ និងកូនប្រុសរបស់គាត់នៅក្នុងការងារ ។ យ៉ូហាន និងយ៉ាកុបបងប្រុសរបស់លោក ក៏មានដៃគូជាមួយបងប្អូនប្រុសពេត្រុស និងអនទ្រេផងដែរ ហើយពួកលោកទាំងបួននាក់បានចាកចោលពីការនេសាទត្រីរបស់ពួកលោកនៅពេលព្រះយេស៊ូវហៅពួកលោកឲ្យដើរតាមទ្រង់នៅក្នុងភាពជាសិស្សពេញម៉ោង ។[២]

ទោះបីដំណឹងល្អពុំបានលើកឡើងជាថ្មីទៀតអំពីសេបេដេក្តី ក៏ម្តាយរបស់យ៉ាកុប និង យ៉ូហាន បានក្លាយជាអ្នកដើរតាមព្រះយេស៊ូវ ដោយចូលរួមជាមួយព្រះយេស៊ូវជំនួសឲ្យកូនៗរបស់គាត់ ហើយមានវត្តមាននៅឯការឆ្កាង ។[៣] ជាទូទៅ

រូបភាពលម្អិតដកស្រង់ពី *អាហារយប់ថ្ងៃចុងក្រោយ* ដោយ ខាល ប្លូច





*ព្រះគ្រីស្ទហៅពួកសាវកយ៉ាកុប និង យ៉ូហាន* អែតជីង អាច់ចេច ( ១៨១៧–១៨៥៦ ) / SHEFFIELD GALLERIES AND MUSEUMS TRUST, UK /
© MUSEUMS SHEFFIELD / THE BRIDGEMAN ART LIBRARY INTERNATIONAL

*ឆ្លើយតបទៅនឹងការហៅរបស់ព្រះយេស៊ូវ យ៉ូហាន និង យ៉ាកុប « ក៏លះចោលសេបេដេជាឪពុកនៅក្នុងទូកជាមួយនឹងពួកជើងឈ្នួល រួចដើរតាមទ្រង់ទៅ » ( ម៉ាកុស ១:២០ ) ។*

ត្រូវបានសម្គាល់ដោយឈ្មោះសាឡូមេ នោះម្ដាយរបស់យ៉ាកុប និង យ៉ូហាន ក៏អាចជាបងស្រីរបស់ម៉ារាដែលជាមាតារបស់ព្រះយេស៊ូវ ដែលធ្វើឲ្យពួកលោកក្លាយជាបងប្អូនជីដូនមួយដំបូងរបស់ព្រះយេស៊ូវ និងជាសាច់ញាតិនឹង យ៉ូហាន បាទីស្ទដែរ ។[4]

មិនយូរប៉ុន្មានបន្ទាប់ពីការហៅរបស់លោក យ៉ូហានបានឃើញអព្ភូតហេតុ និងការបង្រៀនដំបូងៗជាច្រើនរបស់ព្រះអម្ចាស់ ។[5] ដោយឃើញអព្ភូតហេតុទាំងនេះ និងស្ដាប់ការថ្លែងនានា ដូចជាទេសនាកថានៅលើភ្នំ នោះគ្មានការសង្ស័យឡើយ ដែលយ៉ូហានត្រូវបានរៀបចំសម្រាប់គ្រានោះ នៅពេលព្រះយេស៊ូវបានហៅលោកឲ្យធ្វើជាសាវកម្នាក់នៃសាវកដប់ពីរនាក់ ។[6] ស្ដីពីសាក្សីពិសេសទាំងនេះ ពេត្រុស, យ៉ាកុប និង យ៉ូហាន បង្កើតបានជាសិស្សដ៏ស្និទ្ធស្នាលបំផុតដែលមានវត្តមាននៅក្នុងគ្រាសំខាន់ៗនៃការងារបម្រើរបស់ព្រះយេស៊ូវគ្រីស្ទនៅលើផែនដី ៖

- នៅពេលប្រោសកូនស្រីរបស់យ៉ៃរុសឲ្យរស់ឡើងវិញ ដោយឃើញព្រះចេស្ដារបស់ព្រះអម្ចាស់ឈ្នះលើសេចក្ដីស្លាប់មុនគេ ។[7]
- នៅលើភ្នំប្រែរូប ជាកន្លែងដែលពួកលោកបានឃើញព្រះយេស៊ូវបើកសម្ដែងនូវសិរីល្អរបស់ទ្រង់ និងស្ដាប់ឮសំឡេងរបស់ព្រះវរបិតាថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ទ្រង់ ដែលជាទីគាប់ព្រះទ័យដល់ទ្រង់ណាស់ ។[8]
- នៅលើភ្នំដើមអូលីវសម្រាប់ការព្យាករចុងក្រោយរបស់ទ្រង់អំពីជំនាន់ចុងក្រោយនេះ ។[9]
- នៅក្នុងសួនច្បារគែតសេម៉ានី ជាកន្លែងដែលពួកលោកបាននៅក្បែរនោះ នៅពេលព្រះអង្គសង្គ្រោះបានចាប់ផ្ដើមកិច្ចការនៃដង្វាយធួនដ៏អស្ចារ្យរបស់ទ្រង់ ។[10]

ដូចព្រះយេស៊ូវគ្រីស្ទបានប្រទានឈ្មោះបន្ថែមឲ្យស៊ីម៉ូន ឬពេត្រុសនូវឈ្មោះ *កេផាស* ដែលមានន័យថា « ថ្ម » នោះទ្រង់បានប្រទានឈ្មោះឲ្យ យ៉ាកុប និង យ៉ូហាន នូវឈ្មោះ *បោនអ៊ើកេ* ឬ « កូនផ្គរលាន់ » ។[11] ដោយសារពួកលោកបានសួរព្រះយេស៊ូវថា តើពួកលោកគួរហៅភ្លើងឲ្យធ្លាក់លើភូមិមួយរបស់សាសន៍សាម៉ារីដែលបានបដិសេធទ្រង់ ( សូមមើល លូកា ៩:៥១–៥៦ ) ឈ្មោះហៅក្រៅនេះ អាចផ្ដល់ជាយោបល់ថាពួកលោកងាយនឹងខឹង ឬយ៉ាងហោចណាស់មានឆន្ទៈរឹងប៉ឹង ។ ប៉ុន្តែទំនងដូចជាឈ្មោះនេះត្រូវបានគិតទុកជាមុនអំពីសាក្សីដ៏ពោរពេញដោយអំណាច ដែលពួកលោកអាចប្រែក្លាយ នោះឈ្មោះរបស់ពេត្រុសក៏ប្រហែលជាបង្ហាញអំពីភាពមិនលះបង់ច្រើនដំបូងរបស់លោកប៉ុន្តែជាភាព

រឹងប៉ឹង និងរឹងមាំរបស់លោក បន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ ។[១២]

នៅក្នុងការបង្ហាញអំពីយ៉ូហាននៅក្នុងគម្ពីរកិច្ចការ នោះគេពិពណ៌នាពីលោកថា ជាដៃគូដ៏រឹងប៉ឹង និងខ្ជាប់ខ្ជួនរបស់ពេត្រុស ។ យ៉ូហានបាននៅជាមួយពេត្រុស នៅពេលលោកបានព្យាបាលបុរសខ្វិនម្នាក់នៅក្នុងព្រះវិហារបរិសុទ្ធ ហើយពួកលោកបានប្រកាសដោយក្លាហានជាមួយគ្នា នៅចំពោះមុខថ្នាក់ដឹកនាំសាសន៍យូដានៅទីក្រុងយេរូសាឡិម ។ ពួកសាវកទាំងពីរនាក់បានធ្វើដំណើរជាមួយគ្នាទៅស្រុកសាម៉ារី ដើម្បីប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធលើពួកសាសន៍សាម៉ារី ដែលហ្វីលីពបានបង្រៀន ហើយជ្រមុជទឹក ។[១៣]

ប៉ុន្តែ គឺនៅក្នុងការសរសេរដែលទាក់ទងជាមួយយ៉ូហាននោះហើយ ដែលលោកត្រូវបានមើលឃើញច្បាស់បំផុតថាជាសាក្សីដ៏មានឥទ្ធិពលអំពីភាពជាព្រះនៃថៅហ្វាយ និងមិត្តភក្តិរបស់លោកគឺព្រះយេស៊ូវគ្រីស្ទ ។ គម្ពីរទាំងនេះក្នុងព្រះគម្ពីរសញ្ញាថ្មីបង្ហាញយ៉ូហានថា លោកគឺជាគ្រូបង្រៀន និងជាគំរូសម្រាប់ភាពជាសិស្សផ្ទាល់ខ្លួនយើងផង ។

## សិស្សសំណព្វ

គួរឲ្យចាប់អារម្មណ៍ណាស់ យ៉ូហានពុំធ្លាប់ត្រូវបានគេដាក់ឈ្មោះនៅក្នុងដំណឹងល្អ ដែលត្រូវបានសន្មត់ថាជាលោកតាមទម្លាប់ឡើយ ។ ដំណឹងល្អរបស់យ៉ូហានលើកឡើងពីកូនប្រុសពីរនាក់របស់សេបេដេតែម្តងប៉ុណ្ណោះ នៅក្នុងជំពូកចុងក្រោយបំផុត ជាកន្លែងដែលពួកលោកទាំងពីរក្នុងចំណោមពួកសិស្សទាំងប្រាំពីរបានជួបព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ នៅជិតសមុទ្រកាលីឡេ ។ ប៉ុន្តែ សូម្បីតែនៅត្រង់នោះគេក៏ពុំបានលើកឡើងពីឈ្មោះរបស់ពួកលោកផងដែរ ។ ផ្ទុយទៅវិញ ទម្លាប់ដែលគាំទ្រដោយឯកសារយោងនៅក្នុងព្រះគម្ពីរនៃការស្តារឡើងវិញ[១៤] បានកំណត់អត្តសញ្ញាណថា យ៉ូហានត្រូវបានហៅដោយអនាមិកថាជា « សិស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់ » ដែលមានវត្តមាននៅពេលអាហារចុងក្រោយ ពេលឆ្កាង ពេលផ្នូរនៅទទេ និងនៅពេលព្រះយេស៊ូវបង្ហាញព្រះកាយចុងក្រោយនៅសមុទ្រកាលីឡេ ។[១៥]

លោកក៏ជា « សិស្សម្នាក់ទៀត » ដែលនៅជាមួយអនទ្រេ ដែលជាអ្នកដើរតាម យ៉ូហាន បាទីស្ទ ហើយស្តាប់ឮលោកបានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវថា ជាកូនចៀមនៃព្រះ ( សូមមើល យ៉ូហាន ១:៣៥–៤០ ) ហើយលោកទំនងជាសិស្សដែលបានអមដំណើរពេត្រុស បន្ទាប់ពីគេចាប់ព្រះកាយព្រះយេស៊ូវ ហើយបានជួយពេត្រុសឲ្យចូលទៅក្នុងសាលាសម្តេចសង្ឃ ( សូមមើល យ៉ូហាន ១៨:១៥–១៦ ) ។

នៅក្នុងដំណឹងល្អរបស់យ៉ូហាន សិស្សសំណព្វត្រូវបានពិពណ៌នាថា ជាមិត្តភក្តិជិតស្និទ្ធផ្ទាល់នឹងព្រះអម្ចាស់ ។ ជាមួយនឹងម៉ាថា, ឡាសារ និង ម៉ារា នោះយ៉ូហានត្រូវបានពិពណ៌នាយ៉ាងច្បាស់នៅក្នុងដំណឹងល្អនេះថា ជាមនុស្សម្នាក់ដែលព្រះយេស៊ូវស្រឡាញ់ ( សូមមើល យ៉ូហាន ១១:៣, ៥ ) ។ តួនាទីរបស់លោកនៅឯពេលទទួលទានអាហារយប់ចុងក្រោយ ពុំគ្រាន់តែឆ្លុះបញ្ចាំងពីកិត្តិយសប៉ុណ្ណោះទេ ថែមទាំងឆ្លុះបញ្ចាំងពីភាពស្និទ្ធស្នាលផងដែរ ។

ក្រៅពីមិត្តភាពរបស់លោកជាមួយព្រះអង្គសង្គ្រោះ វគ្គបទគម្ពីរផ្សេងទៀតបង្ហាញថា លោកគឺជាសាក្សីដ៏មានឥទ្ធិពលម្នាក់នៃព្រឹត្តិការណ៍សំខាន់ៗបំផុតនៃបេសកកម្មរបស់ព្រះយេស៊ូវ ៖ លោកបានឈរនៅឯគល់នៃដងឈើឆ្កាង ដើម្បីមើលការសុគតរបស់ព្រះអម្ចាស់ទុកជាការបូជាធួនអំពើបាប បានរត់ទៅផ្នូរបន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញ ដើម្បីបញ្ជាក់ថា ផ្នូរនោះនៅទទេ ហើយបានឃើញព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ។

ដំណឹងល្អរបស់យ៉ូហានលើកឡើងចំនួនពីរដង ដែលវាផ្អែកទៅលើទីបន្ទាល់នៃសិស្សសំណព្វ ហើយគូសបញ្ជាក់ថា ទីបន្ទាល់របស់លោកគឺពិត[១៦] ជាអ្វីមួយដែលបង្ហាញដោយការដាក់ចំណងជើងជាថ្មីរបស់យ៉ូសែប ស្ម៊ីធ អំពីដំណឹងល្អថា « ទីបន្ទាល់របស់យ៉ូហាន » ។[១៧]

ដោយសារតែពួកអ្នកប្រាជ្ញនៅតែជជែកវែកញែកអំពីអត្តសញ្ញាណនៃសិស្សសំណព្វ ប្រសិនបើលោកគឺជាសាវកយ៉ូហាន នោះលោកគឺជាប្រភពនៃឯកសារនៅក្នុងដំណឹងល្អ ប្រសិនបើលោកពុំមែនជាអ្នកនិពន្ធដើមរបស់គម្ពីរនោះទេ ។[១៨] ហេតុអ្វីលោកនៅតែបន្តអត់មានឈ្មោះ ពុំធ្លាប់ត្រូវបានគេកំណត់អត្តសញ្ញាណដោយផ្ទាល់ថាជាសាវកយ៉ូហាន ? ចម្លើយអាចមានដូចជា ដោយសារលោកមានចេតនាឲ្យបទពិសោធន៍ផ្ទាល់របស់លោកក្លាយជាបទពិសោធន៍សម្រាប់អ្នកជឿ និងពួកសិស្សនៅគ្រប់ជំនាន់ ។ តាមរយៈការនៅជាអនាមិក នោះលោកអាចធ្វើឲ្យយើងស្រមៃថា ខ្លួនយើងនៅក្នុងបទពិសោធន៍របស់លោក រៀនអំពីរបៀបស្រឡាញ់ និងត្រូវបានព្រះអម្ចាស់ស្រឡាញ់ ហើយបន្ទាប់មកទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើង ដែលក្រោយមកទៀតយើងត្រូវបានហៅឲ្យចែកចាយជាមួយមនុស្សដទៃ ។

*« គឺសិស្សនោះឯង ដែលធ្វើបន្ទាល់ពីសេចក្តីទាំងនេះ ព្រមទាំងចែងរឿងទាំងនេះទុកផង យើងរាល់គ្នាដឹងថា សេចក្តីបន្ទាល់របស់គាត់ នោះពិតហើយ » ( យ៉ូហាន ២១:២៤ ) ។*

## សំបុត្រ ៖ ទី១ ទី២ និង ទី៣ របស់យ៉ូហាន

ដូចដំណឹងល្អរបស់យ៉ូហានដែរ សំបុត្រទាំងបីដែលសន្មត់ថាជារបស់យ៉ូហានក៏គ្មានសំបុត្រណាមួយដែលដាក់ឈ្មោះលោកផ្ទាល់ដែរ ។ ទោះជាយ៉ាងណាក៏ដោយ យ៉ូហានទី ១ ដែលមាននូវការសរសេរខាងគោលលទ្ធិកាន់តែច្រើនជាមួយនឹងដំណឹងល្អនៅក្នុងរបៀប និងប្រធានបទនៃសំបុត្រនោះ ដែលដាក់បញ្ចូលនូវសារៈសំខាន់អំពីសេចក្តីស្រឡាញ់ និងការគោរពប្រតិបត្តិ មាននូវប្រធានបទនានាដែលព្រះអង្គសង្គ្រោះបានបង្រៀននៅក្នុងដំណើររឿងរបស់យ៉ូហានអំពីអាហារយប់ចុងក្រោយ ។

ដោយបានសរសេរបន្ទាប់ពីដំណឹងល្អ នោះយ៉ូហានទី ១ ចាប់ផ្តើមដោយការប្រកាសទីបន្ទាល់អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់អ្នកនិពន្ធ « ឯសេចក្តីដែលមានតាំងពីដើមមក ដែលយើងខ្ញុំ *បានឮ* ហើយភ្នែក *បានឃើញ* ក៏បានមើល *ហើយដៃបានប៉ះពាល់* ខាងឯព្រះបន្ទូលនៃជីវិត » ( យ៉ូហានទី ១ ១:១ ការគូសបញ្ជាក់បានបន្ថែម ) ។ ក្រៅពីថ្លែងជាថ្មីអំពីបន្ទាត់ចាប់ផ្តើមនៃដំណឹងល្អរបស់យ៉ូហាន នោះអ្នកនិពន្ធបាន

សង្កត់ធ្ងន់លើទីបន្ទាល់ដ៏មានឥទ្ធិពល ផ្ទាល់ខ្លួន ខាងរូបកាយអំពីព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលព្រះបន្ទូលនៃព្រះបានបង្កើតមក ។

ពួកគ្រិស្តសាសនិកជំនាន់ដើម ដែលជាអ្នកអានព្រះគម្ពីរនេះដំបូងគេ ហាក់ដូចជារងការឈឺចាប់ដោយសារការបែកបាក់ផ្ទៃក្នុងជាមួយក្រុមមួយដែលជឿលើជំនឿខុសឆ្គងអំពីព្រះយេស៊ូវបានចាកចេញពីសាសនាចក្រ ។[១៩] នៅក្នុងយ៉ូហានទី ១ អ្នកនិពន្ធពុំគ្រាន់តែជាសាក្សីម្នាក់ប៉ុណ្ណោះទេ លោកថែមទាំងជាអ្នកមានសិទ្ធិអំណាចដែលអំពាវនាវឲ្យកែតម្រូវគោលលទ្ធិខុសឆ្គង ហើយប្រឈមមុខនឹងការគំរាមកំហែងនានាចំពោះសេចក្ដីជំនឿ មកពីពួកប្រឆាំងនឹងព្រះគ្រីស្ទ ព្រមទាំងវិញ្ញាណខុសឆ្គងដែរ ( សូមមើល យ៉ូហានទី ១ ២:១៨–២៧; ៤:១–៦ ) ។ បេសកកម្មរបស់លោកក៏ដើម្បីលើកទឹកចិត្តដល់អស់អ្នកដែលបន្តស្មោះត្រង់តាមរយៈការចែកចាយសេចក្ដីពិតដ៏មានអត្ថន័យអំពីព្រះ និងព្រះគ្រីស្ទ ព្រមទាំងសារៈសំខាន់នៃសេចក្ដីជំនឿ និងសេចក្ដីសុចរិតដែលបន្តមាន ។

នៅក្នុងយ៉ូហានទី ១ និង យ៉ូហានទី ៣ លោកបានបង្ហាញអត្តសញ្ញាណរបស់លោកយ៉ាងសាមញ្ញថាជា « អ្នកចាស់ទុំ » ហើយបន្តសង្កត់ធ្ងន់លើសារៈសំខាន់នៃសេចក្ដីស្រឡាញ់ និងការគោរពប្រតិបត្តិ និងគ្រោះថ្នាក់នៃការបង្រៀនខុសឆ្គង ព្រមទាំងអស់អ្នកដែលបដិសេធសិទ្ធិអំណាចត្រឹមត្រូវរបស់សាសនាចក្រ ។[២០]

គម្ពីរទាំងបីក្បាលនេះបង្រៀនយើងអំពីសារៈសំខាន់នៃការបូជាដែលបន្តមានចំពោះព្រះយេស៊ូវគ្រីស្ទដែលបានបើកសម្ដែង ។

**អ្នកទទួលវិវរណៈ**

ក្នុងចំណោមគម្ពីរប្រាំក្បាលដែលកំណត់ថាជារបស់លោក មានតែគម្ពីរវិវរណៈទេដែលពិតជាប្រើឈ្មោះរបស់យ៉ូហាន ដោយបង្ហាញអំពីអត្តសញ្ញាណរបស់អ្នកនិពន្ធបីដងដោយដាក់ឈ្មោះនោះនៅក្នុងខគម្ពីរដំបូងរបស់គម្ពីរនោះ ( សូមមើល វិវរណៈ ១:១, ៤, ៩ ) ។ លើសពីការបង្ហាញអត្តសញ្ញាណខ្លួនលោកថាជាអ្នកបម្រើរបស់ព្រះ នោះអ្នកនិពន្ធផ្ដល់នូវការបង្ហាញមួយផ្សេងទៀតអំពីតួនាទី ឬការហៅរបស់លោក ប៉ុន្តែភាគច្រើននៃពួកអ្នកមានសិទ្ធិអំណាចគ្រិស្តសាសនិកជំនាន់ដើមបានជឿថា លោកគឺជាយ៉ូហានកូនសេបេដេ ។

ព្រះគម្ពីរមរមន និងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញាបញ្ជាក់ថា សាវកយ៉ូហានត្រូវបានប្រទានឲ្យនូវបេសកកម្មពិសេសមួយ ដើម្បីទទួល និងសរសេរការនិមិត្តដែលលោកបានទទួល ។[២១] គម្ពីរវិវរណៈដែលពោរពេញដោយភាពស្មុគស្មាញ នឹងមាននិមិត្តរូបដ៏ច្រើនលើសលប់នោះ មានបំណងដើម្បីលួងលោម និងបញ្ជាក់ដល់ពួកគ្រិស្តសាសនិកដែលរងការឈឺចាប់ដោយការបៀតបៀន ឬការសោកល្បងនៅគ្រប់ជំនាន់ ព្រមទាំងក្នុងពេលដំណាលគ្នានោះបើកបង្ហាញអំពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទពេញមួយប្រវត្តិសាស្ត្រផងដែរ ។

ទោះបីជាកាលបរិច្ឆេទពីរផ្សេងគ្នាត្រូវបានស្នើសុំឡើងអំពីពេលវេលាដែលយ៉ូហានបានសរសេរគម្ពីរវិវរណៈក្តី—កាលបរិច្ឆេទដំបូងនៅក្នុងទសវត្សរ៍ឆ្នាំ ៦០ នៃគ.ស. អំឡុងពេលគ្រងរាជនៃព្រះចៅអធិរាជ្យណេរូ និងកាលបរិច្ឆេទចុងក្រោយនៅទសវត្សរ៍ឆ្នាំ ៩០ នៃ គ.ស. អំឡុងពេលគ្រងរាជនៃព្រះចៅអធិរាជដូមីធៀន—កាលបរិច្ឆេទទាំងពីរនេះបានមាន បន្ទាប់ពីការស្លាប់របស់ពេត្រុសដោយសារតែបុព្វហេតុសាសនា ដោយទុកឲ្យយ៉ូហានជាសាវកច្បងបន្តនៅរស់រានមានជីវិត ។

ប៉ុន្តែការហៅរបស់លោកពុំគ្រាន់តែដើម្បីទទួល និងកត់ត្រាការនិមិត្តដែលមាននៅក្នុងគម្ពីរនោះប៉ុណ្ណោះទេ ។ នៅក្នុងការនិមិត្តមួយក្នុងការនិមិត្តនានា ទេវតាបានប្រាប់យ៉ូហានអំពីអ្នកទទួលវិវរណៈឲ្យយកគម្ពីរ ឬមុរក្រដាសតូចមួយ ហើយបរិភោគវា ។ ដំបូងវាផ្អែមនៅក្នុងមាត់របស់លោក វាធ្វើឲ្យពោះរបស់លោកល្វីង ដែលយ៉ូសែប ស្ម៊ីធ បានបកប្រែថា តំណាងឲ្យបេសកកម្មរបស់លោក ដើម្បីជួយប្រមូលពួកសាសន៍អ៊ីស្រាអែល ជាផ្នែកមួយនៃការស្ដារឡើងវិញនៃអ្វីៗគ្រប់យ៉ាងទាំងអស់ ( សូមមើល វិវរណៈ ១០:៩–១១; គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៧:១៤ ) ។ បេសកកម្មនេះអាចធ្វើទៅបាន ដោយសារការងារបម្រើបន្តរបស់យ៉ូហានបន្ទាប់ពីលោកបានប្រែរូប ។ ខណៈដែលពួកអ្នកអធិប្បាយទាំងសម័យបុរាណ និងទំនើបត្រូវបានបែងចែកទាក់ទងនឹងអត្ថន័យនៃសេចក្ដីថ្លែងរបស់ព្រះយេស៊ូវទៅពេត្រុស អំពីជោគវាសនារបស់យ៉ូហាននៅចុងបញ្ចប់នៃដំណឹងល្អ ( សូមមើល យ៉ូហាន ២១:២០–២៣ ) នោះយ៉ូសែប ស្ម៊ីធ បានទទួលវិវរណៈមួយបញ្ជាក់ថា បេសកកម្មរបស់យ៉ូហាននឹងបន្ត ក្នុងស្ថានភាពជាបុគ្គលដែលប្រែរូប រហូតដល់ព្រះអង្គសង្គ្រោះយាងត្រឡប់មកវិញ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៧:១–៦ ) ។ ម្យ៉ាងវិញទៀត លោកពុំគ្រាន់តែបានព្យាករអំពីនាទីចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែបេសកកម្មរបស់លោករួមមានទាំងការជួយបំពេញការព្យាករទាំងនេះ ព្រមទាំងមើលឃើញការបំពេញនៃកិច្ចការទាំងនោះដែលត្រូវបានបើកសម្ដែងដល់លោក ។

> *« កាលណាយើងស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់ នោះយើងដឹងថា យើងស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ »*
> *( យ៉ូហានទី ១ ៥:២ ) ។*

ទោះបីបេសកកម្មផ្ទាល់របស់យើងមិនធំដុំក្តី គំរូរបស់យ៉ូហានបង្រៀនថា សេចក្ដីស្រឡាញ់របស់យើងចំពោះព្រះយេស៊ូវគ្រីស្ទដឹកនាំយើងឲ្យទទួលយកការហៅផ្ទាល់របស់យើង និងឧបសគ្គនានាក្នុងជីវិតយើង មិនថា មានរឿងល្អ ឬអាក្រក់បែបណានោះឡើយ ។

**ការធ្វើឲ្យខ្លួនយើងក្លាយជាសិស្សសំណព្វ**

យ៉ូហានគឺជាសមាជិកដឹកនាំម្នាក់នៅក្នុងពួកដប់ពីរនាក់ដើមរបស់ព្រះយេស៊ូវ ជាបុគ្គលម្នាក់ដែលមានទំនាក់ទំនងស្និទ្ធស្នាលយ៉ាងផ្ទាល់ជាមួយព្រះអង្គសង្គ្រោះ ហើយបានបម្រើតួនាទីសំខាន់ៗក្នុងនាមជាសាក្សីរបស់ទ្រង់ ជាថ្នាក់ដឹកនាំសាសនាចក្រ និងជាអ្នកទទួលវិវរណៈ ។ ប៉ុន្តែរបៀបដែលលោកបានជ្រើសរើសដើម្បីបង្ហាញខ្លួនលោកថាជា សិស្សសំណព្វនៅក្នុងដំណឹងល្អដែលមានឈ្មោះរបស់លោក ធ្វើឲ្យលោក

ក្លាយជាគំរូមួយសម្រាប់ពួកយើងទាំងអស់គ្នានៅក្នុងភាពជាសិស្សផ្ទាល់ខ្លួនរបស់យើង ។ យើងរៀនពីលោកថា ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ នោះយើងទាំងអស់គ្នាអាចសម្រាកនៅក្នុងព្រះពាហុនៃសេចក្តីស្រឡាញ់របស់ទ្រង់ ជាសេចក្តីស្រឡាញ់ដែលយើងទទួលស្គាល់យ៉ាងពេញលេញ តាមរយៈពិធីបរិសុទ្ធនានាដូចជាទ្រង់បានបង្កើតឡើងនៅឯអាហារយប់ចុងក្រោយ ។ យើងក៏អាចឈរនៅគល់នៃដងឈើឆ្កាងជានិមិត្តរូបផងដែរ ដោយថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវបានសុគតសម្រាប់ពួកយើង ហើយរត់ដោយក្តីសង្ឃឹម ដើម្បីរៀនឲ្យដឹងដោយខ្លួនយើងថា ព្រះអម្ចាស់មានព្រះជន្មរស់ ។ ដូចជាយ៉ូហានដែរ ក្នុងនាមជាសិស្សសំណព្វ នោះការហៅរបស់យើងគឺដើម្បីចែកចាយទីបន្ទាល់នោះជាមួយមនុស្សដទៃ ដោយការថ្លែងទីបន្ទាល់អំពីសេចក្តីពិត និងការបំពេញការហៅណាក៏ដោយដែលយើងត្រូវបានហៅ រហូតដល់ពេលដែលព្រះអម្ចាស់យាងមកម្តងទៀត ។ ■



*សាក្សីដ៏មានឥទ្ធិពលម្នាក់នៃព្រឹត្តិការណ៍សំខាន់ៗបំផុតនៃបេសកកម្មរបស់ព្រះយេស៊ូវ នោះយ៉ូហានបានឈរនៅឯគល់នៃដងឈើឆ្កាង ដើម្បីមើលការសុគតរបស់ព្រះអម្ចាស់ បានរត់ទៅផ្នូរបន្ទាប់ពីការមានព្រះជន្មរស់ឡើងវិញ ដើម្បីបញ្ជាក់ថា ផ្នូរនោះនៅទទេ ហើយបានឃើញព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញ ។*

*យ៉ូហាន និង ពេត្រុស នៅឯផ្នូរ ដោយ វ៉លធើរ រ៉ាន*

**កំណត់ចំណាំ**

១. គួរឲ្យចាប់អារម្មណ៍ណាស់ មានតែគម្ពីរវិវរណៈមួយគត់ដែលថ្លែងដោយផ្ទាល់ថា អ្នកសរសេរគម្ពីរនោះគឺជាយ៉ូហាន ( សូមមើល វិវរណៈ ១:១, ៤ ) ។ គ្មានដំណឹងល្អណាផ្សេងទៀត រួមទាំងដំណឹងល្អរបស់យ៉ូហាន បានបង្ហាញអត្តសញ្ញាណរបស់អ្នកនិពន្ធឡើយ ។ ប៉ុន្តែទម្លាប់នៃពួកគ្រិស្តសាសនិកជំនាន់ដើម បានកំណត់អត្តសញ្ញាណរូបភាពនៃសិស្សសំណព្វនៅក្នុងដំណឹងល្អរបស់យ៉ូហានជាមួយនឹងសាវកនៃឈ្មោះនោះ ។ សម្រាប់ការពិភាក្សាអំពីភស្តុតាងនេះ ការពិភាក្សានៃពួកអ្នកប្រាជ្ញ និងការយល់ដឹងអំពីការស្តារឡើងវិញទាក់ទងនឹងការបង្ហាញអត្តសញ្ញាណនេះ សូមមើល កំណត់ចំណាំទី ១៧ ។ ស្រដៀងគ្នានេះ គម្ពីរយ៉ូហានទី ១ ពុំបង្ហាញអត្តសញ្ញាណអ្នកនិពន្ធគម្ពីរនេះឡើយ ប៉ុន្តែរបៀបសរសេរ និងប្រធានបទក្នុងគម្ពីរនោះទាក់ទងគ្នាយ៉ាងខ្លាំងជាមួយនឹងដំណឹងល្អរបស់យ៉ូហាន ។ គម្ពីរយ៉ូហានទី ២ និង យ៉ូហានទី ៣ ទាក់ទងនឹង « អ្នកចាស់ទុំ » ប៉ុន្តែទម្លាប់ពួកគ្រិស្តសាសនិកជំនាន់ដើមបានភ្ជាប់គម្ពីរទាំងនេះជាមួយនឹងអ្នកនិពន្ធនៃយ៉ូហាន និងយ៉ូហានទី ១ ។

២. សូមមើល ម៉ាកុស ១:១៩–២០ សូមមើលផងដែរ ម៉ាថាយ ៤:២១–២២; លូកា ៥:១០–១១ ។ ពួកអ្នកប្រាជ្ញភាគច្រើនយល់ស្របថា ម៉ាកុសបានសរសេរមុនអំឡុងពេលពាក់កណ្តាលទសវត្សរ៍ឆ្នាំ ៦០ នៃ គ.ស ជាមួយម៉ាថាយ និង លូកា បានសរសេរអំឡុងទសវត្សរ៍ឆ្នាំ ៧០ ឬដើមទសវត្សរ៍ឆ្នាំ ៨០ នៃ គ.ស ។ ជាលទ្ធផល ការអានសេចក្តីយោងនានាមកពីម៉ាកុស ដំបូងធ្វើឲ្យយើងឃើញអំពីរបៀបដែលម៉ាថាយ និង លូកា បានបន្ថែម ឬកែសម្រួលដំណើររឿងពីមុនៗ ។

៣. ខណៈដែល ម៉ាកុស ១០:៣៥–៣៧ កត់ត្រាថា យ៉ាកុប និង យ៉ូហាន ត្រូវបានសុំឲ្យអង្គុយនៅខាងស្តាំ និងខាងឆ្វេងរបស់ព្រះយេស៊ូវនៅក្នុងនគររបស់ទ្រង់ នោះ ម៉ាថាយ ២០:២០–២១ បន្ថែមថា តាមពិតទៅសំណើនេះគឺកើតមកពីម្តាយរបស់ពួកគេទេ ។ ដោយសារវត្តមានរបស់ម្តាយគាត់នៅឯការឆ្កាង និងក្រោយមកទៀតនៅឯផ្នូរទទេ សូមមើល ម៉ាកុស ១៥:៤០; ១៦:១–៨ សូមមើលផងដែរ ម៉ាថាយ ២៧:៥៥–៥៦; លូកា ២៣:៤៩, ៥៥; ២៤:១–១០ និង យ៉ូហាន ១៩:២៥ ។

៤. សម្រាប់ការពិភាក្សាបន្ថែមទៀតអំពីទំនាក់ទំនងទាំងនេះដែលអាចមានរបស់សាឡូមេ ព្រមទាំងប្រវត្តិជាច្រើនទៀតស្តីពីគ្រួសារនេះ និងអាជីវកម្មនេសាទត្រីរបស់សេបេដេ សូមមើល R Alan Culpeppe,r *John, the Son of Zebedee: The Life of a Legend* ( ឆ្នាំ ២០០០ ) ទំព័រ ៧–២៣ ។

៥. សូមមើល ម៉ាកុស ១:២១–៣១, ៤០–៤៥; ២:១–១២; ៣:១–៦ សូមមើលផងដែរ ម៉ាថាយ ៨:១–៤; ៩:១–៨; ១២:៩–១៤; លូកា ៤:៣៣–៣៩; ៥:១២–១៥, ១៧–២៦; ៦:៦–១១ ។

៦. សម្រាប់ទេសនកថានៅលើភ្នំ សូមមើល ម៉ាថាយ ៥–៧ ។ សម្រាប់ការហៅរបស់យ៉ូហាន និងពួកសាវកដំបូងដទៃទៀត សូមមើល ម៉ាកុស ៣:១៣–១៩ សូមមើលផងដែរ ម៉ាថាយ ១០:២–៤; លូកា ៦:១៣–១៦ ។

៧. សូមមើល ម៉ាកុស ៥:៣៧ សូមមើលផងដែរ ម៉ាថាយ ៩:២៣–២៦; លូកា ៨:៥១ ទោះបីជាយ៉ាងណាក្តី ម៉ាថាយពុំបានដាក់ឈ្មោះ ពេត្រុស, យ៉ាកុប និង យ៉ូហាន ឡើយ ។

៨. សូមមើល ម៉ាកុស ៩:២–១០ សូមមើលផងដែរ ម៉ាថាយ ១៧:១–៨; លូកា ៩:២៨–៣៦ ។

៩. សូមមើល ម៉ាកុស ១៣:៣–៣៧ ។

១០. សូមមើល ម៉ាកុស ១៤:៣២–៣៤ សូមមើលផងដែរ ម៉ាថាយ ២៦:៣៦–៣៨ ។

១១. សូមមើល ម៉ាកុស ៣:១៧ ។ *បោនអើរកេ* គឺជាពាក្យក្រិកដែលប្រើជំនួសអក្សរអារ៉ាប់ bene regesh ឬ r’m មានន័យថា « កូននៃការរំជើបរំជួល ឬផ្គរលាន់ » ។

១២. សូមមើល Culpepper *John, the Son of Zebedee* ទំព័រ ៣៨–៤០, ៥០ ។

១៣. សូមមើល កិច្ចការ ៣:១–១១; ៤:១–២១; ៨:១៤–១៧ ។

១៤. សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា ៧; ៧៧; ៨៨:១៤១ ។

១៥. សូមមើល យ៉ូហាន ១៣:២៣; ១៩:២៦, ៣៤–៣៥; ២០:២–១០; ២១:១–១៤, ២០–២៥ សូមមើលផងដែរ Culpeppe,r *John, the Son of Zebedee* ទំព័រ ៥៧–៦៩ ។

១៦. សូមមើល យ៉ូហាន ១៩:៣៥; ២១:២៤–២៥ សូមមើលផងដែរ យ៉ូហាន ២០:៣០–៣១ ។

១៧. សូមមើល *Joseph Smith’s New Translation of the Bible: Original Manuscripts* កែសម្រួលដោយ Scott H. Faulring, Kent P. Jackson និង Robert J. Matthews ( ឆ្នាំ ២០០៤ ) ទំព័រ ២៣៤ ។

១៨. ឧទាហរណ៍អំពីការពិភាក្សារបស់ពួកអ្នកប្រាជ្ញស្តីពីអត្តសញ្ញាណនៃសិស្សសំណព្វ សូមមើល Culpepper *John, the Son of Zebedee* ទំព័រ ៧២–៨៥ និង Raymond E. Brow,n *An Introduction to the Gospel of John* កែសម្រួលដោយ Francis J. Moloney ( ឆ្នាំ ២០០៣ ) ទំព័រ ១៨៩–១៩៩ ។ សម្រាប់សាវកយ៉ូហានជាប្រភព ឬជាអ្នកនិពន្ធដំណឹងល្អរបស់យ៉ូហាន សូមមើល Richard Neitzel Holzapfel, Eric D. Huntsman និង Thomas A. Wayment, *Jesus Christ and the World of the New Testament* ( ឆ្នាំ ២០០៦ ) ទំព័រ ១២៦–១២៧ និងការសរសេរថ្មីៗផ្ទាល់របស់ខ្ញុំនៅក្នុង « The Gospel of John » នៅក្នុង *New Testament History, Culture, and Society* ( ឆ្នាំ ២០១៨ ) កែសម្រួលដោយ Lincoln Blumell ។

១៩. សូមមើល Raymond E. Brown, *The Epistles of John* (The Anchor Bible វ៉ុលទី ៣០ [ ឆ្នាំ ១៩៨២ ] ) ទំព័រ ៤៩–៥៥, ៧១ ។

២០. សូមមើល Culpepper *John, the Son of Zebedee* ទំព័រ ៩០–៩៥ និង Holzapfel, Huntsman និង Wayment, *Jesus Christ and the World of the New Testament* ទំព័រ ២៧៤–២៧៧ ។

២១. សូមមើល Holzapfel, Huntsman និង Waymen,t *Jesus Christ and the World of the New Testament,* ទំព័រ ២៨១–២៨២ ជាពិសេស នីហ្វៃទី ១ ១៤:១៨–២៧; អេធើរ ៤:១៦ និង គោលលទ្ធិ និងសេចក្តីសញ្ញា ៧:១–៣; ៧៧ ។



*ចម្រូតមាស* ដោយ ដាវីឌ មើរីល ទទួលបានសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ

សេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់គឺជាសេចក្ដីជំនឿដើម្បីច្រូតកាត់ ។ វាជាសេចក្ដីជំនឿនៅក្នុងព្រះចេស្ដារបស់ទ្រង់ ពុំមែនក្នុងអំណាចរបស់អ្នកទេ ។






**ដោយអែលឌើរ រៀលហ្វីង**
**ដប្លូលយូ អាន់ឌើរសិន**
*ក្នុងពួកចិតសិបនាក់*


# សេចក្តីជំនឿពីរកម្រិត

លីហៃ និងគ្រួសាររបស់លោកបាននៅក្នុងទីរហោស្ថានអស់រយៈពេលពីរបីថ្ងៃ នៅពេលព្រះអម្ចាស់បានប្រាប់លោកឲ្យបញ្ជូនពួកកូនប្រុសរបស់លោកត្រឡប់ទៅកាន់ទីក្រុងយេរូសាឡិម ដើម្បីទទួលយកផ្ទាំងលង្ហិនពីឡាបាន់ ។ ជារឿយៗ យើងពុំសរសើរកូនប្រុសពីរនាក់របស់លីហៃដែលបះបោរនោះទេ គឺលេមិន និងលេមយួល ប៉ុន្តែពួកគេពិតជាមានឆន្ទៈទៅ ។ ពួកគេមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីសាកល្បង ។

លេមិន ហើយក្រោយមកលេមយួលជាមួយបងប្អូនរបស់គាត់បានសូមផ្ទាំងពីឡាបាន់ ។ ពួកបងប្អូនទាំងនេះបាត់បង់ទ្រព្យសម្បត្តិគ្រួសាររបស់ពួកគេ ហើយស្ទើរតែបាត់បង់ជីវិតនៅក្នុងការប៉ុនប៉ងនោះ ។ នៅត្រង់ចំណុចនេះ សេចក្តីជំនឿរបស់លេមិន និង លេមយួល បានធ្វើឲ្យពួកគេបរាជ័យ ហើយពួកគេបម្រុងនឹងឈប់ ។ ប៉ុន្តែនីហ្វៃមានជំនឿឈ្នះលើគ្រោះថ្នាក់ និងការបាក់ទឹកចិត្តនោះ ៖



« ប្រាកដដូចជាព្រះអម្ចាស់ ទ្រង់មានព្រះជន្មរស់នៅ ហើយប្រាកដដូចជាយើងនៅមានជីវិត នោះយើងនឹងមិនចុះទៅរកឳពុកយើងនៅក្នុងទីរហោស្ថានឡើយ ទាល់តែយើងបានសម្រេចនូវកិច្ចការ ដែលព្រះអម្ចាស់ទ្រង់បានបញ្ជាយើងសិន ។

ហេតុដូច្នោះហើយ ចូរយើងមានចិត្តស្មោះត្រង់ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ » ( នីហ្វៃទី ១ ៣:១៥–១៦ ) ។

ក្រោយមក នីហ្វៃបានអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យរបស់លោក យកបានផ្ទាំងលង្ហិនពីឡាបាន់ ហើយបានត្រឡប់មករកបងៗរបស់លោកវិញ ហើយត្រឡប់ទៅកាន់ឳពុករបស់ពួកគេនៅក្នុងទីរហោស្ថានវិញ ។

វាហាក់បីដូចជាមានកម្រិតនៃសេចក្តីជំនឿពីរដាច់ពីគ្នា ។ កម្រិតទីមួយគឺសេចក្តីជំនឿដើម្បីសាកល្បង ជាជំនឿដើម្បីលូកកណ្តៀវរបស់យើង ។ កម្រិតទីពីរគឺសេចក្តីជំនឿដើម្បីធ្វើ ។ វាមានច្រើនជាងសេចក្តីជំនឿដើម្បីលូកកណ្តៀវរបស់អ្នក—វាជាសេចក្តីជំនឿដើម្បីច្រូតកាត់ ។

*ព្រះគ្រីស្ទនៅក្នុងសួនច្បារគែតសេម៉ានី ដោយ ហែរ៉ា អាន់ឌើសិន*

លេមិន និង លេមយួលមានសេចក្តីជំនឿដើម្បីសាកល្បង ប៉ុន្តែនីហ្វៃមានសេចក្តីជំនឿដើម្បីធ្វើ ។ លេមិន និងលេមយួលមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីសាកល្បងលូកកណ្តៀវរបស់ពួកគេ ប៉ុន្តែនីហ្វៃមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីច្រូតកាត់ ។

ភាពប៉ិនប្រសប់ដាច់ដោយឡែកពីគ្នារវាងសេចក្តីជំនឿដើម្បីលូកកណ្តៀវរបស់អ្នក និងសេចក្តីជំនឿដើម្បីច្រូតកាត់នឹងធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់អ្នក ។ ដើម្បីរស់នៅម្តងទៀតជាមួយព្រះវរបិតាសួគ៌យើង និងដើម្បីរស់នៅក្នុងជីវិតដ៏មានប្រយោជន៍ និងរីករាយនៅលើផែនដីនេះ យើងត្រូវតែអភិវឌ្ឍនូវជំនឿដើម្បីច្រូតកាត់ ។

យើងបានទទួលការសន្យាដ៏អស្ចារ្យមកពីព្រះអម្ចាស់—ការសន្យានៃសុភមង្គល និងអំណរនៅក្នុងជីវិតនេះ និងភាពតម្កើងឡើងនៅក្នុងជីវិតបន្ទាប់ ។ ប៉ុន្តែឧបសគ្គ និងបញ្ហានានានៃជីវិតប្រចាំថ្ងៃរបស់យើង ទំនងជាបំផ្លាញសេចក្តីសង្ឃឹមរបស់យើង ។ ដែនដីសន្យារបស់យើងហាក់ដូចជានៅសែនឆ្ងាយ ដែលមិនអាចទៅដល់ ហើយយើងចាប់ផ្តើមមានចិត្តសង្ស័យ ។

យើងគិតថា « ខ្ញុំពុំអាចទៅដល់គោលដៅនោះទេ ឬទទួលបានពរជ័យនោះទេ ។ ប្រាកដណាស់ ព្រះអម្ចាស់កំពុងព្រះតម្រិះអំពីមនុស្សម្នាក់ទៀត នៅពេលទ្រង់ចុះកិច្ចសន្យាទាំងនោះ » ។

អត់ទេ ទ្រង់ *កំពុង* ព្រះតម្រិះពីបងប្អូន និងខ្ញុំ ។ យើងត្រូវតែមានសេចក្តីជំនឿគ្រប់គ្រាន់ដើម្បីទទួលពរជ័យរបស់យើង—ជាជំនឿដ៏ខ្លាំងថា វាអាចផ្លាស់ប្តូរការសន្យានាពេលអនាគតរបស់យើងឲ្យទៅជាភាពពិតប្រាកដក្នុងពេលបច្ចុប្បន្ន ។ យើងត្រូវការសេចក្តីជំនឿដើម្បីច្រូតកាត់ ។

តើអ្វីជាសេចក្តីជំនឿនេះឲ្យពិតប្រាកដ ហើយតើយើងអាចអភិវឌ្ឍវាដោយរបៀបណា ?

## ចូរមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ

ទីមួយ មិនដូចជាសេចក្តីជំនឿដើម្បីលូកកណ្តៀវរបស់អ្នកឡើយ សេចក្តីជំនឿដើម្បីច្រូតកាត់គឺពុំមែនជាសេចក្តីជំនឿលើខ្លួនអ្នកឡើយ ។ វាពុំដូចគ្នានឹងការមានទំនុកចិត្តលើ



ចូរអធិស្ឋានរៀងរាល់ថ្ងៃ ទូលសូមឲ្យព្រះវរបិតាសួគ៌ នឹងប្រទានពរដល់អ្នក ជាមួយនឹងបំណងប្រាថ្នា សុចរិតដើម្បីសម្រេចឆន្ទៈ របស់អ្នកទៅនឹងព្រះទ័យ របស់ទ្រង់ ។

ខ្លួនឯង ឬមានឥរិយាបថផ្លូវចិត្តវិជ្ជមានឡើយ ។ វាក៏ពុំមែនជាសេចក្ដីជំនឿលើគ្រួសារ ឬមិត្តភក្ដិរបស់អ្នកទេ—ទាំងនេះគឺសុទ្ធតែល្អ ។ សេចក្ដីជំនឿដើម្បីច្រូតកាត់គឺជាសេចក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ វាជាសេចក្ដីជំនឿនៅក្នុងព្រះចេស្ដារបស់ទ្រង់ ពុំមែនក្នុងអំណាចរបស់អ្នកទេ ។

កាលខ្ញុំត្រូវបានហៅឲ្យបម្រើជាប្រធានស្តេកនៅស្តេកមេសា អារីស្សូណា ម៉ារីកូប៉ា អែលឌើរ ដុបលយូ ម៉ាករ ឡូរិន កាលនោះជាពួកចិតសិបនាក់ដែលមានសិទ្ធិអំណាចទូទៅ បានអញ្ជើញខ្ញុំ និងភរិយាខ្ញុំឲ្យទៅការិយាល័យប្រធានស្តេក ហើយផ្តល់ការហៅបម្រើនោះ ។ ខ្ញុំបានទទួលយកវាដោយស្មោះស្ម័គ្រ ។ បន្ទាប់មក លោកបានអញ្ជើញយើងឲ្យចូលទៅក្នុងបន្ទប់ក្រុមប្រឹក្សាជាន់ខ្ពស់ ហើយពិចារណាប្រកបដោយការអធិស្ឋានអំពីបុរសដែលត្រូវផ្តល់អនុសាសន៍ធ្វើជាទីប្រឹក្សារបស់ខ្ញុំ ។ នៅពេលខ្ញុំចូលទៅក្នុងបន្ទប់នោះ ខ្ញុំបានឃើញរូបថតនៃប្រធានស្តេកទាំងអស់ ដែលបានបម្រើកាលពីមុននៅក្នុងស្តេក តាំងពីពេលដែលស្តេកបានបង្កើតឡើង ហើយខ្ញុំបានបាត់បង់ទំនុកចិត្ត ។ ពួកលោកគឺជាថ្នាក់ដឹកនាំដ៏អស្ចារ្យទាំងនៅក្នុងសាសនាចក្រ និងក្នុងសហគមន៍ ។

ខ្ញុំបានមើលទៅភរិយារបស់ខ្ញុំ ហើយនិយាយថា « ខាធ្លីន បងគិតថា បងមិនអាចបម្រើក្នុងមុខងារនេះបានទេ ។ បងមិនល្អដូចពួកលោកឡើយ » ។

ខាធ្លីនបាននិយាយថា « បងមិនបាច់ប្រាប់ខ្ញុំទេ ។ បងគួរតែនិយាយប្រាប់អែលឌើរឡូរិនទៅ » ។

ដោយក្តីភ្ញាក់ផ្អើល នៅពេលខ្ញុំបានប្រាប់លោកថា ខ្ញុំគិតថា ខ្ញុំពុំអាចបំពេញការហៅបម្រើនេះទេ នោះអែលឌើរឡូរិនបានតបថា « ខ្ញុំគិតថា ប្អូនគិតត្រូវហើយ » ។

ប៉ុន្តែក្រោយមកលោកមានប្រសាសន៍ថា « ប្អូនមិនអាចធ្វើវាបានទេ ប៉ុន្តែព្រះអម្ចាស់អាច ។ ទ្រង់មានព្រះចេស្តាដើម្បីធ្វើកិច្ចការរបស់ទ្រង់ ហើយប្រសិនបើប្អូននឹងមានភាពសក្តិសម ហើយខិតខំធ្វើការ នោះទ្រង់នឹងធ្វើកិច្ចការនោះ ។ ប្អូននឹងឃើញរឿងនោះ » ។

ហើយទ្រង់ពិតជាបានធ្វើរឿងនោះមែន ។

សេចក្តីជំនឿដើម្បីលូកកណ្តៀវរបស់អ្នកគឺជាសេចក្តីជំនឿដើម្បីសាកល្បង ។ វាជាសេចក្តីជំនឿលើខ្លួនឯង ហើយវានឹងរសាយបាត់ទៅ នៅពេលដែលស្ថានភាពនោះវាប្រែកាន់តែពិបាក ។ បន្ទាប់មក យើងចាប់ផ្តើមមានចិត្តសង្ស័យ ។ ប៉ុន្តែសេចក្តីជំនឿដើម្បីច្រូតកាត់គឺជាសេចក្តីជំនឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ វាពុំទោរទន់ឡើយ ។

## សម្របឆន្ទៈរបស់អ្នកជាមួយនឹងព្រះទ័យរបស់ព្រះ

ដើម្បីអនុវត្តសេចក្តីជំនឿដើម្បីច្រូតកាត់ យើងត្រូវប្រាកដចិត្តថា បំណងប្រាថ្នា និងគោលបំណងរបស់យើងត្រូវគ្នានឹងព្រះទ័យរបស់ព្រះ ។ យើងពុំអាចអនុវត្តសេចក្តីជំនឿដើម្បីច្រូតកាត់បានឡើយ ប្រសិនបើព្រះពុំយល់ស្របនឹងលទ្ធផលនោះ ។ ដើម្បីទទួលបានជំនួយរបស់ទ្រង់ យើងត្រូវតែសម្របឆន្ទៈរបស់យើងជាមួយព្រះទ័យរបស់ទ្រង់ ។

ដោយសារព្យាការីនីហ្វៃនៅក្នុងព្រះគម្ពីរហេលេមិនជាមនុស្សសុចរិត និងស្មោះត្រង់ ព្រះអម្ចាស់ប្រាប់លោកថា « យើងនឹងប្រទានពរឲ្យអ្នករហូតតទៅ ហើយយើងនឹងធ្វើឲ្យអ្នកខ្លាំងពូកែនៅក្នុងសម្តី និងក្នុងចរិយា ក្នុងសេចក្តីជំនឿ និងក្នុងកិច្ចការទាំងឡាយ មែនហើយ គឺដើម្បីឲ្យគ្រប់ការណ៍ទាំងអស់ ត្រូវបានសម្រេចដល់អ្នក ស្របតាមពាក្យរបស់អ្នក » ។ នោះគឺជាការសន្យាដ៏អស្ចារ្យ ។ បន្ទាប់មកព្រះអម្ចាស់បន្ថែមថា « ព្រោះអ្នកនឹងពុំប្រាថ្នាអ្វី ដែលផ្ទុយពីបំណងរបស់យើងឡើយ » ( ហេលេមិន ១០:៥ ) ។

ហើយមរ៉ូណៃប្រាប់យើងដូច្នេះ ៖ « បើសិនជាអ្នករាល់គ្នាមានសេចក្តីជំនឿជឿដល់យើង នោះអ្នករាល់គ្នានឹងមានអំណាច ប្រយោជន៍នឹងធ្វើនូវអ្វីៗដែលជាការចំបាច់ដល់យើង » ( មរ៉ូណៃ ៧:៣៣ ) ។

ការសម្រេចបំណងប្រាថ្នារបស់យើងទៅនឹងព្រះទ័យរបស់ព្រះគឺត្រូវកើតឡើងមុនសេចក្ដីជំនឿដើម្បីច្រូតកាត់ ។

កាលពួកកូនប្រុសរបស់យើងនៅក្មេង ពួកគេបានលេងនៅក្នុងក្រុមកីឡាវាយកូនបាល់នៅវិទ្យាល័យ ។ កាលនោះពួកគេធ្លាប់បានអធិស្ឋានជាក្រុមពីមុនចាប់ផ្ដើមការប្រកួតនីមួយៗ ។ នៅពេលខ្ញុំបានមើលពីលើវេទិកា នោះខ្ញុំធ្លាប់ឆ្ងល់ថា តើពួកគេអធិស្ឋានទូលសូមអ្វី ។ ប្រសិនបើពួកគេអធិស្ឋានទូលសូមឲ្យឈ្នះការប្រកួត នោះការអធិស្ឋានរបស់ពួកគេគឺខ្វះសេចក្ដីជំនឿដើម្បីច្រូតកាត់ហើយ ។ ការណ៍នេះត្រូវបានបង្ហាញយ៉ាងច្បាស់ដោយពួកគេបានចាញ់ការប្រកួតជាច្រើនដង ។ ព្រះអម្ចាស់ទំនងជាពុំចូលរួមនឹងបំណងប្រាថ្នារបស់ពួកគេថាពួកគេចាំបាច់ត្រូវឈ្នះគ្រប់ការប្រកួតនោះទេ ។

ម្យ៉ាងទៀត ព្រះនឹងជួយពួកយើងឲ្យសម្រេចបាននូវគោលបំណងតែមួយគត់ដែលល្អសម្រាប់យើង ។ នោះគឺដោយសារទ្រង់ស្រឡាញ់យើង ហើយទ្រង់ស្គាល់ច្បាស់ជាងយើងនូវអ្វីដែលនឹងក្លាយជាសេចក្ដីល្អសម្រាប់យើង ។ ហើយតើយើងពុំមានអំណរគុណចំពោះរឿងនេះទេឬ ។ យើងគួរតែអធិស្ឋានរៀងរាល់ថ្ងៃទូលសូមថាព្រះវរបិតាសួគ៌នឹងប្រទានពរដល់យើង ជាមួយនឹងបំណងប្រាថ្នាសុចរិតដើម្បីសម្របឆន្ទៈរបស់យើងទៅនឹងព្រះទ័យរបស់ទ្រង់ ។ យើងត្រូវតែរៀនអធិស្ឋាន ដូចព្រះអម្ចាស់បានអធិស្ឋាននៅក្នុងសួនច្បារគែតសេម៉ានីថា សូមតាមតែព្រះទ័យរបស់ព្រះចុះ កុំតាមចិត្តយើងឡើយ ( សូមមើល លូកា ២២:៤២ ) ។ បន្ទាប់ពីនោះ យើងអាចអនុវត្តសេចក្ដីជំនឿដើម្បីច្រូតកាត់ ។

## ចេញទៅធ្វើការ

ចំណុចទីបីដែលត្រូវធ្វើមុនសេចក្ដីជំនឿដើម្បីច្រូតកាត់នោះគឺការធ្វើការ ។ សាវកយ៉ាកុបបានថ្លែងយ៉ាងច្បាស់ថា សេចក្ដីជំនឿដែលឥតមានការប្រព្រឹត្តតាម នោះឈ្មោះថាស្លាប់ហើយ ។ សេចក្ដីជំនឿដើម្បីលូកកណ្ដៀវរបស់យើងតម្រូវឲ្យមានជំនឿ ប៉ុន្តែសេចក្ដីជំនឿដើម្បីច្រូតកាត់តម្រូវឲ្យមានលើសពីជំនឿ ។ សាវកយ៉ាកុបសរសេរថា ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ ( សូមមើល យ៉ាកុប ២:១៧, ១៩ ) ។

ខ្ញុំបានស្ដាប់រឿងមួយអំពីឪពុកម្នាក់ដែលបានកត់សម្គាល់ឃើញកូនស្រីរបស់គាត់លុតជង្គង់អធិស្ឋាននៅក្បែរគ្រែរបស់នាង ដោយអធិស្ឋានទូលសូមឲ្យព្រះវរបិតាសួគ៌នឹងការពារកូនបក្សីពីការចូលក្នុងអន្ទាក់ ដែលបងប្រុសរបស់នាងបានធ្វើ ហើយដាក់វានៅវាលហាលខាងក្រោយផ្ទះ ។ ក្រោយមកទៀតនៅថ្ងៃនោះ ឪពុកនោះកាន់តែមានកង្វល់ឡើង ។ គាត់ដឹងថា អន្ទាក់នោះគឺជាអន្ទាក់ល្អមួយ ។ គាត់បានជួយកូនប្រុសរបស់គាត់ធ្វើអន្ទាក់នោះ ។

គាត់បាននិយាយទៅកាន់កូនស្រីរបស់គាត់ថា « ប៉ាឮកូនអធិស្ឋានព្រឹកមិញសូមឲ្យព្រះវរបិតាសួគ៌នឹងការពារកូនបក្សីពីការជាប់អន្ទាក់បងប្រុសរបស់កូន ។ ប៉ុន្តែជួនកាលរឿងដ៏សោកសៅកើតឡើង នៅពេលយើងអធិស្ឋានសូមកុំឲ្យវាកើតឡើងបែបនោះ » ។

នាងបានតបថា « ប៉ាកូនដឹងថា បងប្រុសនឹងពុំចាប់បានបក្សីណាមួយឡើយ » ។

ឪពុកនិយាយថា « ប៉ាសូមសរសើរដល់សេចក្ដីជំនឿរបស់កូនសំឡាញ់ ។ ប៉ុន្តែប្រសិនបើបងប្រុសកូនចាប់បានបក្សីមួយចំនួននោះ ប៉ាសង្ឃឹមថា បងប្រុសកូននឹងពុំធ្វើឲ្យប៉ះពាល់ដល់សេចក្ដីជំនឿរបស់កូនទេ » ។

នាងបានពោលថា « បងប្រុសនឹងពុំចាប់បានបក្សីទេ ។ ខ្ញុំដឹងថា គាត់នឹងពុំចាប់បានឡើយ » ។

ឪពុកបានសួរថា « តើកូនអាចមានសេចក្ដីជំនឿដ៏ខ្លាំងបែបនោះដោយរបៀបណា ? »

កូនស្រីរបស់គាត់បានតបថា « ដោយសារបន្ទាប់ពីកូនបានអធិស្ឋានរួច កូនបានដើរចេញទៅក្រោយផ្ទះ ហើយទាត់អន្ទាក់ដាក់សត្វបក្សីរបស់គាត់ឲ្យបែកអស់ » ។

វាជារឿងល្អដើម្បីអធិស្ឋានទូលសូមពរជ័យពីព្រះវរបិតាសួគ៌ ។ ប៉ុន្តែបន្ទាប់ពីយើងអធិស្ឋានរួច យើងត្រូវចេញទៅធ្វើការ ។ យើងមិនអាចរំពឹងថា ព្រះអម្ចាស់ដឹកនាំដំណើររបស់យើងឡើយ ប្រសិនបើអ្នកគ្មានឆន្ទៈរំកិលជើងរបស់យើងនោះ ។ ហើយយើងក៏មិនអាចសូមឲ្យទ្រង់ធ្វើកិច្ចការសម្រាប់យើងនូវអ្វីដែលយើងអាច និងគួរធ្វើសម្រាប់ខ្លួនយើងឡើយ ។

យើងត្រូវធ្វើការដើម្បីសម្រេចគោលដៅសុចរិតរបស់យើង ហើយយើងត្រូវតែខិតខំធ្វើការក្នុងការគោរពបទបញ្ញត្តិ ។ អំណាចដ៏ពិតនៅក្នុងសេចក្ដីសញ្ញារបស់យើង និងអំណាចដ៏ពិតនៅក្នុងសេចក្ដីជំនឿដើម្បីច្រូតកាត់ គឺពុំត្រូវបានទទួលស្គាល់នៅពេលយើងបញ្ចប់ដោយប្រាកដប្រជាថា ព្រះរក្សាការសន្យារបស់ទ្រង់ឡើយ ប៉ុន្តែផ្ទុយទៅវិញគឺនៅពេលយើងបញ្ចប់ដោយប្រាកដប្រជាដើម្បីរក្សាការសន្យារបស់យើង ។ សេចក្ដីពិតដ៏អស្ចារ្យនោះគឺជាអ្វីដែលផ្លាស់ប្ដូរការសន្យានាពេលខាងមុខរបស់យើងឲ្យទៅជាភាពពិតប្រាកដក្នុងពេលបច្ចុប្បន្ននេះ ។ យើងត្រូវតែធ្វើការ ។

សូមកុំបាក់ទឹកចិត្តចំពោះបរាជ័យ ឬកំហុសរបស់អ្នកឡើយ ប៉ុន្តែសូមមានភាពខ្ជាប់ខ្ជួននៅក្នុងកិច្ចខិតខំរបស់អ្នក ហើយមានការប្ដេជ្ញាចិត្ត ។ សេចក្ដីជំនឿដើម្បីច្រូតកាត់ពុំតម្រូវឲ្យមានភាពល្អឥតខ្ចោះនោះទេ ប៉ុន្តែវាតម្រូវឲ្យមានភាពខ្ជាប់ខ្ជួន ។

ខ្ញុំសូមអញ្ជើញអ្នកឲ្យអភិវឌ្ឍសេចក្ដីជំនឿដើម្បីច្រូតកាត់ ។ សូមដាក់សេចក្ដីជំនឿរបស់អ្នកឲ្យរឹងមាំលើព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ សូមប្រាកដថា បំណងប្រាថ្នារបស់អ្នកស្រប ហើយធ្វើតាមព្រះទ័យរបស់ទ្រង់ ។ បន្ទាប់មកទៅធ្វើការដោយអស់ពីចិត្ត គំនិត កម្លាំង និងពលំរបស់អ្នក ដោយការប្ដេជ្ញាចិត្តពុំចុះចាញ់ ហើយខ្ជាប់ខ្ជួន ។ គ្មានឧបសគ្គ គ្មានបញ្ហា គ្មានរនាំងណាដែលនឹងមិនតម្រូវឲ្យមានសេចក្ដីជំនឿដើម្បីច្រូតកាត់នោះទេ ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « The Faith to Reap » បានថ្លែងនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់-អៃដាហូ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ ។*



**បង្កើនសេចក្ដីជំនឿរបស់អ្នក**

« មានអង្គតែមួយគត់ដែលក្ដីជំនឿយើងតែងមានសុវត្ថិភាព គឺលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ។ ហើយអ្នកត្រូវបង្ហាញក្ដីជំនឿអ្នក ! »

ប្រធាន រ័សុល អិម ណិលសុន « ចូរបង្ហាញសេចក្ដីជំនឿអ្នក » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ២៩ ។

បេសកកម្មដ៏មហាអស្ចារ្យរបស់ព្យាការី

# យ៉ូសែប ស៊្មីធ





ខ្ញុំបានជ្រើសរើសនិយាយអំពីយ៉ូសែប ស្ម៊ីធ ជាព្យាការី និងបុរសដ៏អស្ចារ្យ ។ និយាយដល់លោក ខ្ញុំសង្ឃឹមថា ខ្ញុំនឹងចែករំលែកចំណេះដឹងដល់បងប្អូនអំពីសមិទ្ធិផលដ៏ពិសេស និងមហាអស្ចារ្យរបស់បុព្វព្យាការីនៃគ្រាកាន់កាប់ត្រួតត្រានេះ ។

ទំនាក់ទំនងនៃចំណេះដឹង និងទីបន្ទាល់របស់យ៉ូសែប ស្ម៊ីធចំពោះកិច្ចការផ្សព្វផ្សាយសាសនាគឺសំខាន់ខ្លាំងណាស់ ។ យើងទាំងអស់គ្នាដឹងថា សាសនាគន់ការីមួយចំនួនទទួលយកគោលលទ្ធិគ្រឹះនៃដំណឹងល្អ ប៉ុន្តែមិនអាចទទួលយកការពិតដែលថាក្មេងប្រុសអាយុ១៤ឆ្នាំត្រូវបានព្រះវរបិតា និងព្រះរាជបុត្រាយាងមកជួប ហើយថាលោកបានបកប្រែព្រះគម្ពីរមរមន និងបានក្លាយជាព្យាការីដែលយើងបានស្គាល់នោះទេ ។ មនុស្សទាំងឡាយដែលមានការពិបាកក្នុងការជឿលើរឿងរបស់ព្យាការី យ៉ូសែប ស្ម៊ីធត្រូវរៀនពីការបង្រៀននេះរបស់ប្រធាន វ៉សុល អិម ណិលសុន ៖

« បេសកកម្មរបស់យ៉ូសែប ស្ម៊ីធ នៅក្នុងជីវិតរមែងស្លាប់គឺត្រូវបានតែងតាំងជាមុន ។ គំនិតទទួលយកដ៏ល្អរបស់លោកបានបើកផ្លូវទទួលការណែនាំរបស់ព្រះអម្ចាស់ ។ ប៉ុន្តែ បើតាមបទដ្ឋានរបស់លោកិយ យ៉ូសែប ស្ម៊ីធ ហាក់ដូចជាមិនមានគុណសម្បត្តិគ្រប់គ្រាន់នោះទេ ។ ហើយកិច្ចការរបស់លោកក្នុងការធ្វើជាព្យាការីនៃគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះគឺហាក់ដូចជាពុំអាចធ្វើបាននោះឡើយ ។ គំរូនេះបង្ហាញពីគោលការណ៍មួយដែលជាញឹកញាប់គឺពិតអំពីរបៀបដែលព្រះអម្ចាស់ធ្វើកិច្ចការ ៖ ទ្រង់ប្រើប្រាស់ជនដែលមិនទំនងជាមានគុណសម្បត្តិគ្រប់គ្រាន់ឲ្យសម្រេចបានកិច្ចការដែលមិនគួរឲ្យជឿ ! »[១]

វាសំខាន់ណាស់ថា អ្នកផ្សព្វផ្សាយសាសនារបស់យើងមានទីបន្ទាល់អំពីការហៅដ៏ទេវភាព និងកិច្ចការដ៏មហាអស្ចារ្យនៃព្យាការី យ៉ូសែប ស្ម៊ីធ ។

ខ្ញុំគឺជាកូនសិស្សអស់ ៦៥ ឆ្នាំ រៀនអំពីជីវិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ ខ្ញុំបានកើតនៅក្នុងឆ្នាំ ១៩៣២ ពេលសាសនាចក្រទើបតែមានអាយុជាង ១00 ឆ្នាំ ។ ខ្ញុំជឿថា ខ្ញុំជាពួកបរិសុទ្ធថ្ងៃចុងក្រោយ

*JOSEPH SMITH JR., ដោយ WILLIAM WHITAKER, សិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ; រូបចាក់ពុម្ពបានទទួលសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ*



**ដោយប្រធាន**
**ដាល្លិន អេក អូក**
ទីប្រឹក្សាទីមួយក្នុង
គណៈប្រធានទីមួយ

**យ៉ូសែប ស្ម៊ីធ សម្រេចបាននូវសមិទ្ធិផលច្រើនជាងមនុស្សរមែងស្លាប់ណា ៗទាំងអស់ដែលអាចសម្រេចបាននៅក្នុងរយៈពេលដ៏ខ្លី ។ ការពន្យល់តែមួយដែលអាចមានគឺទទួលជំនួយពីស្ថានសួគ៌ ។**





*នៅពេលដែលលោកទទួលមរណៈភាព យ៉ូសែប ស្ម៊ីធ កំពុងបម្រើជាចៅហ្វាយក្រុងណៅវូផង និងជានាយឧត្តមសេនីយ៍ទោនៃកងពលណៅវូផង ។*

ដ៏ស្មោះត្រង់សាមញ្ញក្នុងសតវត្សទីពីរនៃសាសនាចក្រនេះ ។ យើងពុំបានជួបនឹងយ៉ូសែប ស្ម៊ីធនោះទេ តែយើងមានអារម្មណ៍ថាស្គាល់លោក ហើយយើងស្រឡាញ់លោកតាមរយៈអ្វីដែលលោកបានបង្ហាញ និងបង្រៀន ។ យើងជាសាក្សីនៃសេចក្ដីពិតនៃការព្យាករដូចកំណាព្យមួយពោលថា « រាប់លាននឹងស្គាល់ ‹ បងយ៉ូសែប › » ។[២]



## I. យ៉ូសែប ស្ម៊ីធ ជាព្យាការី

យើងទាំងអស់គ្នាស្គាល់ យ៉ូសែប ស្ម៊ីធ ថាជាព្យាការីទីមួយនៃគ្រាកាន់កាប់ត្រួតត្រានេះ ជាឧបករណ៍នៃព្រះអម្ចាស់នៅក្នុងការស្ដារឡើងវិញរបស់ព្រះអម្ចាស់ ។ ប៉ុន្តែ តើព្រះអម្ចាស់បានស្ដារអ្វីខ្លះតាមរយៈព្យាការីរូបនេះ ? មិនមែនពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងអស់ ( និងអ្នកមិនមែនសមាជិកមួយចំនួន ) ដឹងថាព្រះអម្ចាស់បានបំផុសដល់ព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យធ្វើការស្រាយបំភ្លឺ និងការបន្ថែមដ៏ច្រើនក្រៃលែងទៅលើគោលលទ្ធិគ្រីស្ទសាសនាឡើយ ។ នេះជាបញ្ជីសង្ខេបមួយ ៖

- លក្ខណៈនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។
- មុខងារដែលទាក់ទងគ្នារបស់សមាជិកទាំងបីនៃក្រុមព្រះ និងទំនាក់ទំនងរបស់ពួកទ្រង់ចំពោះតួអង្គមែងស្លាប់ ។
- លក្ខណៈនៃការធ្លាក់នៃមនុស្ស ។
- គោលបំណងនៃជីវិតមែងស្លាប់នៅក្នុងការពន្លឿនទៅមុខនៃផែនការរបស់ព្រះវរបិតាសម្រាប់បុត្ររបស់ទ្រង់ដើម្បីទទួលបាននូវជោគវាសនាដ៏អស់កល្បរបស់ពួកគេ ។
- មុខងារនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នៅក្នុងការធានាបាននូវអមតភាព និងនៅក្នុងការផ្ដល់ឱកាសឲ្យមានជីវិតអស់កល្ប ។
- មុខងារនៃអាពាហ៍ពិពាហ៍លើផែនដី និងអស់កល្បនៅក្នុងផែនការរបស់ព្រះវរបិតា ។
- មុខងារដ៏ចាំបាច់នៃបព្វជិតភាព និងពិធីបរិសុទ្ធទាំងឡាយនៅក្នុងផែនការរបស់ព្រះវរបិតា ។
- មុខងារដ៏ចាំបាច់នៃព្រះវិហារបរិសុទ្ធ និងពិធីការជំនួសនៅក្នុងផែនការរបស់ព្រះវរបិតា ។
- ចំណេះដឹងដែលថា ព្រះមានព្រះរាជបំណងសង្គ្រោះបុត្រាបុត្រីទាំងអស់របស់ទ្រង់ ហើយថាមនុស្សគ្រប់រូបដែលបានរស់នៅលើផែនដីនេះ—មិនថាពួកគេស្គាល់ព្រះយេស៊ូវគ្រីស្ទ ឬអត់—គឺមានលទ្ធភាពក្នុងការទទួលបាននូវស្ថានសួគ៌កម្រិតដ៏ខ្ពស់បំផុតនៅបរលោក ។
- ទំនាក់ទំនងនៃប្រភពបីផ្នែកនៃសេចក្ដីពិតអំពីមនុស្ស និងសាកលលោក ៖ វិទ្យាសាស្ត្រ ព្រះគម្ពីរ និងវិវរណៈដែលមានជាបន្ត ។



*យ៉ូសែប ស្ម៊ីធ បានកើតនៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៨០៥ នៅទីក្រុងសារ៉ុន រដ្ឋវើម៉ុន ស.រ.អា. ។*

នរណាក៏ដោយដែលសិក្សាសូម្បីតែផ្នែកដ៏តូចមួយនៃបញ្ជីនេះ—មិនថាអ្នកជឿ ឬអ្នកមិនជឿ—ត្រូវតែទទួលស្គាល់ថា យ៉ូសែប ស្ម៊ីធ ឈរនៅឯក្បាលទឹកនៃអូរដ៏ធំសម្បើមនៃគំនិតសាសនាដ៏រឹងមាំ ថ្មី និងមានតម្លៃ ។ ដូចយើងអាននៅក្នុង *ប្រកាសដំណឹងល្អយើង* ភាពពេញលេញនៃដំណឹងល្អត្រូវបានស្ដារឡើងវិញដល់ផែនដីនេះតាមរយៈ យ៉ូសែប ស្ម៊ីធ ។[៣]

អ្នកអាចនឹងកត់សម្គាល់ឃើញថា បញ្ជីរបស់ខ្ញុំពុំបានលើកឡើងជាក់លាក់នូវការនាំមកនៃព្រះគម្ពីរមរមនរបស់យ៉ូសែប ជាព្រះគម្ពីររំលថ្មី ដែលពិតជាប្រភពនៃគំនិតសាសនាថ្មីៗជាច្រើនទាំងនោះ ។ គម្ពីរនោះសមនឹងទទួលការលើកឡើងជាពិសេស ។ ទំព័របព្វកថារបស់វាប្រកាសពីមុខងារដ៏សំខាន់បំផុតរបស់វាគឺ ៖ « សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » ។ ប៉ុន្តែវាមានច្រើនជាងមុខងារគ្រឹះនោះទៅទៀត ។ នេះជាអ្វីដែលអ្នកប្រាជ្ញម្នាក់ដែលសៀវភៅគាត់លក់ដាច់បំផុត បានមានប្រសាសន៍អំពីគម្ពីរនេះ ៖

« *ព្រះគម្ពីរមរមន* ដាក់បង្ហាញនូវគោលបំណងថ្មីមួយសម្រាប់ប្រទេសអាមេរិក ៖ ក្លាយជាប្រទេសនៃសុចរិតភាពមិនត្រឹមតែជាប្រទេសនៃសេរីភាពនោះទេ ។ ផ្ទុយពីទ្រព្យសម្បត្តិ និងវិសមភាពដែលចេះតែកើនឡើង នោះ*ព្រះគម្ពីរមរមន* គាំទ្រដល់បុព្វហេតុនៃអ្នកក្រីក្រ ។ . . . ផ្ទុយពីរដ្ឋាភិបាលសាធារណរដ្ឋនោះវាស្នើឲ្យមានច្បាប់សុចរិតដោយចៅក្រម និងស្ដេច ដោយនៅក្រោមច្បាប់របស់ព្រះ ។ វាផ្ទុយពីគំរូព្រះគម្ពីរបរិសុទ្ធ និងសាសនាដែលគ្មានអព្ភូតហេតុ *ព្រះគម្ពីរមរមន*ឈរជាវិវរណៈដែលចេះតែបន្តអព្ភូតហេតុ និងវិវរណៈដល់គ្រប់ជាតិសាសន៍ទាំងអស់ ។ វាផ្ទុយនឹងការសង្ស័យ វាលើកស្ទួយជំនឿ វាផ្ទុយនឹងជាតិនិយម វាជំរុញឲ្យមានសាសន៍អ៊ីស្រាអែលជាសាកល ។ វាព្យាករពីមហន្តរាយនៃជាតិសាសន៍ បើពួកគេស្រឡាញ់ទ្រព្យសម្បត្តិ រឹងទទឹងមិនទទួលស្គាល់វិវរណៈ និងអារ្យធម៌សាសន៍ដទៃជាជាងសុចរិតភាព វិវរណៈ និងសាសន៍អ៊ីស្រាអែលនោះ » ។[៤]

សំខាន់ជាងនោះទៀត គឺអ្វីដែលប្រធាន ណិលសុន បានមានប្រសាសន៍ថ្មីៗនេះអំពីព្រះគម្ពីរមរមនថា ៖ វា « គឺជាឧបករណ៍ដែលធ្វើឲ្យការប្រមូលផ្ដុំនៃសាសន៍អ៊ីស្រាអែលដែលបានសន្យានឹងត្រូវបានសម្រេច » ។[៥]

រូបថត៖ MACK នៅទីក្រុងសារ៉ុន រដ្ឋវើម៉ុន ដោយ GEORGE EDWARD ANDERSON ទទួលបានសិទ្ធិអនុញ្ញាតពីបណ្ណាល័យ និងបណ្ណសារប្រវត្តិសាស្ត្រសាសនាចក្រ ។







**យ៉ូសែប ស្ម៊ីធ ឈរនៅឯក្បាលទឹកនៃអូរដ៏ធំសម្បើមនៃគំនិតសាសនាដ៏រឹងមាំ ថ្មី និងមានតម្លៃ ។**

ដូចយើងបានអាននៅក្នុង *ប្រកាសដំណឹងល្អយើង* ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា ព្រះគម្ពីរមរមនគឺជា « មូលដ្ឋាននៃសាសនារបស់យើង » ។[៦]

អ្នកដែលមិនមែនជាពួកបរិសុទ្ធថ្ងៃចុងក្រោយភាគច្រើនពុំដឹងពីការរួមចំណែកដ៏ធំធេងរបស់យ៉ូសែប ស្ម៊ីធ ដល់គំនិតខាងសាសនានោះទេ ។ នៅក្នុងការសិក្សាទូទាំងប្រទេសដ៏គួឲ្យកត់សម្គាល់មួយ អ្នកស្ទង់មតិ ហ្គេរី ឡូរិនស៍ បានរកឃើញថា ជិតពាក់កណ្ដាលនៃមនុស្សដែលគាត់បានសិក្សា បានគិតថាពួកបរិសុទ្ធថ្ងៃចុងក្រោយនៅដាច់ពីគេ ហើយអាថ៌កំបាំង និងមាន « ជំនឿដ៏ចម្លែក » ។[៧] ពេលគាត់បានសួរដល់អ្នកសម្ភាស « តើអ្វីទៅជាការប្រកាសដ៏ចម្បងនៃជំនឿមរមន ? » មានតែម្នាក់ក្នុងចំណោមប្រាំពីរនាក់ប៉ុណ្ណោះដែលពិពណ៌នាជិតត្រូវទៅហ្នឹងការស្ដារឡើងវិញ ឬការស្ដាបនាឡើងវិញនៃជំនឿគ្រីស្ទានដើម ។ ស្រដៀងគ្នានោះដែរ ពេលដែលការស្ទង់មតិថ្នាក់ជាតិមួយទៀតបានសូមដល់អ្នកឆ្លើយតបឲ្យពិពណ៌នាពីចំណាប់អារម្មណ៍របស់ពួកគេអំពីសាសនារបស់យើង នោះគ្មានមនុស្សណាម្នាក់ផ្ដល់យោបល់ពីគ្រិស្តសាសនាដើម ឬការស្ដារឡើងវិញនោះឡើយ ។[៨]

ការរកឃើញទាំងនេះរំឭកយើងថា យើងមិនត្រូវបណ្ដោយឲ្យពួកអ្នកផ្សព្វផ្សាយរបស់យើងចេះតែស្មានៗច្រើនពេកអំពីចំណេះដឹងពីជំនឿរបស់យើងនោះទេ ។ ពួកអ្នកទាំងឡាយដែលពួកគេបង្រៀនអាចធ្លាប់ឮពាក្យថា *មរមន* ប៉ុន្តែពួកអ្នកផ្សព្វផ្សាយសាសនាមិនត្រូវស្មានថា មនុស្សភាគច្រើនមានការយល់ដឹងពីគោលការណ៍ជាគោលៗពីជំនឿរបស់យើងនោះទេ ។

## II. យ៉ូសែប ស្ម៊ីធ បុរសដ៏អស្ចារ្យ

នេះជាគំនិតផ្ទាល់ខ្លួនមួយចំនួនរបស់ខ្ញុំអំពីជីវិតដ៏អស្ចារ្យរបស់យ៉ូសែប ស្ម៊ីធ ។[៩] យ៉ូសែប ស្ម៊ីធ ដែលខ្ញុំបានជួបនៅក្នុងការស្រាវជ្រាវផ្ទាល់ខ្លួនរបស់ខ្ញុំភាគច្រើនបំផុតគឺនៅរដ្ឋអិលលីណោយ ស.រ.អា. គឺជាបុរសនៅព្រំដែន—មានវ័យក្មេង មានមនោសញ្ចេតនា មានថាមពល ហើយគួរឲ្យស្រឡាញ់ និងងាយប្រាស្រ័យទាក់ទងដោយមនុស្សជុំវិញលោក ដែល

LEAVING EDEN, SAVIOR, និង BETWEEN HEAVEN AND EARTH, ដោយ ANNIE HENRIE NADER

ជាញឹកញាប់ពួកគេហៅលោកថា « បង/ប្អូនប្រុស យ៉ូសែប » ។ ភាពយុវវ័យដ៏សមគួររបស់លោកបានឈានដល់ការបម្រើរបស់លោកដែលបានព្យាករទុកជាមុនមកនោះ ។ លោកមានវ័យ ១៤ ឆ្នាំ នៅពេលមានការនិមិត្តដំបូង នៅវ័យ ២១ ឆ្នាំ ជាពេលលោកបានទទួលផ្ទាំងចំណារមាស ហើយនៅវ័យ ២៣ឆ្នាំជាពេលលោកបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ( ក្នុងរយៈពេលតិចជាង ៦០ថ្ងៃ ) ។

នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញារបស់យើង មានវិវរណៈច្រើនជាងពាក់កណ្ដាល ត្រូវបានប្រទានឲ្យតាមរយៈព្យាការី ខណៈលោកមានវ័យ២៥ ឆ្នាំ ឬក្មេងជាងនេះ ។ លោកមានវ័យ ២៦ ឆ្នាំពេលគណៈប្រធានទីមួយត្រូវបានរៀបចំឡើង ហើយមានវ័យតែ ៣៣ ឆ្នាំពេលលោកបានគេចពីការដាក់គុកនៅរដ្ឋមិសសួរី ហើយបន្តភាពដឹកនាំពួកបរិសុទ្ធវិញ ។ លោកមានវ័យតែ ៣៨ ឆ្នាំកន្លះប៉ុណ្ណោះ ពេលលោកត្រូវគេធ្វើឃាត ។

ក្នុងជីវិតដ៏ខ្លីរបស់លោក យ៉ូសែប ស្ម៊ីធ បានមានការរងទុក្ខវេទនាក្នុងជីវិតរមែងស្លាប់នេះច្រើនណាស់ ។ ពេលលោកមានវ័យប្រហែលប្រាំពីរឆ្នាំ លោកបានរងទុក្ខជាមួយនឹងការវះកាត់ជើងដែលឈឺចាប់យ៉ាងខ្លាំងក្រៃលែង ។ ដោយសារតែភាពក្រីក្រនៃគ្រួសារលោក លោកទទួលការអប់រំជាផ្លូវការតិចតួចប៉ុណ្ណោះ ហើយពេលជាយុវជន លោកត្រូវបង្ខំឲ្យធ្វើការជាច្រើនម៉ោងដើម្បីជួយផ្គត់ផ្គង់ដល់គ្រួសារ ។ លោកត្រូវបានគេវាយធ្វើបាបរាងកាយជាច្រើនដង ។ នៅកណ្ដាលនៃការព្យាយាមបំពេញទំនួលខុសត្រូវដ៏គួរឱ្យភ្ញាក់ផ្អើលនៃការហៅដ៏ពិសិដ្ឋរបស់លោក លោកត្រូវធ្វើការជាអ្នកចម្ការ ឬអ្នកលក់ដូរដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ។ លោកបានធ្វើការណ៍នេះដោយគ្មានអំណោយទានខាងវិញ្ញាណដែលគាំទ្រដល់លោកក្នុងការហៅជាព្យាការីរបស់លោកនោះឡើយ ។ ព្រះអម្ចាស់បានមានបន្ទូលប្រាប់លោកថា « ចំពោះកិច្ចការខាងសាច់ឈាមនោះអ្នកនឹងពុំមានកម្លាំងទេ ត្បិតកិច្ចការនេះពុំមែនជាការហៅរបស់អ្នកឡើយ » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ២៤:៩ ) ។

នៅក្នុងរឿងខាងវិញ្ញាណ យ៉ូសែប ស្ម៊ីធ ពុំមានអ្នកណាជាគំរូឲ្យលោករៀនតាមពីរបៀបដើម្បីធ្វើជាព្យាការី និងអ្នកដឹកនាំមួយរូបនោះទេ ។ លោកត្រូវតែពឹងផ្អែកទៅលើសហការីដែលពុំមានបទពិសោធន៍ ។ លោក និងពួកគេបានមានការលំបាក ហើយបានរៀនជាមួយគ្នា ។ យ៉ូសែបមានភាពរ៉ៃរហ័សខ្លាំងណាស់ក្នុងការទទួលបានចំណេះដឹង និងមានភាពចាស់ទុំឆាប់រហ័សផងដែរ ។ គ្មានការសង្ស័យទេថា លោកពិតជាមានអំណោយទានដ៏ពិសិដ្ឋ ។ ដូចដែលយើងនឹងនិយាយនៅសព្វថ្ងៃនេះថា លោក « ជាអ្នកសិក្សាបានលឿន » ។ លោកបានមានប្រសាសន៍ថា លោកត្រូវបានបង្រៀនដោយសារទូតស្ថានសួគ៌ និងដោយវិវរណៈផ្សេងៗទៀតមកពីព្រះ ហើយខ្ញុំជឿលោក ។

អំណោយទានផ្ទាល់ខ្លួនមួយរបស់លោកគឺបានបង្ហាញយ៉ាងច្បាស់ដោយក្ដីស្រឡាញ់ និងភក្ដីភាពនៃមនុស្សដ៏អស្ចារ្យទាំងឡាយដែលបានដើរតាមលោក ។ ពេលយ៉ូសែបបានអញ្ជើញអ្នកដើរតាមលោកឲ្យយកឈ្នះលើភាពមិនឥតខ្ចោះនៃជីវិតរមែងស្លាប់របស់ពួកគេ លោកពុំបានលើកខ្លួនលោកឲ្យខ្ពស់ជាងពួកគេឡើយ ហើយពួកគេស្រឡាញ់លោកដោយសារចរិតបែបនោះឯង ។ នៅក្នុងទេសនកថាមួយដែលយ៉ូសែបបានប្រកាសនៅមួយខែជាងមុនពេលលោកត្រូវគេធ្វើឃាត លោកបានប្រកាសថា « ខ្ញុំពុំដែលបានប្រាប់អ្នកថា ខ្ញុំល្អឥតខ្ចោះនោះទេ ប៉ុន្ដែពុំមានកំហុសណានៅក្នុងវិវរណៈទាំងឡាយដែលបានបង្រៀននោះឡើយ » ។[10] យ៉ូសែប ស្ម៊ីធ មាន « ចរិយាស្លូតសរាយ » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៨ ) ដែលធ្វើឲ្យគេស្រឡាញ់លោកស្ទើរតែគ្រប់ៗគ្នាដែលបានស្គាល់លោក ។ មានអ្នកស្គាល់លោកម្នាក់បាននិយាយថា « ក្ដីស្រឡាញ់ដែលពួកបរិសុទ្ធមានចំពោះលោកគឺហួសពីការបង្ហាញប្រាប់បាន » ។[11] ភាពជាដៃគូនៃមិត្តភក្ដិរបស់លោកគឺជាក្ដីរីករាយដល់យ៉ូសែបដែលបានឃើញការកសាងសង្គម និងស្ថាបនាសហគមន៍ជាគោលបំណងសំខាន់នៃដំណឹងល្អ ។

មានម្ដងខ្ញុំបានកត់សម្គាល់ថា ៖ « អស់មួយជីវិតរបស់លោក យ៉ូសែប ស្ម៊ីធ បានរស់នៅជិតព្រំដែន ជាកន្លែងដែលបុរសត្រូវមានកម្លាំងលើធម្មជាតិ ហើយជួនកាលប្រឆាំងគ្នាទៅវិញទៅមក ។ លោកគឺជាមនុស្សមាឌធំ រឹងមាំ ហើយសកម្មខាងរាងកាយ ។ លោកីរីករាយនឹងកីឡាប្រកួតប្រជែង រួមទាំងទាញដំបងផងដែរ—ជាការសាកល្បងកម្លាំង ( សូមមើល *History of the Church* ៥:៣០២ ) ។ បណ្ណសាររបស់យើងមាននូវការចងក្រងទុកអំពីល្បែងបោកចំបាប់របស់លោកជាមួយមិត្តភក្ដិ និងអ្នកស្គាល់គ្នាផ្សេងៗទៀត ។ នៅថ្ងៃបរិសុទ្ធមួយ លោក និងព្រិកហាំ យ៉ង់ បានផ្សព្វផ្សាយដល់ពួកបរិសុទ្ធនៅទីក្រុងរ៉ាមូស រដ្ឋអិលលីណោយ ដែលមានចំណាយធ្វើដំណើរប្រហែលជាចំណាយពេលមួយថ្ងៃពីទីក្រុងណៅវូ ។ នៅថ្ងៃចន្ទ ពីមុនចាកចេញពីទីក្រុងរ៉ាមូស យ៉ូសែបបានប្រកួតបោកចំបាប់នឹងបុរសម្នាក់ដែលគេហៅថា ‹ បងធំនៅទីក្រុងរ៉ាមូស › ( សូមមើល ទិនានុប្បវត្តិ យ៉ូសែប ស្ម៊ីធ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៨៤៣ ដែលបានកត់ត្រាដោយ វិលឡឺឌ រីឆាដ Joseph Smith Collection, LDS Church Archives ) ។ យ៉ូសែបបានផ្ដួលគាត់ ។ ខ្ញុំសប្បាយចិត្តដែលកាលវិភាគសន្និសីទបច្ចុប្បន្នរបស់យើងមិនផ្ដល់ឱកាសដល់សមាជិកក្នុងមូលដ្ឋានឲ្យប្រកួតសាកល្បងនឹងអ្នកមានសិទ្ធិអំណាចទូទៅដែលមកទស្សនកិច្ចតាមរបៀបនេះ » ។[12]

បុរសពីរបីនាក់បានក្លាយជាមុខព្រួញនៃការវាយប្រហារកាន់តែច្រើនលើបេសកកម្មរបស់ពួកគេ ឬការចងចាំរបស់ពួកគេជាងយ៉ូសែប ស្ម៊ីធ ។ ខ្ញុំបានសង្កេតលើការចោទប្រកាន់ទាំងនេះដោយការស្រាវជ្រាវផ្ទាល់ខ្លួននៅក្នុងកំណត់ត្រាដើមនៅក្នុងរដ្ឋអិលលីណោយ ជាកន្លែងដែលយ៉ូសែបបានរស់នៅក្នុងពេលប្រាំឆ្នាំចុងក្រោយនៃជីវិតរបស់លោក ។ ការចោទប្រកាន់មួយដូចនោះបានកើតឡើង ពេលយ៉ូសែប ស្ម៊ីធ ចៅហ្វាយក្រុង ហើយក្រុមប្រឹក្សាទីក្រុងណៅវូបានហាមប្រាមដល់ *Nauvoo Expositor* ជាសារព័ត៌មានប្រឆាំងមួយ ។



យ៉ូសែប ស្ម៊ីធ មាន វ័យ ២១ ឆ្នាំ ពេលលោកបានទទួលផ្ទាំងចំណារមាស ដែលកប់នៅភ្នំគូម៉ូរ៉ា ហើយមានវ័យតែ ២៣ ឆ្នាំពេលលោកបញ្ចប់ការបកប្រែព្រះគម្ពីរមរមន ។

រូបថតនៃភ្នំគូម៉ូរ៉ា ដោយ GEORGE EDWARD ANDERSON

ការហាមប្រាមនេះផ្ដោតទៅលើប្រទូសភាពទាស់នឹងសាសនាចក្រ ហើយដែលបាននាំឲ្យមានការធ្វើឃាតយ៉ូសែបតែម្ដង ។

អ្នកប្រវត្តិសាស្ត្រពួកបរិសុទ្ធថ្ងៃចុងក្រោយជំនាន់ដើម រួមទាំងអែលឌើរ ប៊ី. អេច. រ៉ូប៊ើត បានទទួលស្គាល់ថា ទង្វើរនេះគឺផ្ទុយពីច្បាប់ ។ ទោះយ៉ាងណា ពេលខ្ញុំធ្វើការស្រាវជ្រាវលើប្រធានបទនេះកាលជាសាស្ត្រាចារ្យផ្នែកច្បាប់វ័យក្មេង នោះខ្ញុំមានការភ្ញាក់ផ្អើលដែលរកឃើញមូលដ្ឋានច្បាប់មួយសម្រាប់ទង្វើបែបនេះនៅក្នុងច្បាប់នៃរដ្ឋអិលលីណោយក្នុងឆ្នាំ ១៨៤៤ ។ មានការហាមប្រាមជាច្រើនចំពោះសារព័ត៌មានលើព្រំដែនក្នុងគ្រាពីមុនសង្គ្រាមស៊ីវិល ។ ការធានាបាននូវសេរីភាពសារព័ត៌មាននៅក្នុងរដ្ឋធម្មនុញ្ញសហរដ្ឋមិនត្រូវបានប្រកាសឲ្យអនុវត្តចំពោះសកម្មភាពនានាក្នុងរដ្ឋាភិបាលនៃទីក្រុង និងរដ្ឋទេពរហូតទាល់តែឆ្នាំ ១៩៣១ ហើយពេលនោះមានតែដោយការបោះឆ្នោតប្រាំលើបួនរបស់តុលាការកំពូលសហរដ្ឋលើវិសោធនកម្មនៃរដ្ឋធម្មនុញ្ញដែលបានអនុម័តក្នុងឆ្នាំ ១៨៦៨ ប៉ុណ្ណោះ ។[១៣] មនុស្សម្នាក់គួរវិនិច្ឆ័យលើសកម្មភាពរបស់យ៉ូសែប ស្ម៊ីធ ដោយផ្អែកទៅលើមូលដ្ឋានច្បាប់ និងកាលៈទេសៈនៅជំនាន់លោក មិនមែននៅជំនាន់យើងទេ ។



JOSEPH SMITH, ដោយ WILLIAM WHITAKER

ជានិស្សិតនៅមហាវិទ្យាល័យឈីកាហ្គោ អ្នកប្រវត្តិសាស្ត្រ ម៉ារិន អេស. ហីល និងខ្ញុំបានចាប់អារម្មណ៍នឹងការពិតដែលមានគេដឹងតែបន្តិចបន្តួចថាមានបុរសប្រាំនាក់បានទៅកាន់អង្គជំនុំជម្រះនៅរដ្ឋអិលលីណោយអំពីឃាតកម្មនៃយ៉ូសែប ស្ម៊ីធ ។ អស់រយៈពេលជាង ១០ ឆ្នាំ យើងបានស្រាវជ្រាវរុករកតាមបណ្ណាល័យ និងបណ្ណាសារដ្ឋាននានាទូទាំងប្រទេសដើម្បីស្វែងរកគ្រប់ព័ត៌មានដែលនៅសេសសល់អំពីអង្គជំនុំជម្រះនៅឆ្នាំ ១៨៤៥ នេះ និងអស់អ្នកដែលចូលរួមក្នុងរឿងនេះ ។ សៀវភៅរបស់យើងបានរំឭកពីពាក្យសម្ដី និងសកម្មភាពរបស់ប្រជាជនរដ្ឋអិលលីណោយដែលបានស្គាល់យ៉ូសែប ស្ម៊ីធ ដោយផ្ទាល់—អ្នកខ្លះបានស្រឡាញ់លោក និងបានប្រថុយជីវិតរបស់ពួកគេជួយលោក ហើយអ្នកខ្លះទៀតដែលស្អប់លោក និងបានចូលរួមដាក់ផែនការសម្លាប់លោក ។ គ្មានអ្វីដែលបង្ហាញឲ្យឃើញនៅក្នុងការរកឃើញរបស់យើងនៅក្នុងកំណត់ត្រាដើមរបស់តុលាការ ឬនៅក្នុងសាក្សីនៅឯអង្គជំនុំជម្រះឲ្យបានវែងអន្លាយ ដែលឆ្លុះបញ្ចាំងពីភាពទុយ៌សលើបុរសដែលត្រូវបានគេធ្វើឃាតនោះឡើយ ។[១៤]

ការដែលអាចចូលទៅមើលកំណត់ត្រាតុលាការរដ្ឋអិលលីណោយបាន វាអាចដឹកនាំទៅកាន់តំបន់ស្រាវជ្រាវអំពីយ៉ូសែប ស្ម៊ីធ មួយផ្សេងទៀតដែលមិនធ្លាប់មាននរណាប៉ះពាល់ពីមុនមកនោះ ។ យ៉ូសែប អាយ. ប៊ិនលី ពេលនោះជានិសិត្សច្បាប់នៅឈីកាហ្គោ និងខ្ញុំបានរកឃើញកំណត់ត្រាជាច្រើនអំពីសកម្មភាពជំនួញរបស់យ៉ូសែប ស្ម៊ីធ ។ យើងបានសហការនិពន្ធអត្ថបទមួយលើប្រធានបទនេះដែលមានចំណងជើងថា *Brigham Young University Law Review* នៅឆ្នាំ ១៩៧៦ ។[១៥] នៅទសវត្សរ៍ឆ្នាំ ១៨៤០ បានកើតមាននូវគ្រាមួយដែលមានការធ្លាក់ចុះ និងសម្ពាធខាងហិរញ្ញវត្ថុនៅទូទាំងប្រទេស ។ ស្ថានភាពសេដ្ឋកិច្ចនៅក្នុងរដ្ឋតាមព្រំដែនដូចជារដ្ឋអិលលីណោយ បានមានការខូចខាតជាដំណំ ។ ឧទាហរណ៍ អ្នកនិពន្ធជីវប្រវត្តិរបស់ អ័ប្រាហាំ លីងខុន បានរៀបរាប់អំពីរឿងអាម៉ាស់ផ្នែកហិរញ្ញវត្ថុរបស់

| អាយុ ៖ | ព្រឹត្តិការណ៍ ៖ |
|---|---|
| ១៤ | ការនិមិត្តដំបូង |
| ២១ | ផ្ទាំងចំណារមាស |
| ២៣ | បានបកប្រែព្រះគម្ពីរមរមន បានចប់សព្វគ្រប់ |
| ២៥ | ទទួលបានវិវរណៈបានពាក់កណ្ដាលនៅក្នុងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា |
| ២៦ | បានរៀបចំគណៈប្រធានទីមួយ |
| ៣៣ | រត់គេចចេញពីគុកនៅរដ្ឋមិសសួរី បានបង្កើតថ្នាក់ដឹកនាំជាថ្មី |
| ៣៨ | ត្រូវបានគេធ្វើទុក្ករកម្ម |

លោកអំឡុងពេលទសវត្សនេះ ពេលដែលជំនួញជួបគ្រោះថ្នាក់ កាតព្វកិច្ចជាច្រើនមានការយឺតយ៉ាវ ហើយបណ្ដឹងកើតមានឡើងជាញឹកញាប់ ។[១៦]

សត្រូវរបស់យ៉ូសែប ស្ម៊ីធ បានចោទលោកថាធ្វើការក្លែងបន្លំកាត់ឈ្មោះទ្រព្យសម្បត្តិនានា ដែលភាគច្រើនធ្វើឡើងក្នុងនាមឲ្យសាសនាចក្រ ។ ដំណើរមានតៗគ្នានៃទម្រង់ការតុលាការដែលបានបន្តអស់ជិតមួយទសវត្ស បានពិនិត្យមើលការចោទប្រកាន់ទាំងនេះនៅក្នុងភាពពិស្ដារយ៉ាងផ្ចិតផ្ចង់ ។ នៅទីបំផុតក្នុងឆ្នាំ ១៨៥២ ជាយូរក្រោយមកបន្ទាប់ពីការចាកចេញរបស់ពួកបរិសុទ្ធពីរដ្ឋអិលលីណោយ ( ដូច្នេះពុំមានអ្នកនយោបាយ ឬបុព្វហេតុណាផ្សេងទៀតដែលជួយដល់ពួកបរិសុទ្ធ ឬអ្នកដឹកនាំរបស់ពួកគេទៀតទេ ) ចៅក្រមកណ្ដាលក៏បានសម្រេចក្ដីលើបណ្ដឹងនេះជាមួយនឹងវិក្រឹត្យការថា ពុំមានការរកឃើញការក្លែងបន្លំ ឬអំពើខុសឆ្គងខាងសីលធម៌ណាផ្សេងទៀតដែលធ្វើឡើងដោយយ៉ូសែប ស្ម៊ីធ ឡើយ ។[១៧]

អ្នកប្រាជ្ញទាំងឡាយដែលមានចំណេះដឹងអំពីបញ្ហាសាធារណៈនៅក្នុងគ្រានេះ បានសរសេរបែបនេះអំពីយុទ្ធនាការរបស់យ៉ូសែប ស្ម៊ីធ សម្រាប់បេក្ខភាពប្រធានាធិបតេយ្យសហរដ្ឋ ៖


THE PROPHET.

SATURDAY MORNING, JUNE 22, 1844.

SUPER HANC PETRAM ÆDIFICABO.

FOR PRESIDENT,

GEN. JOSEPH SMITH,

OF NAUVOO, ILLINOIS.

FOR VICE PRESIDENT,

SIDNEY RIGDON,

OF PENNSYLVANIA.

*យ៉ូសែប ស្ម៊ីធ បានឈរឈ្មោះធ្វើជាប្រធានាធិបតីនៃសហរដ្ឋអាមេរិកនៅក្នុងឆ្នាំ ១៨៤៤ ។ លិខិតបណ្ណនេះប្រកាសពីប្រសាសន៍ដែលលោកត្រូវបានណាត់ដើម្បីឡើងថ្លែងសុន្ទរកថានៅប្រាំថ្ងៃពីមុនគេធ្វើឃាតលោក ។*


រូបថតផ្ទៃខាងក្រោយ ដោយ GEORGE EDWARD ANDERSON

« ខណៈដែលលោកអាចនឹងពុំមានឱកាសប្រាកដប្រជាក្នុងការឈ្នះការបោះឆ្នោតជាតិឆ្នាំ ១៨៤៤ ក្ដី ក៏លោកបានធ្វើយុទ្ធនាការយ៉ាងវាងវៃជាបេក្ខភាពរបស់គណបក្សទីបី ដែលពិតជាមានភាពប្រាកដប្រជាខ្លាំងណាស់ក្នុងការជំរុញឲ្យមានការកែទម្រង់ច្បាប់នៅក្នុងសហរដ្ឋ ។ លោកបានសង្ឃឹមហើយបានធ្វើកិច្ចការដើម្បីធ្វើឲ្យគំនិតសាធារណៈមានការប្រសើរឡើងលើបញ្ហាសំខាន់ៗរួមមាន ទាសភាព សេរីភាពសាសនា ពន្ធនាគារ និងដីធ្លីសាធារណៈ ។ លោក និងរបើ៊ត ហ្វេស. ឃិននិឌី ជនជាតិអាមេរិកតែពីរនាក់គត់ដែលត្រូវបានធ្វើឃាតខណៈពេលដែលពួកលោកនៅជាបេក្ខភាពសម្រាប់តំណែងប្រធានាធិបតីសហរដ្ឋអាមេរិក » ។[១៨]

លក្ខណៈសម្បត្តិរបស់យ៉ូសែប ស្ម៊ីធ ប្រហែលជាអាចយល់បានច្បាស់បំផុតដោយបុរសទាំងឡាយដែលស្គាល់លោកច្បាស់បំផុត និងអ្នកដែលបានឈរជិតលោកបំផុតនៅក្នុងថ្នាក់ដឹកនាំសាសនាចក្រ ។ ពួកគេគោរពស្រឡាញ់លោក និងគាំទ្រលោកជាព្យាការីមួយរូប ។ « បងប្រុសរបស់លោកហៃរ៉ុម បានសុខចិត្តស្លាប់នៅក្បែរលោក ។ យ៉ូហាន ថេលើរ ក៏នៅជាមួយនឹងលោកដែរ នៅពេលលោកត្រូវបានគេសម្លាប់នោះ បានមានប្រសាសន៍ ៖ ‹ ខ្ញុំថ្លែងទីបន្ទាល់ចំពោះមុខព្រះ ទេវតា និងមនុស្សទាំងឡាយថា លោកគឺជាបុរសដ៏ល្អ មានកិត្តិយសប្រកបដោយគុណធម៌ម្នាក់ . . .—ថាលក្ខណៈឯកជន និងទូទៅរបស់លោកគ្មានមន្ទិលសង្ស័យនោះទេ—ហើយថាលោកបានរស់នៅ និង ស្លាប់ក្នុងនាមជាបុរសម្នាក់នៃព្រះ › ( *The Gospel Kingdom* [ ឆ្នាំ ១៩៨៧ ] ទំព័រ ៣៥៥; សូមមើលផងដែរ គ និង ស ១៣៥:៣ ) ។ ព្រិកហាំ យ៉ង់ បានប្រកាសថា ៖ ‹ ខ្ញុំមិនគិតថាមានបុរសណាម្នាក់ដែលរស់នៅលើផែនដីនេះ ដែលបានស្គាល់ [ យ៉ូសែប ស្ម៊ីធ ] ច្បាស់ជាងខ្ញុំឡើយ ហើយខ្ញុំនិយាយដោយមុតមាំ ដោយព្រះយេស៊ូវគ្រីស្ទបានទទួលយក ថាគ្មានបុរសណាល្អជាងនេះដែលធ្លាប់បានរស់នៅ ឬរស់នៅលើផែនដីនេះឡើយ › [ “Remarks,” *Deseret News,* ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៨៦២ ទំព័រ ៦៥ ] » ។[១៩]

## III. យ៉ូសែប ស្ម៊ីធ និងច្បាប់

ជាភស្ដុតាងច្បាស់ណាស់ចេញពីឧទាហរណ៍ទាំងឡាយដែលខ្ញុំបានថ្លែងរួចមកហើយនេះ ចំណាប់អារម្មណ៍ដ៏យូរអង្វែងរបស់ខ្ញុំទៅលើប្រវត្តិច្បាប់គឺរួមមានទាំងចំណាប់អារម្មណ៍ពិសេសលើអន្តរកម្មរបស់យ៉ូសែប ស្ម៊ីធ ជាមួយនឹងប្រព័ន្ធច្បាប់នៃសហរដ្ឋអាមេរិកនៅជំនាន់លោក ។ អ្នកប្រវត្តិសាស្ត្របានថ្លែងតាមទំនៀមថា យ៉ូសែប ស្ម៊ីធ ជាបុគ្គលមួយរូបដែលជាប់ពាក់ព័ន្ធនឹងសកម្មភាពផ្លូវច្បាប់មិនលើសពី ៤០ សកម្មភាពនោះទេ ។ សព្វថ្ងៃនេះជាមួយនឹងអត្ថប្រយោជន៍នៃកិច្ចការដែលបានធ្វើចំពោះ *The Joseph Smith Papers* យើងដឹងថាតួលេខគឺច្រើនជាង ២២០ ។ សកម្មភាព

ផ្លូវច្បាប់ទាំងនេះរាប់ « ពីករណីប្រមូលផ្ដុំធម្មតាទៅដល់បញ្ហាស្មុគស្មាញ [ បណ្ដឹងវិវាទ ] ដែលរួមមានទ្រឹស្ដីច្បាប់ស្មុគស្មាញ ។ . . . យ៉ូសែបបានរក្សាទំនាក់ទំនងជាមួយមេធាវីជាច្រើនដើម្បី . . . នាំទៅការពារសកម្មភាព [ បែបនេះ ] . . . ទាំងបញ្ហាស៊ីវិល និងបទឧក្រិដ្ឋ » ។[២០]

ដោយទាញយកពីចំណេះដឹងដ៏អស្ចារ្យសម្បូរបែបអំពីជីវិតរបស់ព្យាការីនោះយើងមានអ្នកប្រាជ្ញពួកបរិសុទ្ធថ្ងៃចុងក្រោយ ជេហ្វ្រី អិន. វ៉កឃើរ ដែលបានសរសេរថា ៖ « ដោយមិនអាចបដិសេធបាន យ៉ូសែប ស្ម៊ីធ បានចូលរួមក្នុងប្រព័ន្ធច្បាប់របស់អាមេរិកយ៉ាងជិតស្និត យ៉ាងសកម្ម និងដោយជាប់លាប់ ។ ការមិនអើពើនឹងសកម្មភាពដ៏សំខាន់ទាំងនេះ គឺជាការខកខានមិនបានដឹងនូវរបៀបជាច្រើនដែលលោកបានចំណាយពេល និងថាមពលរបស់លោកយ៉ាងចំណាន និងមានប្រសិទ្ធភាព—ច្រើនណាស់ ដែល ដានីយ៉ែល អេច. វែលស៍ ខ្លួនលោកផ្ទាល់ដែលជាអ្នកច្បាប់ ចៅក្រម និងជាមេធាវីទូទៅមួយរូបដែលបានស្គាល់ស្ម៊ីធយ៉ាងច្បាស់ បានមានយោបល់ថា ៖ ‹ ខ្ញុំបានស្គាល់អ្នកច្បាប់ទាំងឡាយអស់មួយជីវិតខ្ញុំ ។ យ៉ូសែប ស្ម៊ីធ ជាអ្នកច្បាប់ដ៏ល្អបំផុតដែលខ្ញុំធ្លាប់ស្គាល់ក្នុងជីវិតខ្ញុំ › [ ដូចដែលបានដកស្រង់នៅក្នុង *The Journal of Jesse Nathaniel Smith: Six Decades in the Early West: Diaries and Papers of a Mormon Pioneer,* ឆ្នាំ ១៨៣៤–១៩០៦ ( ឆ្នាំ ១៩៥៣ ) ទំព័រ ៤៥៦ ] » ។[២១]

អ្នកនិពន្ធពួកបរិសុទ្ធថ្ងៃចុងក្រោយបីរូបធ្វើការសង្ខេបដូចតទៅនេះ ៖ « ជាមួយនឹងការចូលរួមដ៏ខ្លាំងក្លារបស់លោកក្នុងប្រព័ន្ធច្បាប់ លោកស្ម៊ីធបានរៀនយ៉ាងឆាប់រហ័សពីវិន័យរបស់ល្បែងនេះ ហើយបានប្រើប្រាស់វិន័យទាំងនោះដោយស្របច្បាប់ឲ្យពេញប្រយោជន៍ដោយស្របច្បាប់ ដោយពុះពារប្រើប្រាស់យ៉ាងពេញលេញនូវឱកាស និងការការពារថ្មីៗដែលផ្ដល់ឲ្យដោយច្បាប់ប្រទេសដ៏ក្មេងខ្ចីនេះ ។ ជម្រើស និងការប្រព្រឹត្តខាងច្បាប់របស់លោក ធ្វើឲ្យឃើញច្បាស់ថាលោកទទួលព័ត៌មានបានយ៉ាងល្អអំពីបញ្ហាផ្លូវច្បាប់ ហើយថាលោកបានបោះជំហានយ៉ាងច្បាស់លាស់ដើម្បីប្រើប្រាស់របៀបដ៏ត្រឹមត្រូវដែលត្រូវបានអនុញ្ញាតដោយច្បាប់ មិនថាពេលលោកព្យាយាមទទួលបាននូវការរក្សាសិទ្ធិសម្រាប់ព្រះគម្ពីរមរមននៅក្រោមច្បាប់រដ្ឋ, រៀបចំអាពាហ៍ពិពាហ៍ក្រោមច្បាប់រដ្ឋអូហៃអូ, រៀបចំពិធីបរិសុទ្ធនៅណៅវូ, អំពាវនាវឲ្យមានការការពារពេញលេញដល់សេរីភាពសាសនា, ធ្វើឲ្យមានការប្រើប្រាស់ច្បាប់ថ្មីៗដែលគ្រប់គ្រងដីធ្លីរដ្ឋដោយមានប្រសិទ្ធភាព, គាំទ្រសិទ្ធិមនុស្សម្នាក់ដែលត្រូវបានគេចាប់ខ្លួនថាមិនគួរត្រូវបានដាក់គុកយូរជាងពេលវេលាជាក់លាក់មួយលើកលែងតែចៅក្រមបានកាត់ក្ដីបែបនោះ, តម្រូវឲ្យមានយុត្តាធិការសមរម្យ, ឬដាក់ស្នើយកការការពារនៅក្រោមច្បាប់ក្ស័យធនដែលទើបនឹងអនុម័តថ្មីៗក្ដី ។ នៅក្នុងពេលទំនេររបស់លោក លោកសិក្សាសៀវភៅច្បាប់ ។ លោកបានដឹងពាក្យពេចន៍ច្បាស់លាស់នៃរដ្ឋធម្មនុញ្ញ និងភាសាច្បាប់ត្រឹមត្រូវនៃលក្ខន្តិកៈរបស់រដ្ឋ ។ គ្មានការសង្ស័យទេថាលោកបានដឹងយ៉ាងច្បាស់នូវការអភិវឌ្ឍខាងច្បាប់ជាច្រើននៅកម្រិតរដ្ឋ និងសហព័ន្ធនៅក្នុងជីវិតលោក » ។[២២]



ពិតជាសំខាន់ដែលអ្នកនិពន្ធទាំងបីនាក់នោះបន្ថែមសេចក្ដីថ្លែងនេះ ៖ « ក្នុងនាមជាចុងចោទម្នាក់ លោកមិនដែលត្រូវបានផ្ដន្ទាទោសដោយសារបទល្មើសឧក្រិដ្ឋណាឡើយ ។ ពេលណាដែលលោកត្រូវបានផ្ដល់ឲ្យនូវសវនាការដ៏យុត្តិធម៌ នោះលោកត្រូវបានគេរកឃើញថាជាពលរដ្ឋសុចរិត និងទៀងត្រង់មួយរូប » ។[២៣]

ការសង្ខេបដ៏ពិស្ដារនៃបណ្ដឹងវិវាទរបស់ព្យាការីដែលត្រូវបានជ្រើសរើស និងវិភាគនៅក្នុងសៀវភៅនោះដែលខ្ញុំបានដកស្រង់គឺផ្អែកលើកិច្ចការដ៏សន្ធឹកសន្ធាប់ដែលនិស្សិតច្បាប់ លោក ជេ. រូបឹន ក្លាក ដែលបានសិក្សាលើប្រធានបទនោះ ហើយបានធ្វើកិច្ចការយ៉ាងពិស្ដារដែលដឹកនាំទៅកាន់សៀវភៅដែលនិពន្ធដោយអ្នកនិពន្ធបីរូបនេះ ។ ខ្ញុំមានការទាក់ចិត្តជាខ្លាំងនឹងការពិពណ៌នានៃគំនិតរបស់និស្សិតច្បាប់ទាំងនេះ ៖

« និស្សិតច្បាប់ដែលបានប្រើប្រាស់ច្បាប់ថ្មីពីមុននៃសៀវភៅនេះជាសៀវភៅសិក្សារបស់ពួកគេ បានមានគំនិតមិនផ្លាស់ប្ដូរថា យ៉ូសែបមានការទទួលខុសត្រូវ, ស្មោះត្រង់, ប្រុងប្រយ័ត្ន, មានក្ដីមេត្តា, ល្អិតល្អន់, គោរពច្បាប់, អត់ធ្មត់, វិជ្ជមាន,

« យ៉ូសែប ស្ម៊ីធ ជាអ្នកច្បាប់ដ៏ល្អបំផុតដែលខ្ញុំធ្លាប់ស្គាល់ក្នុងជីវិតខ្ញុំ »
*—អែលឌើរ ដានីយ៉ែល អេច វែលស៍ អគ្គមេធាវីប្រចាំរដ្ឋយូថា*



*JOSEPH SMITH THE PROPHET,* ដោយ DAN WEGGELEND, ទទួលបានសិទ្ធិអនុញ្ញាតពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ



ប្រកបដោយធនធាន, វាងវៃ, យល់ដឹង, មានលក្ខណៈវិនិច្ឆ័យល្អ, និងពូកែផ្នែកច្បាប់ ( ប្រើពាក្យសម្ដីផ្ទាល់របស់ពួកគេ ) ជាពិសេសពេលវាទាក់ទងនឹងការការពារសាសនា និងសិទ្ធិស៊ីវិលរបស់អ្នកដទៃទៀត ឬបំពេញភារកិច្ចដែលគាត់ត្រូវបានប្រគល់ឱ្យ ។ . . . យ៉ូសែប ស្ម៊ីធ មិនដែលបាត់បង់សេចក្ដីជំនឿលើរដ្ឋធម្មនុញ្ញនោះទេ ហើយបានពុះពារធ្វើកិច្ចការយ៉ាងមាំមួននៅក្រោមការឧបត្ថម្ភគាំទ្រវា សូម្បីលោកមានចិត្តធុញថប់ ខកចិត្ត និងការប្រុងប្រយ័ត្នចំពោះមនុស្សដែលផ្ដល់ការបម្រើសេវានេះក្ដី » ។[២៤]

## IV. សេចក្ដីបញ្ចប់

នៅក្នុងជីវិតលោក យ៉ូសែប ស្ម៊ីធ សម្រេចបានច្រើនជាងមនុស្សរមែងស្លាប់ណាៗទាំងអស់អាចសម្រេចបាននៅក្នុងរយៈពេលដ៏ខ្លី ។ ការពន្យល់តែមួយដែលអាចមានគឺទទួលជំនួយពីស្ថានសួគ៌ ។ ខ្ញុំចូលចិត្តការសង្ខេបនេះ ៖

« លោកបានបកប្រែ និងបោះពុម្ពព្រះគម្ពីរមរមននៅក្នុងទីក្រុងនូវយ៉ោក, បានរៀបចំសាសនាចក្រនៅក្នុងទីក្រុងនូវយ៉ោក, ហើយបន្ទាប់មកបានតាំងទីលំនៅនៅអូហៃអូ មិសសួរី និងអិលលីណោយម្ដងទៀត, បានស្ថាបនាទីក្រុងទាំងឡាយ រួមមាន ខឺឡង់ ហ្វារវែស្ទ និងណៅវូ, បានហៅ និងបង្ហាត់បង្រៀនដល់អ្នកដឹកនាំសាសនារាប់រយនាក់, បានសិក្សាភាសាហេព្រើរ និងគម្ពីរប៊ីប, បានបង្កើតសមាគមសង្គ្រោះនៅណៅវូ, បានធ្វើជំនួញជាលក្ខណៈឯកជន និងជាដៃគូរច្រើន, បានបង្កើតអចលនទ្រព្យ និងកសាងព្រះវិហារបរិសុទ្ធ, បានសរសេរ និងបោះពុម្ពអត្ថបទ និងវិចារណកថានានា, មានក្រុមគ្រួសារដ៏ធំ ហើយបានស្រឡាញ់រាប់អានមិត្តភក្ដិជាច្រើន ហើយបានបម្រើក្នុងសមាសភាពស៊ីវិលមួយចំនួន រួមមានកងមេបញ្ជាការនៃកងជីវពលបុរសមួយកងដ៏ធំ, ក៏ដូចជាបានធ្វើជាចៅហ្វាយក្រុង និងមេចៅក្រមនៃទីក្រុងណៅវូផងដែរ ។ លោកបានថ្លែងជាប្រចាំនៅក្នុងការថ្វាយបង្គំ, ការឧទ្ទិសប្រចាំសប្ដាហ៍ និងនៅឯពិធីបុណ្យសពដែលមានជាញឹកញាប់, លោកបានទាក់ទាញជនដែលមានសេចក្ដីជំនឿរាប់ពាន់នាក់ បំផុសឲ្យមានកំណើនអ្នកប្រែចិត្តជឿឲ្យធ្វើអន្តោប្រវេសន៍មកសហរដ្ឋ » ។[២៥]

នៅក្នុងសុន្ទរកថាសន្និសីទទូទៅមួយដែលបានថ្លែងកាលពីជាង ២០ឆ្នាំមុន ខ្ញុំបាននិយាយថា ៖

« ដូចជាពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់ដទៃទៀតដែរ ខ្ញុំបានស្ថាបនាជីវិតរបស់ខ្ញុំលើទីបន្ទាល់ និងបេសកកម្មរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ។ នៅក្នុងការអាន និងការស្រាវជ្រាវដើមរបស់ខ្ញុំ ខ្ញុំមិនដែលបានបដិសេធទីបន្ទាល់របស់ខ្ញុំអំពីការហៅជាព្យាការីរបស់លោក និងនៃដំណឹងល្អ ព្រមទាំងការស្ដារឡើងវិញនៃបព្វជិតភាពដែលព្រះអម្ចាស់បានចាប់ផ្ដើមតាមរយៈលោកនោះឡើយ ។ ខ្ញុំសូមអះអាងដោយរឹងមាំពីទីបន្ទាល់ដែលយ៉ូសែប ស្ម៊ីធ បានបង្ហាញនៅក្នុងសំបុត្រជូនលោកវ៉េនវ៉ឺធដ៏ល្បីល្បាញនៅឆ្នាំ ១៨៤២ ៖

« ‹ . . . បទដ្ឋាននៃសេចក្ដីពិតត្រូវបានបង្កើតឡើង គ្មានដៃដែលមិនស្អាតស្អំណា អាចបញ្ឈប់កិច្ចការនេះពីការរីកចម្រើនឡើយ ការបៀតបៀនអាចកញ្ជ្រោលឡើង ពួកមនុស្សកំណាចអាចប្រមូលផ្ដុំគ្នា ពួកទាហានអាចប្រជុំគ្នា ពួកអ្នកមួលបង្កាច់អាចបង្ខូចកេរ្ដិ៍ឈ្មោះ តែសេចក្ដីពិតនៃព្រះនឹងឆ្ពោះទៅមុខដោយក្លៀវក្លា ថ្លៃថ្នូរ និង ឯករាជ្យរហូតទាល់តែវាបានដល់គ្រប់ទាំងទ្វីប គ្រប់តំបន់ គ្រប់ប្រទេស និង បានឮដល់គ្រប់ត្រចៀក រហូតដល់គោលបំណងនៃព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏មហិមានឹងមានបន្ទូលថា កិច្ចការបានចប់សព្វគ្រប់ហើយ › (*Times and Seasons,* ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៨៤២ ទំព័រ ៧០៩; ការដកស្រង់នៅក្នុង Daniel H. Ludlow, ed., *Encyclopedia of Mormonism,* វ៉ុល ៥ [ ឆ្នាំ ១៩៩២ ], ៤:១៧៥៤ ) » ។[២៦]

បងប្អូនប្រុសស្រី ខ្ញុំសូមថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ព្រះអង្គសង្គ្រោះរបស់យើង ដែលបានយាងមកជាមួយនឹងព្រះវរបិតា ដើម្បីជួបនឹងព្យាការីវ័យក្មេង ដែលព្រះវរបិតាបានមានព្រះបន្ទូល ៖ « *នេះជាព្រះរាជបុត្រាដ៏ស្ងួនភ្ងារបស់យើង ។ ចូរស្ដាប់ទ្រង់ចុះ !* » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៧ ) ។ យើងបានឮព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើងនៅក្នុងវិវរណៈចាប់តាំងពីពេលនោះមក ។ នេះគឺជាសាសនាចក្ររបស់ទ្រង់ ។ យើងជាអ្នកកាន់សិទ្ធិអំណាចនៃបព្វជិតភាពដ៏បរិសុទ្ធរបស់ទ្រង់ ។ យើងដើរឆ្ពោះទៅមុខនៅក្នុងបុព្វហេតុរបស់ទ្រង់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់អំពីការហៅរបស់ព្យាការីយ៉ូសែប ស្ម៊ីធ និងអំពីការហៅរបស់ពួកព្យាការីទាំងឡាយដែលបានស្នងតំណែងពីលោកនៅក្នុងកិច្ចការដ៏អស្ចារ្យនេះដែលអ្នកបានចូលរួម ។ ■

*ដកស្រង់ចេញពីសុន្ទរកថា « យ៉ូសែប ស្ម៊ីធ ៖ ព្យាការី និងបុរសដ៏អស្ចារ្យ » ដែលបានថ្លែងនៅឯសិក្ខាសាលាថ្នាក់ដឹកនាំបេសកកម្ម នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៨ ។*

*ព្យាការី យ៉ូសែប ស្ម៊ីធ មានវ័យ ៣៨ ឆ្នាំ ពេលលោកត្រូវគេធ្វើទុក្ករកម្មជាមួយនឹងបងប្រុសលោកគឺហៃរុម នៅឯគុកកាតធេច នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៨៤៤ ។*





« សេចក្ដីពិតនៃព្រះនឹងឆ្ពោះទៅមុខដោយក្លៀវក្លា ថ្លៃថ្នូរ និង ឯករាជ្យរហូតទាល់តែវាបានដល់គ្រប់ទាំងទ្វីប គ្រប់តំបន់ គ្រប់ប្រទេស និង បានឮដល់គ្រប់ត្រចៀក រហូតដល់គោលបំណងនៃព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏មហិមានឹងមានបន្ទូលថា កិច្ចការបានចប់សព្វគ្រប់ហើយ » ។

*—Joseph Smith, នៅក្នុងសំបុត្រជូនលោកវ៉េន្តវើធ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៨៤២*

**កំណត់ចំណាំ**

១. រ័សុល អិម ណិលសុន *Accomplishing the Impossible* ( ឆ្នាំ ២០១៥ ) ទំព័រ ១–២ ។
២. « សរសើរដល់លោក » *ទំនុកដំកើងព្រះ* លេខ ១៦ ។
៣. សូមមើល *ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ ២០០៤ ) ទំព័រ ៣៧ ។
៤. Richard Lyman Bushman, *Joseph Smith: Rough Stone Rolling* ( ឆ្នាំ ២០០៥ ) ទំព័រ ១០៥ ។
៥. រ័សុល អិម ណិលសុន នៅក្នុង Sarah Jane Weaver, « President Nelson Shares the ‹ Hopes of My Heart › with New Mission Leaders, » *Church News,* ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ news.lds.org ។
៦. *ប្រកាសដំណឹងល្អយើង* ទំព័រ ១០៣ សូមមើលផងដែរបុព្វកថានៃព្រះគម្ពីរមរមន ។
៧. Gary C. Lawrence, *How Americans View Mormonism: Seven Steps to Improve Our Image* ( ឆ្នាំ ២០០៨ ) ទំព័រ ៣២ ។
៨. សូមមើល Gary C. Lawrence *How Americans View Mormonism* ទំព័រ ៤២ ។
៩. ផ្នែកនេះនៅក្នុងអត្ថបទនៅកំណត់ចំណាំទី ១០ ត្រូវបានកែសម្រួលមកពី ដាល្លិន អេក អូក « Joseph Smith in a Personal World, » នៅក្នុងកំណែរបស់ John W. Welch, *The Worlds of Joseph Smith: A Bicentennial Conference at the Library of Congress* ( ឆ្នាំ ២០០៦ ) ទំព័រ ១៥៩ ។
១០. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ ២០០៧ ) ទំព័រ ៥២២ ។
១១. Mary Alice Cannon Lambert, នៅក្នុង « Joseph Smith, the Prophet, » *Young Woman's Journal,* ខែ ធ្នូ ឆ្នាំ ១៩០៥ ទំព័រ ៥៥៤ ។
១២. ដាល្លិន អេក អូក «The Relief Society and the Church» *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៧២ ។
១៣. សូមមើល ដាល្លិន អេក អូក « The Suppression of the *Nauvoo Expositor*, » *Utah Law Review,* វ៉ុល ៩ លេខ ៤ ( ឆ្នាំ ១៩៦៥ ) ទំព័រ ៨៦២–៩០៣ ។
១៤. សូមមើល Dallin H. Oaks and Marvin S. Hill, *Carthage Conspiracy: The Trial of the Accused Assassins of Joseph Smith* ( ឆ្នាំ ១៩៧៥ ) ។
១៥. សូមមើល Dallin H. Oaks and Joseph I. Bentley, « Joseph Smith and Legal Process: In the Wake of the Steamboat Nauvoo, » *BYU Law Review,* វ៉ុល ១៩៧៦, លេខ ៣ ( ឆ្នាំ ១៩៧៦ ) ទំព័រ ៧៣៥–៨២ ។
១៦. សូមមើល David Herbert Donald, *Lincoln* ( ឆ្នាំ ១៩៩៥ ) ទំព័រ ៩៤–១១៨ ។
១៧. សូមមើល Dallin H. Oaks and Joseph I. Bentley, « Joseph Smith and Legal Process, » ទំព័រ ៧៨១ ។
១៨. Gordon A. Madsen, Jeffrey N. Walker, and John W. Welch, eds., *Sustaining the Law: Joseph Smith's Legal Encounters* ( ឆ្នាំ ២០១៤ ) ទំព័រ x–xi ។
១៩. ដាល្លិន អេក អូក « Joseph, the Man and the Prophet » ទំព័រ ៧៣ ។
២០. Jeffrey N. Walker in Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ vi ។
២១. Jeffrey N. Walker in Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ vii ។
២២. Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ xvii ។
២៣. Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ xvii–xviii ។
២៤. Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ xviii ។
២៥. Gordon A. Madsen and others, eds., *Sustaining the Law,* ទំព័រ xi–xii ។
២៦. ដាល្លិន អេក អូក « Joseph, the Man and the Prophet » ទំព័រ ៧៣ ។

# សាសនាគន់ការីធ្លាក់ពីលើចុងឈើ

ចំពោះអ្នកផ្សព្វផ្សាយវ័យក្មេងពីរនាក់ដែលផ្សព្វផ្សាយនៅតាមដងផ្លូវនៃទីក្រុងប៊ុយណូស៊ែ ប្រទេសអាហ្សង់ទីន ក្នុងឆ្នាំ ១៩៩៥ នោះការសន្យាដែលពួកគេបានទទួលមកពីសមាជិកម្នាក់ក្នុងគណៈប្រធានតំបន់ ដែលហាក់ដូចជាចម្លែក ៖ « ប្រសិនបើអ្នកខិតខំធ្វើការ ហើយគោរពប្រតិបត្តិទាំងស្រុង នោះសាសនាគន់ការីនឹងធ្លាក់ពីលើចុងឈើមកដើម្បីទទួលបុណ្យជ្រមុជទឹក » ។ មិនយូរប៉ុន្មានក្រោយមក យើងបានយល់អំពីការសន្យានោះ ។

ឪពុករបស់ខ្ញុំកំពុងកាត់តម្រឹមដើមឈើនៅតាមចិញ្ចឹមផ្លូវនៅខាងមុខផ្ទះរបស់យើង ។ នៅពេលដែលគាត់បានឡើងដើមឈើនោះដើម្បីកាត់តម្រឹមវា គាត់បានឃើញយុវជនពីរនាក់ដើរតម្រង់មករកគាត់នៅតាមផ្លូវ ។ នៅពេលពួកគេដើរកាត់ក្រោមដើមឈើនោះ គាត់បានហៅពួកគេពីលើចុងឈើដោយប្រើភាសាអង់គ្លេស ។

ឪពុករបស់ខ្ញុំពុំសូវចេះនិយាយភាសាអង់គ្លេសទេ ប៉ុន្តែគាត់ចេះពីរបីពាក្យ ហើយគាត់ចង់ចេះចង់ដឹង ។ តើយុវជនទាំងពីរនាក់នោះជានរណា ហើយពួកគេកំពុងធ្វើអ្វីនៅក្នុងភូមិរបស់យើងនេះ ?

ពួកអ្នកផ្សព្វផ្សាយសាសនាបានឈប់ ហើយឆ្ងល់ថា សំឡេងនោះបន្លឺចេញមកពីណា ។ បន្ទាប់មកឪពុករបស់ខ្ញុំបានចុះពីចុងឈើនោះ ហើយនិយាយជាមួយពួកគេ ។ ដោយភ្ញាក់ផ្អើលចំពោះសារលិខិត និងអត្តចរិតរបស់ពួកគេ នោះគាត់បានអញ្ជើញពួកគេឲ្យចូលផ្ទះ ។

បទពិសោធន៍របស់ឪពុកខ្ញុំកាលពីមុនជាមួយផ្នែកសាសនាបានធ្វើឲ្យគាត់មានក្ដីអំពល់ ប៉ុន្តែសារលិខិតនៃដំណឹងល្អដែលបានស្ដារឡើងវិញនេះបានបំផុសដល់ចិត្តរបស់គាត់ ។ គាត់បានរស់នៅឆ្លងកាត់គ្រាដ៏លំបាកនានា ហើយគាត់បានដឹងថា គាត់ត្រូវការការផ្លាស់ប្ដូរ ។ គាត់បានស្ដាប់ដោយយកចិត្តទុកដាក់នៅពេលអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនគាត់ ម្ដាយខ្ញុំ ជីដូនរបស់ខ្ញុំ និងរូបខ្ញុំ ។

ខ្ញុំមានអាយុតែ ១១ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែសេចក្ដីពិតដែលពួកគេបង្រៀនក៏បំផុសគំនិតខ្ញុំ—ព្រមទាំងម្ដាយ និងជីដូនខ្ញុំដែរ ។ ជាលទ្ធផល ពួកយើងទាំងអស់គ្នាបានជ្រមុជទឹកនៅរយៈពេលពីរបីខែក្រោយមក គឺនៅខែកញ្ញាឆ្នាំ ១៩៩៥ ។

*នៅពេលដែលឪពុកខ្ញុំបានឡើងដើមឈើនោះដើម្បីកាត់តម្រឹមវា គាត់បានឃើញយុវជនពីរនាក់ដើរតម្រង់មករកគាត់នៅតាមផ្លូវ ។*



រចនាដោយ រ៉ូប៊ើត ក្រហ្វ៊ិត

មិនយូរប៉ុន្មានក្រោយមក គ្រាប់ពូជនៃសេចក្ដីជំនឿដែលពួកអ្នកផ្សព្វផ្សាយសាសនាបានដាំនៅក្នុងចិត្តរបស់យើងត្រូវបានចិញ្ចឹមបីបាច់ដោយការរាប់អានមកពីមិត្តភក្តិនៅព្រះវិហារ ក្រៅពីការបង្រៀនដំណឹងល្អ និងបទពិសោធន៍ល្អជាមួយថ្នាក់ដឹកនាំដ៏រឹងមាំរបស់សាសនាចក្រ ។ ដោយសារការស្វាគមន៍ដ៏កក់ក្ដៅដែលយើងបានទទួល នោះគ្រាប់ពូជនៃសេចក្ដីជំនឿរបស់យើង « ធ្លាក់ទៅក្នុងដីល្អ ក៏ពន្លកដុះឡើង បង្កើតផលផ្លែបានមួយជាមួយរយភាគ » ( លូកា ៨:៨ ) ។

ផលផ្លែនៃសេចក្ដីជំនឿរបស់យើងដែលយើងរីករាយនាពេលបច្ចុប្បន្ននេះ—គឺជិត ២៥ ឆ្នាំក្រោយមក—រួមទាំងការតាំងចិត្តដ៏រឹងប៉ឹងចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ចំពោះពរជ័យនៃព្រះវិហារបរិសុទ្ធ និងជីវិតដែលពេញលេញ និងរីករាយជាមួយនឹងជំនាន់ថ្មីមួយនៃសមាជិកគ្រួសារដែលរួបរួមគ្នាអស់កល្បជានិច្ច ។

យើងនឹងមានអំណរគុណជានិច្ចចំពោះអ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់ទាំងពីរនាក់នោះ ដែលបានដាក់ការសន្យាដ៏បំផុសគំនិតមួយឲ្យទៅជាការសាកល្បង ។ ■

**យ៉ាមីឡា កាមីណូស ទីក្រុងប៊ុយណូស៍ស៊ែ ប្រទេសអាហ្សង់ទីន**

# ចេញពីភាពភ័យខ្លាចទៅជាការទទួលទានអាហារដ៏ធំមួយ

ខ្ញុំសកម្មក្នុងសាសនាចក្រអស់ពេញជីវិតខ្ញុំ ។ ខ្ញុំបានបម្រើបេសកកម្មពេញម៉ោង បានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ហើយបានជួយចិញ្ចឹមកូនស្រីបួននាក់ដ៏អស្ចារ្យ ។ ប៉ុន្តែយូរៗទៅ ខ្ញុំបានកត់សម្គាល់ឃើញថា មិត្តភក្តិរបស់ខ្ញុំមួយចំនួនបានបោះបង់ចោលភាពជាសមាជិករបស់ពួកគេពីសាសនាចក្រ ។ សមាជិកគ្រួសារមួយចំនួនប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីសួរសំណួរ និងរិះគន់ថ្នាក់ដឹកនាំព្រះវិហារ ។ ហើយខ្ញុំក៏ចាប់ផ្ដើមមានមន្ទិលសង្ស័យអំពីសាសនាចក្រនៅក្នុងគ្រាដំបូងនៃជីវិតរបស់ខ្ញុំ ។ មន្ទិលសង្ស័យរបស់ខ្ញុំ បានបណ្ដាលឲ្យខ្ញុំភ័យខ្លាចនឹងអនាគត ។ ពេលខ្លះ ខ្ញុំមានអារម្មណ៍អស់សង្ឃឹម ។

អំឡុងគ្រាលំបាកនេះ ខ្ញុំបានបង្ខំចិត្តខ្លួនឯងដើម្បីចូលរួមសន្និសីទស្តេក ។ នៅពេលប្រធានស្តេកបាននិយាយគាត់បានថ្លែងថា « ប្រសិនបើយើងត្រូវរស់រានមានជីវិតនៅក្នុងគ្រាដ៏លំបាកនៅពេលខាងមុខ នោះយើងត្រូវចាកចេញពីការទទួលទានធម្មតារបស់យើង ទៅរកការទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទជាបន្ទាន់ ។ យើងត្រូវតែសិក្សាព្រះគម្ពីរឲ្យបានទៀងទាត់ ហើយផ្ដោតចិត្តលើការសិក្សាព្រះគម្ពីរ ដោយធ្វើឲ្យវាក្លាយជាអាទិភាពនៅក្នុងជីវិតរបស់យើង ។ ប្រសិនបើយើងធ្វើដូច្នេះ នោះខ្ញុំសន្យាថាយើងនឹងមិនភ័យខ្លាចឡើយ » ។

ខ្ញុំបានចាប់អារម្មណ៍នឹងពាក្យ « ភ័យខ្លាច » ។ ខ្ញុំបានដឹងថា ខ្ញុំបានបណ្ដោយឲ្យការសិក្សាដំណឹងល្អរបស់ខ្ញុំទៅជារឿងធម្មតា ។ ជាលទ្ធផល ភាពភ័យខ្លាចបានគ្រប់គ្រងជីវិតរបស់ខ្ញុំ ។ ខ្ញុំបានសម្រេចចិត្តព្យាយាមសាកល្បងតាមការទូន្មានរបស់ប្រធានស្តេករបស់ខ្ញុំ ។

ខ្ញុំបានទៅផ្ទះវិញ ហើយបានធ្វើកាលវិភាគសម្រាប់ការសិក្សាដំណឹងល្អ ។ នៅជ្រុងម្ខាងក្នុងបន្ទប់ ខ្ញុំបានដាក់តុតូចមួយជាមួយនឹងកៅអីដែលមានផាសុកភាពមួយ ។ ខ្ញុំបានព្យួររូបភាពព្រះអង្គសង្គ្រោះពីលើនៅលើជញ្ជាំង ។ ខ្ញុំបានប្រមូលព្រះគម្ពីររបស់ខ្ញុំ ខ្មៅដៃ និងសៀវភៅកំណត់ចំណាំមួយ ។ ខ្ញុំបានចាប់ផ្ដើមការសិក្សារបស់ខ្ញុំដោយការអធិស្ឋាន ។



*ខ្ញុំបានរៀបចំតុតូចមួយជាមួយកៅអីមួយដែលមានផាសុកភាព ហើយចាប់ផ្ដើមការសិក្សាដំណឹងល្អរបស់ខ្ញុំជាមួយនឹងការអធិស្ឋាន ។*

ពីរបីសប្ដាហ៍ក្រោយមក ខ្ញុំបានអភិវឌ្ឍទម្លាប់ប្រចាំថ្ងៃមួយ ។ ដំបូងខ្ញុំស្ដាប់សុន្ទរកថានៃសន្និសីទទូទៅបន្ទាប់មកសិក្សាប្រធានបទដំណឹងល្អជាក់លាក់មួយ ។ បន្ទាប់មក ខ្ញុំអានពីរបីជំពូកមកពីព្រះគម្ពីរមរមន ហើយបញ្ចប់ការសិក្សារបស់ខ្ញុំដោយការអធិស្ឋានដ៏ស្មោះសរទៅកាន់ព្រះវរបិតាសួគ៌ ។

ទោះបីជាមានការបំបែរអារម្មណ៍ជាច្រើនក្ដី ខ្ញុំកម្រនឹងខកខានសិក្សាដំណឹងល្អមួយថ្ងៃណាឡើយអស់រយៈពេលប្រាំមួយខែ ។ ខ្ញុំបានទទួលការយល់ដឹងកាន់តែប្រសើរអំពីប្រធានបទដំណឹងជាច្រើន ហើយបានពង្រឹងទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះវរបិតាសួគ៌ តាមរយៈការអធិស្ឋានជាទៀងទាត់ និងដោយស្មោះសរ ។

ទីបន្ទាល់របស់ខ្ញុំបានប្រែជាអ្វីមួយដែលខ្ញុំអាចពឹងផ្អែកបាន ។ មន្ទិលសង្ស័យរបស់ខ្ញុំបានលោយបាត់ ដោយសារទីបន្ទាល់ថ្មីៗដែលខ្ញុំបានទទួលពីដំណឹងល្អដែលបានស្ដារឡើងវិញ ។ ខ្ញុំបានឃើញថា ខ្ញុំពុំសូវបារម្ភឡើយដោយសារខ្ញុំបានទុកចិត្តលើព្រះកាន់តែច្រើនឡើង ។ ខ្ញុំទទួលអារម្មណ៍ថា សេចក្ដីភ័យខ្លាច និងភាពអស់សង្ឃឹមបានចេញឆ្ងាយពីខ្ញុំ ។ ខ្ញុំក៏បាត់បង់ចំណាប់អារម្មណ៍លើសកម្មភាពដែលខ្ជះខ្ជាយពេលវេលា ហើយកត់សម្គាល់ឃើញថា ខ្ញុំប្រែកាន់តែមានចិត្តសប្បុរស និងសុភាពចំពោះមនុស្សដទៃ ។

នៅពេលខ្ញុំស្ដាប់តាមការទូន្មានរបស់ប្រធានស្តេកខ្ញុំ នោះព្រះអាចផ្លាស់ប្ដូរខ្ញុំបាន ។ ខ្ញុំត្រូវបានព្យាបាល ហើយស្ដារឡើងវិញដោយលោកថៅហ្វាយផ្ទាល់ នៅពេលខ្ញុំបានទទួលទានព្រះបន្ទូលរបស់ទ្រង់ ។ ■

**ម៉ាត ម៉ាកស្វែល រដ្ឋយូថាហ៍ ស.រ.អា**



**យើ**ងបានខិតខំធ្វើការពេញមួយថ្ងៃ ។ ពួកយើងឃ្លាន ។ ការរើសលុយបានប្រហែលជាពរជ័យសម្រាប់ការបម្រើរបស់យើង ។

# ប៉ុន្តែខ្ញុំឃ្លាន !

**នៅ**ថ្ងៃដែលមានភ្លៀងធ្លាក់មួយក្នុងបេសកកម្មរបស់ខ្ញុំក្នុងប្រទេសកូឡុំប៊ី ដៃគូខ្ញុំ និងខ្ញុំ នៅសល់ពេលមួយម៉ោងទៀត ពីមុនយើងទៅផ្ទះ ។ យើងឃ្លាន ហើយអស់កម្លាំងដោយសារដើរពេញមួយថ្ងៃហើយ ។ យើងពុំបានជួបនរណាម្នាក់ដើម្បីបង្រៀនឡើយ ។

យើងក៏គ្មានប្រាក់នៅជាប់នឹងខ្លួន ហើយយើងក៏ពុំបានទៅហាងទិញគ្រឿងស្បៀងឡើយ ។ យើងដឹងថា យើងនឹងទៅផ្ទះ ហើយគ្មានអ្វីបរិភោគទេ ។ ខ្ញុំបានព្យាយាមមិនគិតពីអារម្មណ៍អវិជ្ជមាននេះទេ ហើយផ្ដោតទៅលើកិច្ចការវិញ ។

ភ្លាមនោះដៃគូរបស់ខ្ញុំស្រែកឡើងថា « មើលនេះនែ៎ ! »

គាត់រើសបានលុយមួយចំនួនពីលើដី ។ ការបង្ហាញនៅលើទឹកមុខរបស់គាត់ នោះខ្ញុំអាចប្រាប់ថា គាត់កំពុងគិតអ្វីដែលខ្ញុំបានគិត ។ យើងអាចទិញអាហារបរិភោគហើយ !

ប៉ុន្តែមួយសន្ទុះក្រោយមក ដៃគូរបស់ខ្ញុំនិយាយថា « អត់ទេ នេះពុំមែនជាលុយរបស់យើងទេ ! »

ខ្ញុំបានគិតថា « ប៉ុន្តែខ្ញុំឃ្លាន ! »

ខ្ញុំបានប្រាប់គាត់ថា « ទោះវាជារបស់នរណាក៏ដោយ យើងពុំអាចរកម្ចាស់វាឃើញនៅម៉ោងយប់បែបនេះឡើយ » ។

គាត់បានផ្ដល់យោបល់ឲ្យយើងអធិស្ឋាន ។ ខ្ញុំដឹងថា នោះគឺជារឿងត្រឹមត្រូវ ប៉ុន្តែខ្ញុំមានកូនចិត្តមួយថា វាឆ្កួតណាស់ ។ យើងបានខិតខំធ្វើការពេញមួយថ្ងៃ ។ ពួកយើងឃ្លាន ។ ការរើសលុយបានប្រហែលជាពរជ័យសម្រាប់ការបម្រើរបស់យើង ។

បន្ទាប់មក ខ្ញុំបានចាំអំពីម្ដាយរបស់ខ្ញុំ ។ កាលខ្ញុំនៅតូច គាត់បានបង្រៀនបងស្រីរបស់ខ្ញុំ និងខ្ញុំឲ្យមានចិត្តទៀងត្រង់ជានិច្ច ។ គាត់គឺជាគំរូមួយសម្រាប់ពួកយើង ហើយគាត់បានអធិស្ឋានថា យើងនឹងមានចិត្តក្លាហានដើម្បីមានចិត្តទៀងត្រង់ ។ ខ្ញុំបានដឹងថា ប្រសិនបើគាត់បាននៅទីនោះ នោះគាត់ច្បាស់ជាកើតទុក្ខ ប្រសិនបើខ្ញុំពុំធ្វើការសម្រេចចិត្តត្រឹមត្រូវនោះ ។

ដូច្នេះយើងបានអធិស្ឋាន ។ យើងបានទូលសូមដល់ព្រះវរបិតាសួគ៌ឲ្យជួយយើងរកឃើញម្ចាស់លុយនោះវិញ ។ បីបួននាទីក្រោយមក យុវជនម្នាក់បានមករកអ្វីមួយ ។ គាត់បានយំ ហើយមើលទៅដូចជាពិបាកចិត្ត ។ ខ្ញុំ និងដៃគូរបស់ខ្ញុំបានទៅរកគាត់ ហើយដឹងថា យើងមានអ្វីដែលគាត់កំពុងតែរកនោះ ។

យើងបានប្រគល់លុយនោះទៅឲ្យគាត់វិញ ហើយគាត់បានអរគុណយើងម្ដងហើយម្ដងទៀត ។ គាត់បាននិយាយថា គាត់ត្រូវការវាដើម្បីបង់ថ្លៃសាលា ។ ប្រសិនបើគ្មានលុយនោះទេ នោះគាត់នឹងពុំអាចចុះឈ្មោះចូលរៀនបានឡើយ ។ ខ្ញុំបានយំ ហើយខ្ញុំបានប្រែចិត្តពីចំណង់ប្រាថ្នាមុនដំបូងរបស់ខ្ញុំដើម្បីចាយលុយនោះ ។ យើងបានព័ត៌មានទំនាក់ទំនងរបស់ក្មេងប្រុសនោះ ហើយយើងអាចទៅបង្រៀនគាត់ និងមនុស្សប្រាំនាក់ផ្សេងទៀត ។ នៅយប់នោះ ខ្ញុំបានថ្លែងអំណរគុណដល់ដៃគូរបស់ខ្ញុំសម្រាប់គំរូល្អរបស់គាត់ ។

ខ្ញុំដឹងថា ព្រះប្រទានពរដល់យើង នៅពេលយើងមានចិត្តទៀងត្រង់ ។ យើងគ្មានអ្វីបរិភោគឡើយនៅយប់នោះ ប៉ុន្តែខ្ញុំពុំចាំថា ខ្ញុំបានចូលដេកទាំងស្រេកឃ្លានឡើយ ។ ការរើសលុយបាននោះគឺជាពរជ័យជាងអ្វីៗទាំងអស់ ។ ■

**អីសាដូរ៉ា ម៉ាគីស ហ្គាសៀ ទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល**

រូបភាពគូរដោយ អេលែន ហ្គាន់ស៍

# ឡកម្តៅផ្ទះយើងដំណើរការដោយសារសេចក្តីជំនឿ




នៅពេលស្វាមីរបស់ខ្ញុំម៉ាក និងខ្ញុំបានរស់នៅជាមួយកូនតូចប្រាំនាក់របស់យើងនៅឆ្នេរភាគខាងកើតនៃសហរដ្ឋអាមេរិក យើងបានរស់នៅក្នុងផ្ទះមួយដែលមានឡកម្តៅដែលប្រើប្រេង ។ ដើម្បីមើលកម្រិតប្រេង នោះយើងត្រូវដាក់កម្រិតវ៉ាស់មួយនៅក្នុងធុងប្រេង ។ ហើយប្រសិនបើប្រេងនោះវាជិតអស់ យើងនឹងទូរសព្ទទៅក្រុមហ៊ុនប្រេងសម្រាប់ឡកម្តៅនោះឲ្យមកចាក់បំពេញធុងប្រេងនោះ ។

នៅអំឡុងពេលរដូវរងាដ៏ខ្លាំងមួយនាខែមករា យើងមានបញ្ហាហិរញ្ញវត្ថុកើតឡើង ។ ខ្ញុំបានធ្វើការក្រៅម៉ោងនៅពេលល្ងាចនៅហាងមួយ ដើម្បីជួយដល់ចំណូលយើង ប៉ុន្តែយើងនៅតែពុំអាចបំពេញសេចក្តីត្រូវការរបស់យើងឡើយ ។ ទីបំផុត ខ្ញុំបានឈានដល់ការសម្រេចចិត្តថា តើត្រូវថ្វាយដង្វាយមួយភាគក្នុងដប់ ឬត្រូវបង់លុយថ្លៃប្រេង ។ យើងបានវ៉ាស់កម្រិតប្រេងនោះ ហើយវាបានចុះមកដល់កម្រិត ៥ សង់ទីម៉ែត្រ ។ ចំណុះនោះអាចប្រើបានតែមួយ ឬពីរថ្ងៃប៉ុណ្ណោះ ។ ប៉ុន្តែយើងសម្រេចចិត្តដាក់ទីទុកចិត្តរបស់យើងទៅលើព្រះអម្ចាស់ ហើយបានថ្វាយដង្វាយមួយភាគក្នុងដប់របស់យើង ។

នៅថ្ងៃបន្ទាប់មក ម៉ាកបានវ៉ាស់កម្រិតប្រេងម្តងទៀត ។ វានៅតែមានចំណុះប្រាំសង់ទីម៉ែត្រដដែល ។ ម៉ាកបានវាស់វាម្តងទៀតនៅថ្ងៃបន្ទាប់ទៀត ហើយវានៅតែមានចំណុះប្រាំសង់ទីម៉ែត្រដដែល ។ ការដុតកម្តៅនៅតែបន្ត ប៉ុន្តែកម្រិតប្រេងពុំបានចុះឡើយ ។ ពីរថ្ងៃបន្ទាប់មក កម្រិតប្រេងនោះនៅតែមានចំណុះប្រាំសង់ទីម៉ែត្រដដែល ។ ខ្ញុំចាំពីការយំដោយអំណរពេលយប់ កាលខ្ញុំបានឮសំឡេងម៉ាស៊ីនកម្តៅបានឆេះឡើង ។ ឡកម្តៅរបស់យើងពុំមែនដំណើរការដោយប្រេងឡើយ ប៉ុន្តែដំណើរការដោយសារសេចក្តីជំនឿវិញ ។

ខ្ញុំមានអារម្មណ៍ដូចជាស្រ្តីមេម៉ាយដែលបានផ្តល់អាហារដល់ព្យាការីអេលីយ៉ា ហើយបានឃើញថា « ម្សៅក្នុងខាប់នោះ មិនដែលអស់ទៅ ហើយប្រេងក្នុងដបក៏មិនចេះរលោះឡើយ » ( ពង្សាវតារក្សត្រ ទី ១ ១៧:១៦ ) ។ ទីបំផុត នៅពេលដល់ថ្ងៃត្រូវបង់ប្រាក់ ម៉ាកបានវ៉ាស់កម្រិតប្រេងម្តងទៀត ។ លើកនេះវាមានចំណុះពីរសង់ទីម៉ែត្រកន្លះ ។ ឥឡូវប្រេងបានចុះ ប៉ុន្តែយើងមានប្រាក់ដើម្បីចាក់បំពេញធុងប្រេងនោះ ។

គ្រួសាររបស់យើងបានសាកល្បងការសន្យារបស់ព្រះដែលមាននៅក្នុងម៉ាឡាគី ៣:១០ ៖ « ហើយល្បងលយើងឥឡូវ បើយើងមិនបើកទ្វារស្ថានសួគ៌ ដើម្បីចាក់ព្រះពរមកលើឯង ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » ។

ជូនចំពោះអស់អ្នកដែលមានចិត្តសង្ស័យចំពោះពរជ័យពីការថ្វាយដង្វាយមួយភាគក្នុងដប់ នោះខ្ញុំសូមលើកទឹកចិត្តពួកគេឲ្យទទួលយកការអញ្ជើញរបស់ព្រះអម្ចាស់ដើម្បី « ល្បងលយើងឥឡូវ » ។ ការថ្វាយដង្វាយមួយភាគក្នុងដប់ចាក់បើកបង្អួចស្ថានសួគ៌ ហើយតាមរយៈការគោរពប្រតិបត្តិ និងភាពស្មោះត្រង់ចំពោះក្រឹត្យវិន័យរបស់ព្រះអម្ចាស់ នោះយើងបានពរក្នុងរបៀបជាច្រើន ។

គ្រួសាររបស់យើងនឹងពុំភ្លេចឡើយ កាលប្រេងនៃឡកម្តៅរបស់យើងដំណើរការដោយសេចក្តីជំនឿជាជាងដោយប្រេង ។ ■

**ល្វីស មែនសៀស រដ្ឋតិចសាស ស.រ.អា**

*យើងបានវ៉ាស់កម្រិតប្រេងនោះនៅក្នុងឡកម្តៅ ហើយវាបានចុះមកដល់កម្រិត ៥ សង់ទីម៉ែត្រ ។ ចំណុះនោះអាចប្រើបានតែមួយ ឬពីរថ្ងៃប៉ុណ្ណោះ ។*

រចនារូបភាពដោយ គុប អ៊ីលូស្រ្តេសិន



## រៀនដើម្បីធ្វើកិច្ចការលំបាក

នៅពេលខ្ញុំគិតអំពីពាក្យភាពខ្លួនទីពឹងខ្លួន ឃ្លាមួយមកពីប្រធានបេសកកម្មខ្ញុំបានផុសឡើងក្នុងចិត្តខ្ញុំ ៖ « សូមធ្វើកិច្ចការលំបាកៗដោយខ្លួនឯង » ។ មែនហើយ វាគឺជាសេចក្ដីថ្លែងមួយដ៏ចម្លែក ប៉ុន្តែមានសេចក្ដីពិតជាច្រើននៅក្នុងគំនិតដែលថា **មានរឿងលំបាកៗជាច្រើននៅក្នុងជីវិតយើង** យើងពុំអាចសូមឲ្យមនុស្សដទៃធ្វើវាជំនួសយើងបានឡើយ ។

ដូច្នេះតើយើង « ធ្វើកិច្ចការលំបាកៗដោយខ្លួនឯង » ទាក់ទងនឹងភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្តយ៉ាងដូចម្ដេច ? តើយើងអាចដោះស្រាយការខកចិត្ត និង **រៀនដោះស្រាយនូវគ្រប់បញ្ហាផ្នែកផ្លូវចិត្តរបស់យើងដោយរបៀបណា ?**

ដោយអំណរគុណ យើងពុំត្រូវទុកឲ្យនៅក្នុងទីងងឹតឡើយ—ធនធាននានាមាននៅជុំវិញយើង ។ យើងអាចរកឃើញធនធានមួយចំនួននេះនៅក្នុង « របៀប ១៤ យ៉ាង ដើម្បីធ្វើឲ្យសុខភាពផ្លូវចិត្តរបស់អ្នកត្រឡប់មកលើផ្លូវវិញ » ។ កាន់តែសំខាន់បំផុតនោះ **យើងអាចធ្វើឲ្យជីវិតយើងមានភាពងាយស្រួល** នៅពេលយើងគោរពបទបញ្ញត្តិ ( សូមមើលទំព័រ ៤៤ ) ។

ការរៀនឆ្លើយតបចំពោះអ្វីៗដែលកើតឡើងនៅក្នុងជីវិតយើងគឺជាដំណើរការមួយ ។ ការមានភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្តពុំមែនមានន័យថា យើងនឹងមានអារម្មណ៍តាមអ្វីដែលយើងចង់មានជានិច្ចនោះទេ ។ វាមានន័យថា តាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ និងកិច្ចខិតខំផ្ទាល់របស់យើង **នោះយើងអាចគ្រប់គ្រងផ្លូវចិត្តក្នុងរបៀបមួយដែលមានសុខភាពល្អ និងប្រកបដោយភាពច្នៃប្រឌិត ។** ប្រធាន អិម រ័សុល បាឡឺដ ផ្ដល់ការទូន្មានមួយចំនួនដល់យើងឲ្យអនុវត្តដើម្បីសម្រេចបាននូវតុល្យភាពនេះ ( សូមមើលទំព័រ ៤៨ ) ។

នៅពេលយើង **ស្វែងរកភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត** យើងអាចទទួលអារម្មណ៍ថា យើងដូចជាចាបតូចមួយ ( សូមមើលទំព័រ ៤៦ ) ប៉ុន្តែពេលយើងអនុវត្តកិច្ចខិតខំនេះ និងមានភាពជាដៃគូជាមួយព្រះវរបិតាសួគ៌ នោះយើងអាចមានទំនុកចិត្តថា ថ្ងៃណាមួយយើងនឹង « ហើរឡើងទៅលើដោយស្លាបដូចជាឥន្ទ្រី » ( អេសាយ ៤០:៣១ ) ដែលជាវិធីមួយទៀតនៃការនិយាយថា យើងនឹងមានកម្លាំងដើម្បីធ្វើកិច្ចការលំបាកៗដោយខ្លួនឯងបាន ។

សូមជូនពរឲ្យអ្នកបានសម្រេច

Heather J Johnson

### ចែកចាយរឿងរបស់អ្នក

តើអ្នកមានរឿងអស្ចារ្យដើម្បីចែកចាយឬទេ ? ឬតើអ្នកចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? ដូច្នេះ យើងចង់ឮពីអ្នក ! សូមផ្ញើអត្ថបទ ឬមតិកែលម្អរបស់អ្នកទៅ **liahona.lds.org** ។

# យុវមជ្ឈិមវ័យ



## នៅក្នុងវគ្គនេះ


៤៤ ដំណឹងល្អ ៖ យោបល់ដ៏មានប្រយោជន៍អស់កល្ប
ដោយ ឡូរី ហ្វូលើរ

៤៦ បង្រៀនខ្ញុំឲ្យហោះហើរ ៖ ការសម្រេចបាននូវភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្តតាមមាគ៌ារបស់ព្រះអម្ចាស់
ដោយ វ៉ាលើរី ឌូវ៉ែន

៤៨ យោបល់ចំនួន ៨ យ៉ាង ដើម្បីធ្វើឲ្យតម្រូវការជីវិតមានលំនឹង
ដោយប្រធាន អិម រ័សុល បាឡឹដ


### មានតែលើអិនធើរណែតប៉ុណ្ណោះ


ការស្វែងរកអ្នកមានវិជ្ជាជីវៈខាងសុខភាពផ្លូវចិត្តដែលត្រឹមត្រូវសម្រាប់អ្នក
ដោយ ខេរីន សេ្សីរ័ត្ន

របៀប ១៤ យ៉ាង ដើម្បីធ្វើឲ្យសុខភាពផ្លូវចិត្តរបស់អ្នកត្រឡប់មកលើផ្លូវវិញ ។
ដោយ ហ៊ីស្សេី ដេ ចនសុន

មូលហេតុដែលខ្ញុំមិនភ័យខ្លាចទៀតចំពោះការប្រឹក្សាអំពីសុខភាពផ្លូវចិត្ត
ដោយ ដេវី ក្លាក




### ពាក្យទូន្មានល្អបំផុត . . .

*យុវមជ្ឈិមវ័យចែកចាយពាក្យទូន្មានល្អបំផុតដែលពួកគេធ្លាប់បានទទួលអំពីការមើលថែដល់សុខភាពផ្លូវចិត្ត និងគំនិតរបស់ពួកគេ ៖*

« សូមឆ្លៀតពេលហាត់ប្រាណ ឈប់ព្រួយបារម្ភ និងកម្ចាត់ចោលនូវគំនិត និងអារម្មណ៍អវិជ្ជមានដែលអ្នកមាន » ។
*—ប្រាយអិនណា ហ្វ័ររ៉េសស្ទើរ រដ្ឋវ៉ាស៊ីនតោន ស. រ. អា.*

« សូមកុំខ្លាចដើម្បីទៅជួបគ្រូពេទ្យ ។ ជាមួយនឹងការរួមផ្សំគ្នាត្រឹមត្រូវនៃការព្យាបាលខាងវិញ្ញាណ និងសាច់ឈាម នោះខ្ញុំអាចរស់នៅ ហើយរង់ចាំការហៅបម្រើបេសកកម្ម ដើម្បីខ្ញុំអាចបម្រើព្រះអម្ចាស់ » ។
*—ណែត សៀល រដ្ឋយូថាហ៍ ស.រ.អា.*

« ចូរធ្វើកិច្ចការល្អៗក្នុងកម្រិតសមរម្យ ហើយផ្ដោតជីវិតរបស់អ្នកលើព្រះគ្រីស្ទ » ។
*—ណាន គ្រូ រដ្ឋល្វីស៊ីអាណា ស.រ.អា.*

« សូមចាំថា សម្រាកឲ្យបានគ្រប់គ្រាន់ ។ ស្ដាប់ទៅវាកំប្លែង ប៉ុន្តែវាពិតជាសំខាន់ណាស់ ! »
*—ស៊ីដនី ស្មីធ រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.*

*តើពាក្យទូន្មានល្អបំផុតអ្វី ដែលអ្នកធ្លាប់បានទទួលអំពីការពុំរិះគន់លើខ្លួនរបស់អ្នក ? សូមផ្ញើចម្លើយរបស់អ្នកទៅ* ***liahona.lds.org*** ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៩ ។



**ឡូរី ហ្វូលើរ** គឺជាអ្នកបោះពុម្ពសម្រាប់ទស្សនាវដ្ដី *Friend* ។ គាត់ចូលចិត្តស្វែងរកក្រុមចម្រៀងថ្មីៗ ស្ដាប់ព័ត៌មានតាមវិទ្យុ និងចម្អិនម្ហូបមកពីជុំវិញពិភពលោក ។ ជួនកាលគាត់សរសេរអត្ថបទបន្តិចបន្តួច ។



**វ៉ាលើរី ដូវ៉ាន់** មកពីរដ្ឋកាលីហ្វ័រញ៉ា ស.រ.អា. បានរៀបការនឹងស្វាមីគាត់ឈ្មោះវ៉ាយអិនអស់រយៈពេលបួនឆ្នាំហើយ ។ ថ្មីៗនេះគាត់ទើបតែមានកូនប្រុសម្នាក់ ។ គាត់ចូលចិត្តកីឡាយ៉ូកា ការគូររូប ការអាន និងការឡើងភ្នំ ។



**ហ៊ីស្សេី ដេ ចនសុន** គឺជាអ្នកអ្នកនិពន្ធ និងអ្នកកែសម្រួលអត្ថបទ ។ គាត់ចូលចិត្តកីឡាជិះស្គីលើទឹក ហើយធ្វើដំណើរផ្សងព្រេងនៅលើភ្នំពេលរដូវរងា ។ គាត់ចូលចិត្តអក្សរសាស្ត្រអង់គ្លេស ហើយផ្ដល់អនុសាសន៍ឲ្យប្រើពាក្យ « y'all ( អ្នកទាំងអស់គ្នា ) » នៅក្នុងការសន្ទនាប្រចាំថ្ងៃ ។



**ដាវី ក្លាក** ចូលចិត្តចំណាយពេលជាមួយភរិយា និងកូនស្រីរបស់គាត់ ។ ពេលគាត់ពុំធ្វើការក្នុងនាមជាគណនេយ្យករ នោះគាត់ចំណាយពេលក្នុងសកម្មភាពខាងក្រៅផ្ទះ លេងកីឡា វត់ ជិះកង់ ឬមើលកីឡាវាយកូនបាល់ ។

### មានច្រើនទៀតសម្រាប់អ្នក

សូមមើល « យុវមជ្ឈិមវ័យប្រចាំសប្ដាហ៍ » ដែលមាននៅក្នុងវគ្គយុវមជ្ឈិមវ័យនៅលើកម្មវិធី Gospel Library សម្រាប់មាតិកាឌីជីថលថ្មី ដែលមានរៀងរាល់សប្ដាហ៍ ហើយសូមតាមដានពួកយើងនៅលើ **facebook.com/liahona** ដើម្បីស្វែងរកអត្ថបទនានាដែលមាននៅលើអិនធើរណែតប៉ុណ្ណោះ និងមាតិកាបន្ថែម ។





# ដំណឹងល្អ

## យោបល់ដ៏មានប្រយោជន៍អស់កល្ប

ដោយ ឡូរី ហ្វូលើរ
ទស្សនាវដ្ដីសាសនាចក្រ

តើអ្នកធ្លាប់គិតអំពីរបៀបដែលការគោរពបទបញ្ញត្តិធ្វើឲ្យជីវិតមានភាពកាន់តែងាយស្រួលដែរឬទេ ?

កាលពីខែមុន មិត្តភក្តិមួយចំនួន និងខ្ញុំបាននិយាយប្រាប់គ្នាអំពីកិច្ចការដែលយើងធ្វើនៅសប្ដាហ៍នោះ ។ មិត្តម្នាក់បានចែកចាយថា គាត់បានដោះស្រាយបន្ទុកមួយដ៏លំបាកគឺការជាសះស្បើយពីការញៀនស្រារបស់ម្ដាយគាត់ ។ គាត់មានអាយុក្មេងជាងខ្ញុំបន្តិចស្ដាប់ទៅវាជាកិច្ចការដ៏លំបាកមួយ ។

ពេលយប់កាន់តែជ្រៅបន្តិច យើងបានជជែកគ្នាអំពីថ្លៃចំណាយលើការជក់បារី និងរបៀបដែលមនុស្សម្នាក់ដែលយើងជក់បារីអស់មួយកញ្ចប់ក្នុងមួយថ្ងៃ ។ ( បើគិតលុយវិញគឺអស់ច្រើនណាស់ ! ) គាត់បានព្យាយាមឈប់ជក់ ហើយគាត់កំពុងឆ្លងកាត់ការផ្ដាច់បារី ។ កូនប្រុសរបស់គាត់រីករាយណាស់ដែលគាត់ឈប់ជក់បារី ។ ឪពុករបស់គាត់បានស្លាប់ដោយសារហូបថ្នាំលើសកម្រិត ដែលធ្វើឲ្យគាត់ភ័យច្រើនក្នុងការប្រើប្រាស់ថ្នាំនានា ។



ទីបំផុតការសន្ទនារបស់យើងបញ្ចប់ត្រឹមរឿងកាហ្វេ—តើមនុស្សផឹកកាហ្វេច្រើនប៉ុន្មានរៀងរាល់ព្រឹក ( និងពេលរសៀល ហើយជួនកាលពេលយប់ទៀត ) និងរបៀបដែលពួកគេខកខានមិនបានផឹកកាហ្វេ ដោយសារតែពួកគេគ្មានប្រាក់ទិញផឹករៀងរាល់ថ្ងៃទៀត ។

ពេលខ្ញុំបើកឡានទៅផ្ទះវិញដោយគិតអំពីការសន្ទនាទាំងនេះ នោះខ្ញុំបានគិតថា « ពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាយោបល់គ្រឹះដ៏មានប្រយោជន៍ចម្បងដ៏ធំបំផុតនៃជីវិត ។ ( ប្រសិនបើអ្នកពុំស្គាល់ « យោបល់ដ៏មានប្រយោជន៍ » គឺជារបៀបមួយដែលធ្វើឲ្យជីវិតរបស់អ្នកល្អប្រសើរឡើង រស់នៅកាន់តែ



មានប្រសិទ្ធិភាព ជាដើម ។ ដូចម្នាក់នៅលើអ៊ិនធើរណែតបានពិពណ៌នាវាថា យោបល់ដ៏មានប្រយោជន៍គឺជាអ្វីដែលគេធ្លាប់ហៅថា « គំនិតល្អ » ) ។ វាដូចជាអ្វីដែលព្រះបានមានបន្ទូល « នេះជារបៀបមួយដើម្បីសន្សំប្រាក់របស់អ្នក ជួយអ្នកឲ្យមានសុខភាពល្អ ការពារកូនរបស់អ្នក ហើយចៀសផុតពីបន្ទុកខាងផ្លូវចិត្តដ៏លំបាក រួមទាំងការឈឺចាប់ផ្ទាល់ខ្លួន និងការឈឺចាប់របស់មនុស្សដទៃ ។ វាស្ទើរតែដូចជាអ្វីដែលព្រះបានរៀបចំទុកជាមុននូវរាល់បញ្ហាទាំងអស់ដែលយើងជួប ហើយប្រទានដល់យើងនូវវិធីមួយដើម្បីចៀសវាងពាក់កណ្ដាលពីវា ។...

ជាមួយនឹងបទបញ្ញត្តិណាមួយរបស់ព្រះ នោះយើងមានជម្រើសដើម្បីធ្វើតាម ឬព្រងើយកន្តើយនឹងបទបញ្ញត្តិទាំងនោះ ។ ប៉ុន្តែនៅពេលខ្ញុំគិតអំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃថា ជាសេចក្ដីណែនាំមកពីព្រះដែលរៀបចំទុកជាមុន និងការពារយើងពីឧបសគ្គជាច្រើន នោះខ្ញុំបានគិតថា « ចុះមានអ្វីកើតឡើងប្រសិនបើបទបញ្ញត្តិរបស់ព្រះទាំងអស់ដំណើរការតាមរបៀបនោះ ? » ចុះមានអ្វីកើតឡើង ប្រសិនបើព្រះវរបិតាសួគ៌ជាទីស្រឡាញ់ ដែលមានបទពិសោធន៍នៃជីវិតនេះ និងឧបសគ្គនានា បានប្រទានសៀវភៅណែនាំមួយ ដើម្បីជួយយើងឲ្យរស់នៅដោយគ្មានការឈឺចាប់ ? ហើយតើមានអ្វីកើតឡើង ប្រសិនបើទ្រង់ប្រទានសៀវភៅណែនាំនោះដល់យើង ដោយសារទ្រង់ស្រឡាញ់ពួកយើង ហើយមានព្រះទ័យការពារយើង ?

តើអ្នកពេញចិត្តនឹងអ្វីដែលអ្នកមាន ដើម្បីរីករាយ និងមានអំណរដែរឬទេ ? « កុំឲ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឲ្យសោះ » ( និក្ខមនំ ២០:១៧ ) ។

តើអ្នកចង់ចៀសវាងពីកំហុស ការជាប់ឃុំឃាំង ការបង់ប្រាក់ជានាច្រើនដើម្បីរួចពីការឃុំឃាំង និងថ្លៃថៅក្រមដែរឬទេ ? តើអ្នកចង់រក្សាទំនុកចិត្ត និងការគោរព—និងការងាររបស់អ្នកឬទេ ? « កុំឲ្យលួចប្លន់ឲ្យសោះ » ( និក្ខមនំ ២០:១៥ ) ។

តើអ្នកចង់បន្តនៅជិតព្រះ ដើម្បីឲ្យទ្រង់អាចណែនាំ និងដឹកនាំអ្នក ហើយជួយអ្នកឲ្យរែកបន្ទុករបស់អ្នកដែរឬទេ ? « ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្តអស់ពីព្រលឹង ហើយអស់អំពីគំនិតឯង » ( ម៉ាថាយ ២២:៣៧ ) ។

បញ្ជីនេះនៅមានបន្តទៀត ។ បទបញ្ញត្តិនីមួយៗអាចការពារយើងពីការឈឺចាប់ ធ្វើឲ្យជីវិតយើងកាន់តែងាយស្រួល ធ្វើឲ្យយើងចៀសវាងពីក្ដីអំពល់ ឬជួយយើងឲ្យរកឃើញភាពសុខសាន្ត ។ ហើយយើងទទួលពរជ័យទាំងនេះដោយកិច្ចខិតខំ ឬភាពពុំងាយស្រួលតិចតួចប៉ុណ្ណោះ ។ ( ហើយគ្មានតម្លៃដែលលាក់បាំងឡើយ ! )

ខ្ញុំពិតជាពុំចង់បន្ទាបបទបញ្ញត្តិទាំងឡាយរបស់ព្រះមកត្រឹមតែជាសេចក្ដីណែនាំ ឬយោបល់ដ៏មានប្រយោជន៍នៃជីវិតនោះឡើយ ។ បទបញ្ញត្តិរបស់ព្រះគឺមានទំហំធំជាងនេះឆ្ងាយណាស់ ។ ប៉ុន្តែបទបញ្ញត្តិរបស់ព្រះក៏មានលក្ខណៈសាមញ្ញផងដែរ ។ ព្រះវរបិតាសួគ៌ពុំអាចការពារយើងពីគ្រប់កិច្ចការទាំងអស់ឡើយ ។ ប៉ុន្តែក្នុងនាមជាឪពុកម្ដាយជាទីស្រឡាញ់ ទ្រង់សព្វព្រះទ័យរៀបចំយើង ហើយការពារយើងពីឥទ្ធិពលនៃជម្រើសរបស់យើង—តាមរយៈការណែនាំយើងឲ្យធ្វើជាមនុស្សប្រសើរឡើង ។

ប្រាកដណាស់ យើងអាចរក្សាបទបញ្ញត្តិ ហើយនៅតែមានរឿងអាក្រក់កើតឡើង ។ អញ្ចឹងយើងគោរពបទបញ្ញត្តិធ្វើអ្វី ?

ដោយសារយើងនឹងពុំដឹងសោះឡើយថា តើយើងនឹង *ត្រូវបាន* ការពារពីអ្វីខ្លះឡើយ តាមរយៈការគោរពប្រតិបត្តិរបស់យើង ។ ដោយសារវាជួយរំដោះយើងចេញពីជីវិតដែលធ្វើឲ្យឈឺចាប់ ។ ដោយសារការគោរពប្រតិបត្តិជួយយើងឲ្យបន្តនៅជិតព្រះ ។ ដោយសារវាដាក់យើងនៅក្នុងកន្លែងមួយដើម្បីប្រែចិត្ត នៅពេលយើងជ្រើសរើសខុស ។ ដោយសារយើងទុកចិត្តព្រះ ថាទ្រង់ត្រាស់ដឹងអំពីរបៀបប្រទានពរ និងការពារយើង ។

បញ្ជីនេះនៅមានបន្តទៀត ។ វាគឺជាបញ្ជីមួយដែលវែងជាងបញ្ជីនៃហេតុផលដែលយើង *មិន* គោរពបទបញ្ញត្តិទៅទៀត ។

ទោះមានលទ្ធផលល្អ ឬអាក្រក់ក្ដី ព្រះទុកឲ្យខ្ញុំជ្រើសរើសថា ខ្ញុំចង់គោរពប្រតិបត្តិខ្លាំងប៉ុណ្ណា ។ *ខ្ញុំ* អាចជ្រើសរើសថា តើខ្ញុំបើកខ្លួនខ្ញុំចំពោះពរជ័យដែលទ្រង់មានសម្រាប់ខ្ញុំធំប៉ុណ្ណា ។ ដូច្នេះហេតុអ្វីត្រូវគោរពបទបញ្ញត្តិ ? ដោយសារខ្ញុំចង់ឲ្យជីវិតខ្ញុំទទួលបានជំនួយដែលព្រះកំពុងព្យាយាមប្រទានឲ្យដោយឥតដែនកំណត់ ។ ■

# បង្រៀនខ្ញុំឲ្យហោះហើរ

## ការសម្រេចបាននូវភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្តតាមមាគ៌ារបស់ព្រះអម្ចាស់

យើងត្រូវពឹងផ្អែកលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយត្រូវអនុវត្តកិច្ចខិតខំផ្ទាល់ខ្លួនរបស់យើង នៅពេលយើងមានគោលបំណងចង់មានភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត ។



ដោយ វ៉ាលើរី ឌូរ៉ែន

នៅពេលយើងគិតអំពីកូនចាបកំពុងតែរៀនហើរ នោះយើងស្រមៃឃើញរូបភាពនៃការព្យាយាមដ៏ក្លាហានចុងក្រោយរបស់វា ៖ កូនចាបលោតចេញពីសំបុកវា លាស្លាបវាឡើង ហើយហោះទៅលើមេឃ ។ ពីមុនជោគជ័យនោះ វាទំនងជាជួបនូវបរាជ័យជាច្រើនដែលធ្វើឲ្យកូនចាបនោះពុំអាចហោះទៅលើមេឃបាន ប៉ុន្តែធ្លាក់ខ្លាក់ទៅលើដីវិញ ។

ដូចជាចាបដែលរៀនហើរដែរ យើងក៏ធ្លាក់ចុះម្ដងហើយម្ដងទៀតដែរ នៅពេលយើងចង់សម្រេចឲ្យបានភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្តផ្ទាល់ខ្លួនរបស់យើង ។ ប៉ុន្តែប្រសិនបើយើងបែរទៅរកព្រះអម្ចាស់ដើម្បីសូមជំនួយ ហើយអនុវត្តកិច្ចខិតខំ នោះយើងអាចរៀនអំពីរបៀបទទួលបានជោគជ័យម្ដងទៀត នៅពេលដែលជីវិតហាក់ដូចជាពុំកើតឡើងដូចការគ្រោងទុក្ខ ហើយពឹងផ្អែកទៅលើទ្រង់ និងពេលដែលការសាកល្បងបានប្រែជាខ្លាំងក្លាពេកចំពោះយើងឲ្យស៊ូទ្រាំដោយខ្លួនយើងបាននោះ ។

### ការរៀនហើរ

ប្រសិនបើការរៀនហើរគឺជាដំណើរការមួយដ៏ឈឺចាប់ ហេតុអ្វីសត្វចាបចាកចេញពីសំបុកវាដែលជាកន្លែងដំបូងរបស់វាធ្វើអ្វី ? ពីព្រោះដោយសារតែមេវា ។ នៅផ្នែកដំបូងនៃជីវិតកូនៗរបស់វា មេចាបនឹងយកចំណីទៅដោយផ្ទាល់ឲ្យពួកគេដល់សំបុក ។ ប៉ុន្តែនៅពេលណាមួយ មេចាបចាប់ផ្ដើមទុកចំណីនៅខាងក្រៅសំបុក ដូច្នេះកូនចាបត្រូវធ្វើដំណើរចេញពីកន្លែងសុខស្រួលរបស់វា ដើម្បីទទួលបានការចិញ្ចឹមបីបាច់ ។

វាគឺជាដំណើរការដូចគ្នា ដែលយើងស៊ូទ្រាំ នៅពេលយើងរៀនប្រែក្លាយជាមានភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត—ប៉ុន្តែយើងពុំអាចរំពឹងទុកថា អាចហើរបានទាំងស្រុងដោយខ្លួនយើងនៅឡើយទេ ។

ដូចគ្នាទៅនឹងមេចាបដែលអនុញ្ញាតឲ្យកូនវាចេញពីសំបុកដែរ នោះព្រះវរបិតាសួគ៌ទុកឲ្យយើងឆ្លងកាត់ការសាកល្បង និងបទពិសោធន៍នានា ដែលអាចមានភាពឈឺចាប់ ស្មុគស្មាញ និងបាក់ទឹកចិត្ត ។ ផែនការនៃសេចក្ដីសង្គ្រោះរបស់ទ្រង់ត្រូវបានរៀបចំឡើងដើម្បីជួយយើងឲ្យប្រែក្លាយដូចទ្រង់ ដូច្នេះគ្រប់ឧបសគ្គទាំងអស់ដែលយើងជួប អាចជាឱកាសដើម្បីរៀន និងរីកចម្រើន ។ ដូចជាមេចាបដែរ ព្រះវរបិតាសួគ៌នៅតែប្រទានដល់យើងនូវការល្បួងលោម និងការណែនាំ ដោយសារមានតែតាមជំនួយរបស់ទ្រង់ប៉ុណ្ណោះ



ដែលយើងអាចសម្រេច និងរក្សាសុខភាពផ្លូវចិត្ត និងអារម្មណ៍យើងបាន ។

### ការហើរដោយស្លាបរបស់យើងផ្ទាល់

ទោះបីជាព្រះវរបិតាសួគ៌ជាដៃគូរបស់យើងក្ដី យើងពុំគួររំពឹងឲ្យទ្រង់ធ្វើអ្វីគ្រប់យ៉ាងសម្រាប់យើងឡើយ ។ ទ្រង់សព្វព្រះទ័យឲ្យយើងប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើង និងធនធាននានាដែលទ្រង់បានប្រទានឲ្យយើងនៅលើផ្លូវរបស់យើងដើម្បីមានភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត ។

ឧទាហរណ៍ ពេលយើងមានការឈឺចាប់ក្នុងចិត្ត កំហឹង ឬការបាត់បង់ នោះទ្រង់សព្វព្រះទ័យឲ្យយើងប្រឹក្សាជាមួយទ្រង់ ប៉ុន្តែយើងពុំគួរឈប់នៅត្រឹមនេះទេ—យើងត្រូវការធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ដើម្បីអនុវត្តតាមការបំផុសគំនិតដែលទ្រង់បានប្រទានដល់យើង រក្សាបទបញ្ញត្តិ ចូលរួមព្រះវិហារបរិសុទ្ធដើម្បីស្វែងរកភាពសុខសាន្ត ការលួងលោម និងចម្លើយ គិតគូរអំពីការទូន្មានរបស់ព្យាការី ហើយទុកចិត្តលើផែនការរបស់ទ្រង់សម្រាប់ពួកយើង ។

ព្រះវរបិតាសួគ៌បានប្រទានឧបករណ៍ជាច្រើនដល់យើងដើម្បីសម្រេចបាននូវភាពខ្លួនទីពឹងខ្លួនផ្នែកផ្លូវចិត្ត ប៉ុន្តែប្រសិនបើយើងខំប្រឹងអស់ពីសមត្ថភាព ហើយនៅតែឃើញថា យើងនៅជាប់គាំង ឬមានការលំបាកជាមួយសុខភាពផ្លូវចិត្តទៀត នោះធនធានបន្ថែមទៀតគឺមានភាពចាំបាច់ណាស់ ។ ពិតណាស់ មានគ្រាជាច្រើនដែលអ្នកត្រូវតែងាកទៅរកអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្ត ឬទទួលការទូន្មានពីប៊ីស្សពរបស់អ្នកសម្រាប់ការណែនាំបន្ថែមទៀត ដើម្បីបន្តដំណើរឆ្ពោះទៅមុខទៀត ។

ចូរដឹងថា ប្រសិនបើយើងសូមការទូន្មានពីមនុស្សដទៃគ្រប់ពេលដែលយើងជួបឧបសគ្គ នោះយើងអាចបាត់បង់ឱកាសដ៏មានតម្លៃដើម្បីរៀន ហើយរីកចម្រើនដោយខ្លួនយើង ។ ជាថ្មីម្ដងទៀត យើងត្រូវតែខិតខំឲ្យអស់ពីសមត្ថភាពរបស់យើងដើម្បីបន្តឆ្ពោះទៅមុខទៀត ។

### ដើរតាមលំនាំរបស់ព្រះអម្ចាស់

នៅក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាកណ្ឌទី ៩ អូលីវើរ ខៅឌើរី ត្រូវបានស្ដីបន្ទោសចំពោះការព្យាយាមបកប្រែផ្ទាំងព្រះគម្ពីរមរមន ដោយពុំបាន « យកមកគិតសោះ ក្រៅពីសុំពី [ ព្រះ ] » ( ខទី ៧ ) ។ ក្រោយមកទ្រង់បានដាស់តឿនឲ្យ « សិក្សាក្នុងគំនិត [ របស់លោក ] » ដើម្បីឈានដល់ការសន្និដ្ឋានរបស់គាត់ បន្ទាប់មក « សូមដល់ [ ព្រះ ] បើសិនជាការណ៍នោះត្រឹមត្រូវ » ( ខទី ៨ ) ។

នៅពេលយើងធ្វើតាមលំនាំនេះ ព្រះវរបិតាសួគ៌ពុំបោះបង់យើងឲ្យពឹងផ្អែកលើសមត្ថភាព និងគំនិតផ្ទាល់ខ្លួនយើងទាំងស្រុងឡើយ នៅពេលយើងខ្វាយខ្វល់នឹងសុខភាពផ្លូវចិត្តរបស់យើងនោះ ។ ទ្រង់កំពុងប្រទានឱកាសឲ្យយើងរៀនសូត្រអំពីរបៀបដើម្បីអនុវត្តសិទ្ធិជ្រើសរើសរបស់យើង ។ ការស្វែងរកចម្លើយចំពោះសំណួររបស់យើង និងការស្វែងរកដំណោះស្រាយរបស់យើងចំពោះបញ្ហានានា ជាមួយនឹងជំនួយរបស់ទ្រង់គឺជាអ្វីដែលនឹងជួយយើងឲ្យប្រែក្លាយដូចជាទ្រង់នៅទីបំផុត ។ ដោយចាំការណ៍នេះក្នុងចិត្ត នោះយើងអាចសូមឲ្យទ្រង់បង្ហាញយើង អំពីរបៀបដែលយើងអាចប្រែកាន់តែមានតុល្យភាពផ្នែកផ្លូវចិត្ត ជំនួសឲ្យការសូមយ៉ាងសាមញ្ញពីទ្រង់ដើម្បីធ្វើឲ្យយើងបានប្រសើរឡើង ។

នៅពេលយើងអនុវត្តសិទ្ធិជ្រើសរើសរបស់យើងម្ដងហើយម្ដងទៀតនៅក្នុងលំនាំនេះ ទោះជាយើងមានការសាកល្បងផ្នែកផ្លូវចិត្តបែបណាក្ដី នោះយើងនឹងប្រែកាន់តែប្រសើរឡើង ហើយមានទំនុកចិត្តកាន់តែច្រើនដោយសន្សឹមៗ ។ ខណៈដែលយើងពុំទាន់ចេះហើរស្ទាត់នៅឡើយ នោះយើងអាចប្រាកដថា ទ្រង់គង់នៅជាមួយយើងនៅតាមផ្លូវ ហើយរីករាយនៅក្នុងសេចក្ដីពិតថា ទ្រង់កំពុងជួយយើងឲ្យប្រែកាន់តែប្រសើរឡើងបន្តិចម្ដងៗ ។ មានឱកាសផ្សេងទៀតរៀងរាល់ថ្ងៃដើម្បីប្រែខ្លួនកាន់តែប្រសើរឡើង—ដែលរៀបចំយើងសម្រាប់ថ្ងៃដែលយើងនឹងអាចហើរដោយខ្លួនយើងបាន ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋកាលីហ្វូញ៉ា ស.រ.អា. ។*

រចនារូបភាពពី GETTY IMAGES



**ប្រធាន**
**អិម រ័សុល បាឡឺដ**
ប្រធានស្ដីទីក្នុង
កូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

ខ្ញុំមានយោបល់មួយចំនួនដែលខ្ញុំសង្ឃឹមថា នឹងមានតម្លៃដល់អ្នកដែលខ្វាយខ្វល់នឹងការធ្វើឲ្យតម្រូវការនៃជីវិតមានតុល្យភាព ។

## យោបល់ចំនួនប្រាំបីយ៉ាងដើម្បី
# ធ្វើឲ្យតម្រូវការជីវិតមានតុល្យភាព

១. ***ទីមួយ សូមគិតអំពីជីវិតរបស់អ្នក ហើយដាក់អាទិភាពរបស់អ្នក ។*** សូមស្វែងរកពេលស្ងប់ស្ងាត់ជាទៀងទាត់ដើម្បីគិតឲ្យស៊ីជម្រៅអំពីកន្លែងដែលអ្នកនឹងទៅ និងអ្វីដែលអ្នកនឹងត្រូវការដើម្បីធ្វើទៅដល់ទីនោះ ។ ព្រះយេស៊ូវជាគំរូរបស់យើង ជារឿយៗទ្រង់ « បានថយចេញទៅឯទីស្ងាត់ ដើម្បីអធិស្ឋានវិញ » ( លូកា ៥:១៦ ) ។ យូរៗម្ដង យើងត្រូវតែធ្វើដូច្នេះដែរដើម្បីរំឭកខ្លួនរបស់យើងខាងវិញ្ញាណដូចជាព្រះអង្គសង្គ្រោះបានធ្វើដែរ ។ សូមសរសេរកិច្ចការនានាដែលអ្នកចង់សម្រេចបាននៅថ្ងៃនីមួយៗ ។ សូមចាំក្នុងចិត្តនូវសេចក្ដីសញ្ញាពិសិដ្ឋដ៏សំខាន់បំផុត ដែលអ្នកបានចុះជាមួយព្រះអម្ចាស់ នៅពេលអ្នកសរសេរកាលវិភាគប្រចាំថ្ងៃរបស់អ្នក ។

២. ***ទីពីរ ដាក់គោលដៅខ្លីៗដែលអ្នកចង់សម្រេចបាន ។*** សូមដាក់គោលដៅដែលអ្នកអាចធ្វើឲ្យមានតុល្យភាពបានល្អ—កុំដាក់គោលដៅច្រើនពេក ឬតិចពេក ហើយកុំដាក់គោលដៅខ្ពស់ពេក ឬទាបពេក ។ សូមសរសេរគោលដៅដែលអ្នកអាចសម្រេចបាន ហើយខិតខំធ្វើវា ស្របតាមសារៈសំខាន់របស់វា ។ អធិស្ឋានទូលសូមការណែនាំពីព្រះនៅក្នុងការដាក់គោលដៅរបស់អ្នក ។

៣. ***ទីបី តាមរយៈការចាត់ចែងថវិកាដោយឈ្លាសវៃ សូមគ្រប់គ្រងតម្រូវការពិតប្រាកដរបស់អ្នក ហើយវាស់វែងវាដោយប្រុងប្រយ័ត្ន ដែលវាផ្ទុយទៅនឹងចំណង់ចង់បានជាច្រើនរបស់អ្នកនៅក្នុងជីវិត ។*** មានបុគ្គល និងគ្រួសារជាច្រើនបានជួបនឹងការជំពាក់បំណុលដ៏លើសលុប ។ សូមប្រុងប្រយ័ត្ននឹងការផ្ដល់ឲ្យដ៏ទាក់ទាញជាច្រើនដើម្បីខ្ចីប្រាក់ ។ ខ្ចីប្រាក់គឺងាយជាងការសងប្រាក់វិញឆ្ងាយណាស់ ។ គ្មានផ្លូវកាត់ដើម្បីមានសុវត្ថិភាពខាងហិរញ្ញវត្ថុឡើយ ។ យើងនឹងគ្មានលំនឹងក្នុងជីវិតយើងឡើយ លុះត្រាតែហិរញ្ញវត្ថុរបស់យើង ត្រូវបានគ្រប់គ្រងដោយសុវត្ថិភាព ។

សូមចាំជានិច្ចថា ត្រូវថ្វាយដង្វាយមួយភាគក្នុងដប់ឲ្យពេញលេញ ។

GETTY IMAGES



**៤.** ***ទីបួន សូមបន្តនៅក្បែរនឹងស្វាមី ឬភរិយា កូនៗ សាច់ញាតិ និងមិត្តភក្តិ ។*** ពួកគេនឹងជួយអ្នកឲ្យរក្សាតុល្យភាពនៅក្នុងជីវិតអ្នក ។ សូមបង្កើតទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិរបស់អ្នក តាមរយៈទំនាក់ទំនងបើកចំហរ និងស្មោះត្រង់ ។

ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងគ្រួសារល្អ អាចត្រូវបានរក្សាតាមរយៈទំនាក់ទំនងទន់ភ្លន់ ដោយក្ដីស្រឡាញ់ និងចេះគិតចេះគូរ ។ សូមចាំថា ការក្រឡេកមើល ការមិចភ្នែកដាក់ ការងក់ក្បាល ឬការស្ទាបអង្អែលនឹងមានឥទ្ធិពលខ្លាំងជាងពាក្យសម្ដីទៅទៀត ។ ការកំប្លែងលេង និងការស្ដាប់ដ៏ល្អក៏ជាផ្នែកសំខាន់មួយនៃទំនាក់ទំនងល្អផងដែរ ។

**៥.** ***ទីប្រាំ ការសិក្សាព្រះគម្ពីរ ។*** ព្រះគម្ពីរផ្ដល់ប្រភពមួយដ៏ល្អបំផុតដែលយើងមាន ដើម្បីទាក់ទងជាមួយព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ របៀបមួយដែលខ្ញុំបានទទួលចំណេះដឹងពិតប្រាកដថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទគឺតាមរយៈការសិក្សាព្រះគម្ពីររបស់ខ្ញុំ ។ ប្រធាន វ៉ែសុល អិម ណិលសុន បានអញ្ជើញសមាជិកសាសនាចក្រទាំងអស់ឲ្យសិក្សាព្រះគម្ពីរមរមនប្រកបដោយការអធិស្ឋានរៀងរាល់ថ្ងៃ ។

**៦.** ***ទីប្រាំមួយ យើងត្រូវដាក់កាលវិភាគលើប្រតិទិនប្រចាំថ្ងៃរបស់យើង ដើម្បីសម្រាកឲ្យបានគ្រប់គ្រាន់ ហាត់ប្រាណ និងសម្រាកលំហែរកាយ*** ប្រសិនបើយើងចង់រីករាយនឹងជីវិតដែលមានសុខភាពល្អ និងមានតុល្យភាព ។ សុខភាពរូបកាយល្អពង្រីកភាពថ្លៃថ្នូររបស់យើង និងការគោរពខ្លួនឯង ។

**៧.** ***ទីប្រាំពីរ ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។*** យើងពុំត្រូវបាត់បង់ឱកាសពិសេសនេះដើម្បី « បង្រៀនគ្នាទៅវិញទៅមកអំពីគោលលទ្ធិនៃនគរ » ឡើយ ( គ. និង ស. ៨៨:៧៧ ) ដែលនឹងដឹកនាំគ្រួសារទៅកាន់ជីវិតអស់កល្បជានិច្ច ។

សាតាំងតែងតែធ្វើការដើម្បីបំផ្លាញទីបន្ទាល់របស់អ្នក ប៉ុន្តែវានឹងគ្មានអំណាចដើម្បីល្បួង ឬរំខានយើងលើសពីកម្លាំងរបស់យើងដើម្បីទប់ទល់ឡើយ នៅពេលយើងកំពុងសិក្សាដំណឹងល្អ និងរស់នៅតាមបទបញ្ញត្តិនៃដំណឹងល្អ ។

**៨.** ***យោបល់ចុងក្រោយរបស់ខ្ញុំគឺអធិស្ឋានឲ្យបានញឹកញាប់ ។*** អ្នកអាចដឹងអំពីការសម្រេចចិត្តត្រឹមត្រូវដើម្បីធ្វើកិច្ចការនានាប្រចាំថ្ងៃតាមរយៈការអធិស្ឋានដោយខ្ជាប់ខ្ជួនស្មោះសរជានិច្ច ។ នៅពេលខ្ញុំរស់នៅស្របតាមដំណឹងល្អ នោះខ្ញុំឃើញថា ខ្ញុំអាចធ្វើឲ្យអ្វីៗនៅក្នុងជីវិតរបស់ខ្ញុំមានតុល្យភាពកាន់តែងាយស្រួល ។

ខ្ញុំបានដឹងថា យោបល់ផ្សេងទៀតអាចត្រូវបានបន្ថែមលើយោបល់ទាំងនេះដែរ ។ ប៉ុន្តែខ្ញុំជឿថា នៅពេលយើងផ្ដោតទៅលើគោលបំណងគ្រឹះពីរ ឬបី នោះយើងទំនងជាអាចគ្រប់គ្រងតម្រូវការជាច្រើនដែលយើងរំពឹងចង់បាន ។ ចូរចាំថា ការចំណាយពេលច្រើនពេកលើសកម្មភាពតែមួយឬពីរអាចធ្វើឲ្យយើងបាត់បង់តុល្យភាពនៅក្នុងជីវិត ។ នៅក្នុងពេលដំណាលគ្នានោះដែរ បើយើងចំណាយពេលមិនគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពអ្វីមួយដែលសំខាន់នោះក៏អាចធ្វើឲ្យបាត់បង់តុល្យភាពក្នុងជីវិតផងដែរ ។ ស្ដេចបេនយ៉ាមីនបានប្រឹក្សាថា « ការណ៍ទាំងនេះត្រូវបានប្រព្រឹត្តឡើងក្នុងប្រាជ្ញា និងរបៀបរៀបរយ » ( ម៉ូសាយ ៤:២៧ ) ។

ជារឿយៗ ការខ្វះនូវការណែនាំ និងគោលដៅច្បាស់លាស់ អាចខ្ជះខ្ជាយពេលវេលា និងកម្លាំងរបស់យើង ព្រមទាំងរួមចំណែកធ្វើឲ្យជីវិតយើងគ្មានតុល្យភាព ។ គោលដៅចម្បងរបស់យើងគួរតែដើម្បីស្វែងរក « អមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ច » ( ម៉ូសេ ១:៣៩ ) ។ ដោយមានចំណុចនេះជាគោលដៅរបស់យើង ហេតុអ្វីក៏យើងមិនកម្ចាត់ចោលនូវអ្វីៗដែលបង្វែរអារម្មណ៍ និងបំភាន់ ព្រមទាំងប្រើគំនិត អារម្មណ៍កម្លាំងរបស់យើង ដែល ពុំរួមចំណែកក្នុងការធ្វើឲ្យសម្រេចគោលដៅរបស់យើងចេញពីជីវិតយើងទៅ ?

ចូរធ្វើឲ្យអស់ពីសមត្ថភាពរបស់អ្នករៀងរាល់ថ្ងៃ ។ ចូរធ្វើកិច្ចការគ្រឹះនានា ហើយពីមុនអ្នកដឹងពីវា នោះជីវិតរបស់អ្នកនឹងពោរពេញដោយការយល់ដឹងខាងវិញ្ញាណ ដែលនឹងបញ្ជាក់ដល់អ្នកថា ព្រះវរបិតាសួគ៌ស្រឡាញ់អ្នក ។ នៅពេលបុគ្គលម្នាក់ដឹងអំពីរឿងនេះ នោះជីវិតនឹងពោរពេញដោយគោលបំណង និងអត្ថន័យ ដែលនឹងធ្វើឲ្យតុល្យភាពកាន់តែងាយស្រួលដើម្បីរក្សាវាទុក ។ ■

*ដកស្រង់ចេញពីសុន្ទរកថាសន្និសីទទូទៅ*
*ខែ មេសា ឆ្នាំ ១៩៨៧ ។*





# យុវវ័យ

## ចុះបើខ្ញុំចេញទៅ ?

ពេលដែលខ្ញុំផ្លាស់មកនៅទីនេះជាលើកដំបូង មានតែយុវនារីពីរនាក់ផ្សេងទៀតប៉ុណ្ណោះនៅក្នុងសាខារបស់ខ្ញុំ ។ យើងបានក្លាយជាមិត្តនឹងគ្នា ហើយខ្ញុំបានស្គាល់ពួកគេយ៉ាងច្បាស់ ។ ប៉ុន្តែពួកគេបានឈប់មកព្រះវិហារ ។

មានគ្រាមួយ ពេលខ្ញុំទៅព្រះវិហារបរិសុទ្ធ ខ្ញុំបានឃើញប្រធានបេសកកម្ម ។ ខ្ញុំបានប្រាប់គាត់ពីមិត្តរបស់ខ្ញុំ ហើយសួរថា តើខ្ញុំអាចធ្វើអ្វីខ្លះដើម្បីជួយពួកគេឲ្យត្រឡប់មកក្នុងសាសនាចក្រវិញ ។ គាត់បានប្រាប់ខ្ញុំឲ្យនៅកន្លែងដែលខ្ញុំនៅ ចូររឹងមាំ ហើយអធិស្ឋានឲ្យពួកគេ ។

បន្ទាប់ពីគ្រានោះមកមិនយូរប៉ុន្មាន ខ្ញុំបានឃើញមិត្តខ្ញុំម្នាក់ ហើយខ្ញុំរីករាយខ្លាំងណាស់ ដែលបានជួបនឹងនាង ។ ពេលខ្ញុំត្រឡប់មកផ្ទះវិញនៅយប់នោះ ខ្ញុំបានអធិស្ឋាន ហើយបានទទួលអារម្មណ៍យ៉ាងមុឺងម៉ាត់ថា ខ្ញុំត្រូវបន្តនៅត្រង់កន្លែងដែលខ្ញុំនៅ ហើយបន្តទៅព្រះវិហារ បន្តទៅថ្នាក់សិក្ខាសាលា ហើយបន្តធ្វើជាគំរូដល់មិត្តរបស់ខ្ញុំ ។ ចុះបើខ្ញុំចេញទៅ ហើយមិនត្រឡប់មកវិញ ហើយមិត្តខ្ញុំម្នាក់បានត្រឡប់មកព្រះវិហារវិញ ? តើបាននរណាធ្វើមិត្តរបស់ពួកគេ ហើយជួយពួកគេឲ្យត្រឡប់មកវិញ ?

រឿងទាំងឡាយមានភាពងាយស្រួល នៅពេលយើងធ្វើវារួមគ្នា ។

**អាលីអូណា**
ខាគីវ អូប្លាស ប្រទេសអ៊ុយក្រែន

### នៅក្នុងវគ្គនេះ




៥២ ដូចព្រះអង្គសង្គ្រោះ ៖ ការរីកចម្រើននៅក្នុងចំណុចសំខាន់បួន
ដោយ ឌីអាន ថូម៉ាស

៥៦ សេចក្ដីណែនាំរបស់កីឡាករលើកទម្ងន់ដើម្បីឈរឲ្យរឹងមាំ
ដោយ គៀនីនី ម៉ាណូម៉ៅ

៥៨ បាវចនាម្ចាស់ផលឆ្នាំ ២០១៩: « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ »
ដោយគណៈប្រធានយុវជន និងយុវនារីទូទៅ

៦០ ចម្រៀងបាវចនាម្ចាស់ផលប្រចាំឆ្នាំ ២០១៩: បើស្រឡាញ់ទ្រង់
ដោយ នីខ ដេយ៍

៦៤ ពាក្យចុងក្រោយ: ពិធីសាក្រាម៉ង់ និងការប្រែឲ្យកាន់តែដូចព្រះគ្រីស្ទ
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន



**ដោយ ឌីអាន ថូម៉ាស**
ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន

# ដូចព្រះអង្គសង្គ្រោះ

## ការរីកចម្រើននៅក្នុងចំណុចសំខាន់បួន

*យើងពុំដឹងច្រើនអំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទចម្រើនវ័យធំឡើងឡើយ ប៉ុន្តែ លូកា ២:៥២ ផ្តល់តម្រុយដ៏ធំដល់យើង ។*

« ដូច្នេះ ខ្ញុំនឹង . . . ធ្វើអ្វី ? » ខ្ញុំបានស្តាប់ ។ ខ្ញុំពិតជាបានស្តាប់មែន ។ គ្រូបង្វឹកបានពិនិត្យមើលខ្សែចងចុះចំណោតរបស់ខ្ញុំ បានបង្ហាញខ្ញុំយ៉ាងច្បាស់លាស់អំពីរបៀបស្រាយខ្សែនោះ ហើយថែមទាំងមើលចំកែវភ្នែករបស់ខ្ញុំ ហើយនិយាយថា « ខ្ញុំនឹង **មិន** ឲ្យអ្នកធ្លាក់ឡើយ ! »

ប៉ុន្តែនៅគ្រាដ៏ចាំបាច់នោះ ខ្ញុំបានឈរនៅទីនោះ ៖ ញីញ័រ ហើយបែកញើសជោកខ្លួនពេលខ្ញុំមើលទៅលើស្មា និងខាងក្រោមខ្លួនខ្ញុំ . . . មើលចុះទៅឆ្ងាយ ដោយដឹងថា ខ្ញុំត្រូវតែធ្វើជំហានដំបូងនោះ ។

លោតចុះតាមជម្រាលភ្នំ ។

ឥឡូវនេះ អ្នកប្រហែលជាមិនធ្លាប់ស្ថិតនៅក្នុងស្ថានភាពដូចខ្ញុំឡើយ គឺការហៀបនឹងឈានជើងលោតចុះតាមជម្រាលភ្នំដោយសង្ឃឹមថា អ្នកបានរៀបចំខ្លួនគ្រប់គ្រាន់ដើម្បីលោតចុះពីលើទៅក្រោមតាមជម្រាលភ្នំដោយសុវត្ថិភាព ។ ប៉ុន្តែអ្នកហាក់ដូចជាជួបបទពិសោធន៍នោះនៅក្នុងស្ថានភាពខាងវិញ្ញាណ ។ អ្នកដឹងទេ ពេលអ្នកបានសិក្សាព្រះគម្ពីរដោយខ្លួនឯង និងពេលអ្នកបានស្ដាប់គ្រូបង្រៀនថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ពិត ។ អ្នកទទួលអារម្មណ៍ថា ព្រះវិញ្ញាណអញ្ជើញអ្នកឲ្យអនុវត្តក្នុងរបៀបនានាដែល នឹងជួយអ្នកឲ្យប្រែក្លាយកាន់តែដូចព្រះអង្គសង្គ្រោះ ។ អ្នកមានចិត្តរំភើបដើម្បីធ្វើកិច្ចការនេះ ហើយបង្ហាញព្រះអម្ចាស់ថា អ្នកមានការតាំងចិត្តខ្លាំងប៉ុណ្ណាចំពោះដំណឹងល្អរបស់ទ្រង់ ។

បន្ទាប់មកអ្នកគិតថា « តើខ្ញុំធ្វើកិច្ចការនោះដោយរបៀបណា ? »

ហើយអ្វីដែលទំនងដូចជាច្បាស់លាស់ និងអាចធ្វើទៅបានកាលពីគ្រាមួយភ្លែតមុននេះទើបតែបានកន្លងផុតទៅហើយនោះ ។ អ្នកកំពុងឈរនៅគែមនៃជម្រាលភ្នំខាងវិញ្ញាណ ដោយពុំប្រាកដចិត្តថា តើអ្នកមានឧបករណ៍ ឬមានការរៀបចំត្រឹមត្រូវដើម្បីអនុវត្តតាមសេចក្ដីពិតដែលអ្នកបានទទួលនោះឬទេ ។

ដើម្បីប្រែក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ៖ តើអ្នក *ធ្វើវា* ដោយរបៀបណា ?

## សូមចាប់ផ្ដើមពីដើមគ្រា

ព្រះអង្គសង្គ្រោះបានចាប់ផ្ដើមជីវិតរមែងស្លាប់របស់ទ្រង់ដូចអ្នក និងខ្ញុំផងដែរ ៖ គឺជាទារកមួយ ។ ហើយទីបំផុត ដូចជាយើងដែរ ព្រះយេស៊ូវបានចាប់ផ្ដើមធំឡើង ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:១១–១៧ ) ។ ទ្រង់បានរៀនរបៀបដើម្បីដើរ និយាយ និងសើច ។ ទ្រង់បានរៀនរបៀបដើម្បីធ្វើការ អាន និងមានទំនាក់ទំនងជាមួយមនុស្ស ។

ប្រាកដណាស់ របៀបដែលព្រះអម្ចាស់ « ចម្រើនវ័យធំឡើង » គឺត្រូវបានកត់ត្រានៅក្នុង លូកា ២:៥២ ៖ « ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ។

ប្រសិនបើយើងចង់ក្លាយដូចជាព្រះអង្គសង្គ្រោះ នោះយើងត្រូវធ្វើតាមគំរូរបស់ទ្រង់ ។

ដូច្នេះ ចូរមើលលំនាំនេះ ហើយរកមើលខ្លួនយើងអំពីរបៀបក្លាយដូចជាព្រះយេស៊ូវគ្រីស្ទជារឿង *អាច* ធ្វើទៅបាន !



*អ្នកកំពុងឈរនៅគែមនៃជម្រាលភ្នំខាងវិញ្ញាណ ដោយពុំប្រាកដចិត្តថា តើអ្នកមានឧបករណ៍ ឬមានការរៀបចំត្រឹមត្រូវដើម្បីអនុវត្តតាមសេចក្ដីពិតដែលអ្នកបានទទួលនោះឬទេ ។*

## « ប្រាជ្ញារឹតតែច្រើនឡើង »

ព្រះបង្កើតគំនិតរបស់យើងឲ្យមានលទ្ធភាពដ៏អស្ចារ្យមួយ ដើម្បីវាយតម្លៃ ដំណើរការ និងអនុវត្តចំណេះដឹង ។ សេចក្ដីពិត ការគណនា ជំនាញ ដំណើរការនានា—ព័ត៌មានជាច្រើនដែលយើងអាចប្រមូលបានគឺស្ទើរតែគ្មានកំណត់ !

ប៉ុន្តែដូចព្រះអង្គសង្គ្រោះដែរ យើងស្វែងរក *ប្រាជ្ញា* រឹតតែច្រើនឡើង ពុំមែនគ្រាន់តែព័ត៌មាននោះទេ ។ ប្រាជ្ញាអាចប្រើព័ត៌មានដោយត្រឹមត្រូវ យល់ជម្រើសរបស់យើង ហើយធ្វើការសម្រេចចិត្តបានល្អ ។

អែលឌើរ ជេម អ៊ី ថាលម៉េហ្គ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ( ១៨៦២–១៩៣៣ ) បានបង្រៀនថា « ការប្រើប្រាស់ចំណេះដឹងត្រឹមត្រូវបង្កើតឲ្យមានប្រាជ្ញា » ។[1] លោកក៏បានពន្យល់អំពីរបៀបដែលព្រះអង្គសង្គ្រោះបានទទួលប្រាជ្ញាផងដែរ ៖ « ទ្រង់បានប្រមូលចំណេះដឹងតាមរយៈការសិក្សា និងទទួលបានប្រាជ្ញាតាមរយៈការអធិស្ឋាន ការគិត និងកិច្ចខិតខំ » ។[2]

អាលម៉ាបានបង្រៀនហេលេមិនកូនប្រុសរបស់លោកថា « ចូរចងចាំ ហើយឲ្យចេះមាន *ប្រាជ្ញា* នៅក្នុងយុវវ័យរបស់កូនចុះ មែនហើយ ចូររៀននៅក្នុងយុវវ័យរបស់កូនឲ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ » ( អាលម៉ា ៣៧:៣៥ ការគូសបញ្ជាក់បានបន្ថែម ) ។ សូមគិតអំពីរឿងនេះ ៖ សេចក្ដីជំនឿ សិក្សា និងការគោរពប្រតិបត្តិពង្រីកសមត្ថភាពរបស់យើងឲ្យទទួលបានចំណេះដឹង និងមានប្រាជ្ញារឹតតែច្រើនឡើង !

### ប្រាជ្ញា

តើអ្នកអាចអនុវត្តគោលការណ៍នៃសេចក្ដីជំនឿ និងការគោរពប្រតិបត្តិ ដើម្បីជួយអ្នកឲ្យមានប្រាជ្ញារឹតតែច្រើនឡើងដោយរបៀបណា ? តើការធ្វើឲ្យមានប្រាជ្ញារឹតតែច្រើនឡើង អាចជួយអ្នកឲ្យក្លាយកាន់តែដូចជាព្រះអង្គសង្គ្រោះដោយរបៀបណា ?

**សូមរៀនបន្ថែមទៀត ៖**
សូមមើល នីហ្វៃទី ២ ៩:២៨–២៩; គោលលទ្ធិ និងសេចក្ដីសញ្ញា ១៣០:១៨–១៩ ។

GETTY IMAGES

## « កាន់តែធំ »

នីហ្វៃមានមាឌធំ ហើយខ្លាំង ។ លោកគឺជាមនុស្សដែលព្រះគម្ពីរហៅថា « មានមាឌធំ » ( នីហ្វៃទី ១ ២:១៦ ) ។ ខ្ញុំពុំមានមាឌធំឡើយ ។ មាឌរបស់នីហ្វៃត្រូវបានបង្កើតឡើងដើម្បីសម្រេចបាននូវសកម្មភាពផ្សេងជាងមាឌរបស់ខ្ញុំ ដោយសារព្រះអម្ចាស់មានកិច្ចការផ្សេងសម្រាប់នីហ្វៃ ។ នីហ្វៃបានសង់សំពៅ ស្វែងរកអាហារសម្រាប់គ្រួសារលោក ហើយជួយពួកគេធ្វើដំណើរឆ្លងកាត់ទីរហោស្ថាន ។

## រូបរាងកាយ

តើការថែទាំរូបរាងកាយរបស់អ្នកទាក់ទងនឹងការថែទាំវិញ្ញាណអ្នកដូចម្តេចខ្លះ ? តើអ្នកនឹងផ្លាស់ប្តូរ ឬកែលម្អអ្វីខ្លះ ក្នុងការថែទាំដល់រូបកាយរបស់អ្នក ?

**សូមរៀនបន្ថែមទៀត ៖**
សូមអានសុន្ទរកថាសន្និសីទទូទៅដោយប្រធាន រ័សុល អិម ណិលសុន ដែលមានចំណងជើងថា « សូមថ្វាយអំណរគុណដល់ព្រះ » ។

រូបកាយរបស់យើងមាននូវអ្វីដែលយើងត្រូវការ ដើម្បីរស់នៅ ហើយរីករាយនឹងជីវិតរមែងស្លាប់ ។ ដោយសារការរៀបចំរបស់ព្រះ ទារកដែលទើបនឹងកើតនឹងកាន់តែធំបន្តិចម្តងៗ ។ យើងពុំចាំបាច់អភិវឌ្ឍសរីរាង្គ ឬដៃជើងបន្ថែមទៀត ពេលយើងចាស់ទៅនោះទេ—ធាតុទាំងនោះបានបង្កើតរួចហើយ ដែលជាផ្នែកមួយនៃរូបកាយរបស់យើង ។ ពុំតម្រូវឲ្យមានការដាក់ផ្គុំអ្វីទៀតឡើយ ! ប៉ុន្តែដើម្បីឲ្យយើងបម្រើព្រះ និងអស់អ្នកដែលនៅជុំវិញយើង នោះយើងត្រូវរក្សាសុខភាពរូបកាយរបស់យើង ។

រូបកាយរបស់យើងគឺជាព្រះវិហារបរិសុទ្ធ ឬជាផ្ទះ ដែលបានបង្កើតយ៉ាងល្អឥតខ្ចោះសម្រាប់វិញ្ញាណរបស់យើង ( សូមមើល កូរិនថូសទី ១ ៣:១៦–១៧; ៦:១៩–២០ ) ។ ប្រធាន រ័សុល អិម ណិលសុន បានបង្រៀនថា « អ្វីក៏ដោយដែលជាអំណោយទានពីធម្មជាតិ នោះរូបកាយរបស់អ្នកគឺជាការបង្កើតដ៏សំខាន់របស់ព្រះ ។ វាជារោងឧបោសថរបស់សាច់ឈាម—ព្រះវិហារបរិសុទ្ធសម្រាប់វិញ្ញាណអ្នក » ។[៣]

រូបកាយរបស់យើងអាចជួបនឹងឧបសគ្គរូបកាយធ្ងន់ធ្ងរ ពិការភាព និងការឈឺចាប់ដោយសារយើងមានបទពិសោធន៍នៃជីវិតរមែងស្លាប់ ប៉ុន្តែព្រះវរបិតាសួគ៌បង្កើតរូបកាយរបស់យើងយ៉ាងល្អឥតខ្ចោះ ដើម្បីសម្រេចបាននូវឱកាសដ៏មានជោគជ័យនៅក្នុងជីវិតយើង ។

## « កើននូវទីគាប់ព្រះហឫទ័យដល់ព្រះ »

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « *សេចក្តីពិត* ដ៏ធំបំផុតដំបូងគេនៃអស់ទាំងភាពអស់កល្បជានិច្ចនោះគឺថា ព្រះស្រឡាញ់ *យើង* ដោយអស់ពីព្រះទ័យ ព្រះកាយ ព្រះបញ្ញាញាណ និងព្រះចេស្ដា *របស់ទ្រង់* » ។[៤]

ព្រះស្រឡាញ់ *អ្នក* ។ សូម្បីតែនៅពេលអ្នកមានអារម្មណ៍ថា អ្នកមិនល្អបំផុតក្តី ទ្រង់ស្រឡាញ់ *អ្នក*—ដោយអស់ពីកម្លាំង ភាពទន់ខ្សោយ ចម្ងល់ និងសេចក្តីសង្ឃឹមរបស់អ្នក ។ ដូច្នេះតើអ្នក « កើននូវទីគាប់ព្រះហឫទ័យដល់ព្រះ » ដោយរបៀបណា ? អ្នកបង្ហាញទ្រង់ថា អ្នកស្រឡាញ់ទ្រង់វិញ !

មានគ្រាមួយនោះ ព្រះយេស៊ូវបានប្រាប់ពួកសិស្សទ្រង់ថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » ( យ៉ូហាន ១៤:១៥ ) ។ ការគោរពប្រតិបត្តិរបស់អ្នកបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះ ។ ឆន្ទៈរបស់អ្នកដើម្បីគោរពប្រតិបត្តិក្នុងសកម្មភាពតិចតួចប្រចាំថ្ងៃ អាចរៀបចំអ្នកឲ្យឆ្លើយតប ហើយសម្រេចបាននូវរឿងកាន់តែប្រសើរឡើង នៅពេលការអញ្ជើញរបស់ទ្រង់មានឡើងនៅពេលអនាគត ។

## ជាទីគាប់ព្រះហឫទ័យដល់ព្រះ

តើព្រះអង្គសង្គ្រោះបានបង្ហាញថា ទ្រង់ស្រឡាញ់ព្រះវរបិតសួគ៌ដោយរបៀបណា ? តើរឿងនេះបង្រៀនអ្នកអំពីព្រះយេស៊ូវយ៉ាងដូចម្តេច ? តើសកម្មភាពដែលមានប្រសិទ្ធភាព សុចរិតអ្វីខ្លះដែលអ្នកអាចធ្វើ *នៅថ្ងៃនេះ* ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះ ?

**សូមរៀនបន្ថែមទៀត ៖**
សូមមើល ម៉ូសាយ ២:២២, ៤១ ។

« ពេលយើងរៀនច្រើនអំពីព្រះយេស៊ូវគ្រីស្ទ យើងអភិវឌ្ឍជំនឿលើទ្រង់ច្រើនជាងមុន ហើយចង់ធ្វើតាមគំរូទ្រង់ដោយឯកឯង » ។

ជីន បី ប៊ីងហាំ « ដើម្បីឲ្យអំណរបងប្អូនបានពេញលេញ » *Liahona,* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៨៧ ។

## « កើននូវទីគាប់ចិត្តមនុស្ស »

គួរឲ្យភ្ញាក់ផ្អើលណាស់ ! ការមានអ្នកតាមអ្នកច្រើនបំផុតនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម *ពុំ* មែនមានន័យថា អ្នក « កើននូវទីគាប់ចិត្តមនុស្ស » ទេ ។

ព្រះយេស៊ូវបានបង្ហាញនូវរបៀបមួយផ្សេងអំពីការជះឥទ្ធិពលដល់មនុស្សដទៃ—និងអ្នកដែលទ្រង់បានអនុញ្ញាតឲ្យជះឥទ្ធិពលលើទ្រង់ ។ ទ្រង់ « យាងចុះឡើងធ្វើការល្អ » . . . ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់ » ( កិច្ចការ ១០:៣៨ ) ។

**សូមរៀនបន្ថែម ៖**
សូមធ្វើជាមិត្តដូចជាអាំម៉ូនធ្វើចំពោះស្ដេចឡាម៉ូណៃ ។ សូមមើល អាលម៉ា ១៧:១៩–១៨:៤១ ។

### ជាទីគាប់ចិត្តមនុស្ស

តើអ្នកអាចក្លាយជាមិត្តកាន់តែប្រសើរឡើងចំពោះអស់អ្នកដែលនៅជុំវិញអ្នកតាមរបៀបណាខ្លះ ? តើការធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះស្ដីពី « យាងចុះឡើងធ្វើការល្អ » បង្កើនឥទ្ធិពលសុចរិតរបស់អ្នកជាមួយមនុស្សដទៃដោយរបៀបណា ?

មានម្ដងនោះ ប្រធាន ហិនរី ប៊ី អាវរិង ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយមានប្រសាសន៍ដូច្នេះ « ខ្ញុំនៅតែចាំ ហាក់ដូចវាជាថ្ងៃនេះអញ្ចឹង អំពីមិត្តភក្ដិដែលមានឥទ្ធិពលធ្វើឲ្យជីវិតរបស់ខ្ញុំមានសេចក្ដីល្អតាំងពីយូរមកហើយ ។ ពួកគេបានស្លាប់អស់ហើយ ប៉ុន្តែអនុស្សាវរីយ៍នៃសេចក្ដីស្រឡាញ់ គំរូ សេចក្ដីជំនឿ និងទីបន្ទាល់របស់ពួកគេនៅតែលើកស្ទួយដល់ខ្ញុំ » ។[5]

អ្នកអាចបង្កើននូវឥទ្ធិពលរបស់អ្នកតាមរយៈការធ្វើជាមិត្តម្នាក់ដែលមានឥទ្ធិពលលើអ្នកដទៃសម្រាប់សេចក្ដីល្អ ! *ដើម្បីកម្លាំងនៃយុវជន* បង្រៀនអ្នកអំពីរបៀប ៖ « បង្ហាញពីចំណាប់អារម្មណ៍ដ៏ពិតប្រាកដទៅដល់អ្នកដទៃទៀត ចូរញញឹម និងធ្វើឲ្យពួកគេដឹងថាអ្នកខ្វល់ខ្វាយពីពួកគេ ។ ចូរប្រព្រឹត្តិជាមួយមនុស្សគ្រប់រូបដោយការគោរព និងសុភាពរាបសា ចៀសវាងពីការកាត់សេចក្ដី និងការរិះគន់អ្នកទាំងឡាយដែលនៅជុំវិញអ្នក. . .ចូរខំធ្វើជាមិត្តភក្ដិនឹងអ្នកទាំងឡាយដែលមានការអៀនខ្មាស ឬឯកោ អ្នកដែលមានតម្រូវការពិសេស ឬមានអារម្មណ៍ថា ត្រូវបានគេបោះបង់ចោល » ។[6]

សូមគិតអំពីបុគ្គលម្នាក់ៗនៅពេលអ្នកសរសើរ និងគោរពដោយស្មោះ—ចំពោះបុគ្គលដែលអ្នក *គាប់ចិត្ត* ។ តើមានបុគ្គលិកលក្ខណៈអ្វីខ្លះដែលពួកគេបានអភិវឌ្ឍ ដែលរំឭកអ្នកអំពីព្រះយេស៊ូវគ្រីស្ទ ? ដោយសារដូចជាមិត្តល្អរបស់យើងដែរ នោះមិត្តដ៏ល្អបំផុតរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ និងគំរូរបស់ទ្រង់គឺជាបុគ្គលម្នាក់ដែលយើងចង់ធ្វើតាម !

នៅក្នុងពន្លឺរបស់ទ្រង់ ដោយ គ្រេក ខេ អុលសិន

## អ្វីៗទាំងអស់មានទំនាក់ទំនងគ្នា

« ព្រះយេស៊ូវក៏កាន់តែធំ ប្រកបដោយប្រាជ្ញារឹតតែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះ និងចិត្តមនុស្សផង » ( លូកា ២:៥២ ) ។ នៅពេលអ្នកធ្វើតាមលំនាំរបស់ព្រះអង្គសង្គ្រោះស្ដីពីការរីកចម្រើន នោះអ្នកនឹងរកឃើញថា ធាតុទាំងនោះធ្វើការរួមគ្នាយ៉ាងល្អឥតខ្ចោះ ហើយអ្នក *នឹង* ប្រែក្លាយកាន់តែដូចទ្រង់ ។ គំនិត រូបកាយ និងវិញ្ញាណរបស់អ្នកនឹងធ្វើការរួមគ្នាសម្រាប់សេចក្ដីល្អរបស់អ្នក ហើយអ្នកអាចនឹងផ្ដល់ពរដល់មនុស្សជាច្រើន ហើយ « បម្រើ [ ព្រះ ] ឲ្យអស់ពីចិត្ត អស់ពីពលំ អស់ពីគំនិត ហើយអស់ពីកម្លាំង » ! ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៤:២ ) ។ ■


កំណត់ចំណាំ

១. ជេម អ៊ិ ថាល់មេហ្គ *The Articles of Faith* 12th បានបោះពុម្ព ( ឆ្នាំ ១៩២៤ ) ទំព័រ ៩០ ។
២. ជេម អ៊ិ ថាល់មេហ្គ *Jesus the Christ* ( ឆ្នាំ ១៩១៦ ) ទំព័រ ១១២ ។
៣. រ័សុល អិម ណិលសុន « We Are Children of God » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៨៥ ។
៤. ជែហ្វ្រី អ័រ ហូឡិន « Tomorrow the Lord Will Do Wonders among You » *Liahona,* ខែ ឧសភា ឆ្នាំ ២០១៦ ទំព័រ ១២៧ ។
៥. ហិនរី ប៊ី អាវរីង « True Friends » *Liahona,* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ២៩ ។
៦. ដើម្បីកម្លាំងនៃយុវជន ( កូនសៀវភៅឆ្នាំ ២០១១ ) ទំព័រ ១៦ ។




# សេចក្ដីណែនាំរបស់កីឡាករលើកទម្ងន់

ដោយ គៀនីនី ម៉ាណូម៉ៅ

កាលខ្ញុំរៀននៅវិទ្យាល័យ គ្រូបង្វឹកលើកទម្ងន់បានសូមខ្ញុំឲ្យចូលរួមកីឡាលើកទម្ងន់ ។ ខ្ញុំបាននិយាយថា « អត់ទេ សូមអរគុណ ! នោះពុំមែនជាអ្វីដែលខ្ញុំចង់ធ្វើទេ » ។

ប៉ុន្តែគាត់នៅតែបន្តសួរខ្ញុំពីរឿងនោះ ។ អស់ពេលជាច្រើនសប្ដាហ៍ ។

នៅទីបំផុត ខ្ញុំបានសាកល្បងកីឡាលើកទម្ងន់នោះ ។ គាត់និយាយត្រូវណាស់ ៖ ខ្ញុំពិតជាចូលចិត្តកីឡាលើកទម្ងន់ណាស់ ។ ប្រាកដណាស់ នៅគ្រាដំបូងវាចម្លែកបន្តិចសម្រាប់ខ្ញុំ ខ្លួនប្រាណរបស់ខ្ញុំពុំធ្លាប់ធ្វើអ្វីដូចនេះពីមុនឡើយ ។ ប៉ុន្តែខ្ញុំរិតតែមានអារម្មណ៍ចូលចិត្តការហាត់ប្រាណបែបនោះ ។ ខ្ញុំក៏ចូលចិត្តមិត្តរួមក្រុមរបស់ខ្ញុំ និងការប្រកួតផងដែរ ។ ហើយខ្ញុំបានចាប់ផ្ដើមធ្វើវាបានយ៉ាងល្អ ។

ឥឡូវនេះ កីឡាលើកទម្ងន់គឺជាផ្នែកដ៏ធំមួយនៃជីវិតខ្ញុំ ។ ខ្ញុំបានហាត់សមវារៀងរាល់ថ្ងៃ យ៉ាងហោចណាស់ពីរទៅបីម៉ោង ដោយលើកទម្ងន់អង្គុយងើបៗ ការលើកទម្ងន់ត្រឹមស្មា បន្ទាប់មកទៀតលើកឲ្យផុតដៃ និងការលើកទម្ងន់ឲ្យផុតដៃនឹងដាក់ចុះមកវិញ ។ ( ហើយប្រសិនបើអ្នកពុំដឹងពីការលើកទាំងនោះ សូមកុំបារម្ភ—ពីដំបូងខ្ញុំក៏អត់ដឹងផងដែរ ! )

ដូចជាកិច្ចការជាច្រើនដែរ កីឡាលើកទម្ងន់ត្រូវការពេលវេលា និងការអត់ធ្មត់ ហើយជួនកាលអាចមាន



*ខគម្ពីរមួយអាចធ្វើឲ្យមានការផ្លាស់ប្ដូរមួយដ៏ធំ—សូម្បីតែនៅក្នុងការប្រកួតកីឡាលើកទម្ងន់ក្ដី ។*

ការពិបាក ។ សំណាងល្អ គ្រួសាររបស់ខ្ញុំលើកទឹកចិត្តខ្ញុំជានិច្ច ទោះបីនៅពេលខ្ញុំរអ៊ូរទាំអំពីការឈឺខ្លួនប្រាណដែលខ្ញុំមានក្ដី ( វាកើតឡើងញឹកញាប់ ) ។ ឪពុករបស់ខ្ញុំត្រៀមចង់ទឹកកក និងពាក្យលើកទឹកចិត្តដល់ខ្ញុំជានិច្ច ពេលខ្ញុំមកដល់ផ្ទះវិញបន្ទាប់ពីការហាត់សម ។ ហើយម្ដាយរបស់ខ្ញុំលះបង់ជានិច្ច ដើម្បីខ្ញុំអាចទៅចូលរួមក្នុងការប្រកួតបាន ។

ពីរបីឆ្នាំមុន ខ្ញុំបានទៅចូលរួមការប្រកួតមួយនៅហ្វីឡាដេហ្វីយ៉ា រដ្ឋភីលសីនៀន ស.រ.អា. ។ ខ្ញុំមានក្ដីរំភើបដើម្បីប្រកួតជាមួយកីឡាកររលើកទម្ងន់មកពីគ្រប់ប្រទេសទាំងអស់ ប៉ុន្តែខ្ញុំព្រួយបារម្ភបន្តិចអំពីការនៅឆ្ងាយពីគ្រួសាររបស់ខ្ញុំ ។ ដើម្បីធ្វើវាឲ្យងាយស្រួល ម្ដាយរបស់ខ្ញុំបានសន្យាថា ផ្ញើសារជាខគម្ពីរ និងសារលិខិតដ៏បំផុសគំនិតរៀងរាល់ថ្ងៃឲ្យខ្ញុំ ។

នៅយប់ពីមុនការប្រកួត ក្មេងៗមួយចំនួនបានធ្វើពីធីជប់លៀងមួយ ។ ខ្ញុំបានគិតថា វាជាការល្អដើម្បីទៅពិធីជប់លៀងនោះ ដូច្នេះមិត្តរួមបន្ទប់របស់ខ្ញុំ និងខ្ញុំបានទៅពិធីជប់លៀងនោះ ។ ប៉ុន្តែរំពេចនោះ ខ្ញុំបានដឹងថា វាពុំមែនជាពិធីជប់លៀងដែលខ្ញុំចូលចិត្តឡើយ ។ មានយុវវ័យដែលផឹកគ្រឿងស្រវឹង ជក់បារី និយាយពាក្យអសុរស និងរាំមិនសមរម្យ ។ ខ្ញុំបានដឹងថា ខ្ញុំមិនគួរទៅទីនោះឡើយ ប៉ុន្តែខ្ញុំបារម្ភខ្លាចមិត្តរួមបន្ទប់គិតចម្លែកពីខ្ញុំ ។ ឬកីឡាកររផ្សេងទៀតអាចគិតចម្លែកពីខ្ញុំ ។

ប៉ុន្តែក្រោយមក មានអ្វីមួយបានផុសក្នុងចិត្តខ្ញុំ ៖

« ចូរឈរនៅក្នុងទីបរិសុទ្ធ » ។

ឃ្លានោះវានៅក្នុងខគម្ពីរដែលខ្ញុំពេញចិត្ត ហើយជាខគម្ពីរមួយដែលម្ដាយរបស់ខ្ញុំបានផ្ញើឲ្យខ្ញុំកាលពីព្រឹក ៖ គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៧:៨ ៖ « ឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ហើយសូមកុំរើឡើយ រហូតដល់ថ្ងៃនៃព្រះអម្ចាស់មកដល់ ដ្បិតមើលចុះ ថ្ងៃនោះនឹងមកដល់យ៉ាងឆាប់រហ័ស ។ អាម៉ែន » ។

ខ្ញុំពុំដឹងពីមូលហេតុដែលម្ដាយខ្ញុំផ្ញើខគម្ពីរនោះឲ្យខ្ញុំនៅថ្ងៃនោះឡើយ ប៉ុន្តែវាជាខគម្ពីរមួយដែលខ្ញុំចូលចិត្តពេញមួយជីវិតរបស់ខ្ញុំ ។ ខ្ញុំបានទន្ទេញវាចាំ តាំងពីអាយុប្រាំបីឆ្នាំ ហើយវារំឭកខ្ញុំម្ដងហើយម្ដងទៀត ហើយមានចិត្តក្លាហាន គោរពប្រតិបត្តិ និងឈរការពារអ្វីដែលខ្ញុំជឿ ។

« ចូរឈរនៅក្នុងទីបរិសុទ្ធ » ។

ខ្ញុំបាននិយាយទៅមិត្តរួមបន្ទប់របស់ខ្ញុំថា « ខ្ញុំទៅហើយ » ។ ខ្ញុំបានពន្យល់អំពីខគម្ពីរដែលម្ដាយខ្ញុំបានផ្ញើឲ្យខ្ញុំកាលពីព្រឹកមិញ ។ « នេះពុំមែនជាកន្លែងដែលខ្ញុំគួរនៅទេ » ។

មិត្តរបស់ខ្ញុំបានប្រាប់ខ្ញុំថា នាងក៏ពុំចង់នៅទីនោះផងដែរ ។ គាត់ពុំមានអារម្មណ៍ល្អដែរ ប៉ុន្តែដោយពុំចង់នៅតែឯង ហើយត្រូវបានគេមើលឃើញថា ជាមនុស្សនៅក្រៅសង្គម ។ នាងបានអរគុណខ្ញុំ ដែលខ្ញុំបាននិយាយនូវអ្វីទាំងនោះ ហើយយើងបានចេញពីពិធីជប់លៀងនោះ ។

នៅព្រឹកបន្ទាប់មក យើងបានដឹងថា មិនយូរប៉ុន្មានបន្ទាប់ពីយើងបានចាកចេញមក ក្មេងៗដែលនៅក្នុងពិធីជប់លៀងនោះត្រូវបានចាប់ខ្លួន ហើយដកចេញពីការប្រកួត ដោយសារការផឹកស្រា និងជក់ថ្នាំញៀន ។

ប្រសិនបើខ្ញុំពុំត្រូវបានបំផុសគំនិតឲ្យចាំខគម្ពីររបស់ម្ដាយខ្ញុំទេ នោះខ្ញុំអាចត្រូវបានដកចេញពីការប្រកួតផងដែរ ។ ទីបំផុតខ្ញុំបានឈ្នះចំណាត់ថ្នាក់លេខមួយ ដូច្នេះខ្ញុំពិតជាមានអំណរគុណណាស់ដែលខ្ញុំបានចូលរួមការប្រកួតនោះ ។ ( ខ្ញុំគិតថា ខ្ញុំថ្លែងអំណរគុណដល់ម្ដាយខ្ញុំរៀងរាល់ថ្ងៃសម្រាប់ការផ្ញើសារទៅខ្ញុំ ) ។

ការឈ្នះការប្រកួតលើកទម្ងន់គឺជាពរជ័យដ៏ច្បាស់ក្រឡែត និងភ្លាមៗ មកពីការរក្សាបទបញ្ញត្តិ ។ ប៉ុន្តែ គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៧:៨ ពុំបានចែងថា « ចូរឈរនៅក្នុងទីបរិសុទ្ធទាំងឡាយ ដូច្នេះអ្នកអាចឈ្នះការប្រកួតលើកទម្ងន់នោះទេ » ។ ហើយ យ៉ូហាន ១៤:១៥ ពុំបានចែងថា « ប្រសិនបើអ្នកចង់បានពរជ័យភ្លាមៗ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំ » ទេ ។ ព្រះអម្ចាស់ប្រទានពរដល់យើង ដោយសារទ្រង់ស្រឡាញ់យើង ។ ហើយយើងព្យាយាមឲ្យបរិសុទ្ធ ហើយគោរពប្រតិបត្តិ ដោយសារយើងទុកចិត្ត និងស្រឡាញ់ព្រះអម្ចាស់ ។■

*អ្នកនិពន្ធរស់នៅរដ្ឋកាលីហ្វញ៉ា ស.រ.អា. ។*

# ដើម្បីឈរឲ្យរឹងមាំ

# *បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ*

*យ៉ូហាន ១៤:១៥*



*ប្រធានយុវនារីទូទៅ ស៊ីស្ទើរ បូនី អេច ខរ៉ដុន ( កណ្ដាល ), ស៊ីស្ទើរ មីឆែល លីន ក្រេក ទីប្រឹក្សាទីមួយ ( ខាងឆ្វេង ) និង ស៊ីស្ទើរ ប៉េបេកា លីន ក្រាវិន ទីប្រឹក្សាទីពីរ ( ខាងស្ដាំ ) ។*



*ប្រធានយុវជនទូទៅ ស្ទីវិន ជ័យុលយូ អូវិន ( កណ្ដាល ), បងប្រុស ដូក្លាស ឌី ហូមស៍ ទីប្រឹក្សាទីមួយ ( ខាងឆ្វេង ), អិម យ៉ូសែប ប្រោហ្វ ទីប្រឹក្សាទីពីរ ( ខាងស្ដាំ ) ។*

## *បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ*

*ដោយគណៈប្រធានយុវនារីទូទៅ*

បាវចនាយុវវ័យប្រចាំឆ្នាំ ២០១៩ គឺជាការហៅឲ្យធ្វើសកម្មភាព—ជាការអញ្ជើញដោយផ្ទាល់ពីព្រះអង្គសង្គ្រោះរបស់យើង ។ តើអ្នកមានការតាំងចិត្តទាំងស្រុងដែរឬទេ ? តើអ្នកស្រឡាញ់ទ្រង់ដែរឬទេ ? តើអ្នកមានឆន្ទៈដើរតាមស្នាមព្រះបាទទ្រង់ដែរឬទេ?

ព្រះអង្គសង្គ្រោះយេស៊ូវគ្រីស្ទរបស់យើងបានធ្វើអ្វីៗសម្រាប់យើង ដែលយើងពុំអាចធ្វើសម្រាប់ខ្លួនយើងបាន ។ តើទ្រង់បានស្នើឲ្យយើងធ្វើអ្វីខ្លះដើម្បីតបស្នងវិញនោះ ? ទ្រង់បានស្នើថា យើងត្រូវគោរពបទបញ្ញត្តិរបស់ទ្រង់ ដើម្បីយើងអាចបានពរ ដោយមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយពួកយើងជានិច្ច ( សូមមើល ម៉ូរ៉ូណៃ ៤:៣ ) ។

បទបញ្ញត្តិគឺជាអំណោយនៃសេចក្ដីស្រឡាញ់ ។ ព្រះអង្គសង្គ្រោះបានមានព្រះបន្ទូលយ៉ាងសាមញ្ញថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » ប៉ុន្តែ *ហេតុអ្វី* ? ដោយសារទ្រង់ស្រឡាញ់ប្អូនៗ ! ទ្រង់សព្វព្រះទ័យឲ្យ *ប្អូនៗ* សប្បាយរីករាយ ។ ទ្រង់សព្វព្រះទ័យឲ្យជីវិត *របស់ប្អូនៗ* ពោរពេញដោយអំណរ និងលទ្ធភាពនានារាប់មិនអស់ ។ ទ្រង់សព្វព្រះទ័យឲ្យ *ប្អូន* មានសុវត្ថិភាព ហើយត្រូវបានការពារពីសេចក្ដីអាក្រក់នៃពិភពលោក ។ ទ្រង់សព្វព្រះទ័យចាក់ព្រះពរលើ *ប្អូន* ដែលច្រើនលើសលុប « ដែលនឹងគ្មានកន្លែងល្មមទុកបានទេ » ( នីហ្វៃទី ៣ ២៤:១០ ) ។ ទ្រង់សព្វព្រះទ័យឲ្យ *ប្អូន* ត្រឡប់ទៅ ហើយរស់នៅជាមួយទ្រង់ម្ដងទៀត និងក្លាយជាអ្នកទទួលទាននូវពរជ័យ *ទាំងអស់* ដែលព្រះវរបិតាសួគ៌បានសន្យា ។

សូមចាំជានិច្ចពីទំហំដែលព្រះវរបិតាសួគ៌ស្រឡាញ់បុត្រាបុត្រីរបស់ទ្រង់ ។ ទ្រង់មានសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះសម្រាប់ប្អូន ។ ប្អូនអាចបង្ហាញសេចក្ដីស្រឡាញ់របស់ប្អូនចំពោះព្រះតាមរយៈការគោរពបទបញ្ញត្តិរបស់ទ្រង់ ។ សកម្មភាពសុចរិតរបស់ប្អូននឹងនាំមកនូវពរជ័យដ៏មហិមាដល់ប្អូន និងអស់អ្នកដែលនៅជុំវិញប្អូន ។

ដូចព្យាការីរបស់យើង ប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ថា ៖ « ពួកយើងត្រូវការប្អូនៗនៅជាមួយយើងនៅក្នុងកងទ័ពយុវវ័យរបស់ព្រះអម្ចាស់នេះ ។ អ្វីៗនឹងមិននៅដដែលទេបើគ្មានប្អូនៗ ! » លោកបានអញ្ជើញប្អូនឲ្យ « ក្រោកឈរឡើង [ ហើយ ] ធ្វើផ្សេងពីពិភពលោក » តាមរយៈការរស់នៅតាមបទដ្ឋាននៅក្នុង *ដើម្បីកម្លាំងនៃយុវជន* និងតាមរយៈការគោរពតាមបទបញ្ញត្តិ—ដើម្បី « មើលឲ្យដូច មានសំឡេងដូច ធ្វើសកម្មភាពដូច និងស្លៀកពាក់ដូចសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ » ( « Hope of Israel » [ ការប្រជុំធម្មនិដ្ឋានយុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ] ទំព័រ ៨ HopeOfIsrael.lds.org ) ។



នៅពេលប្អូនព្យាយាមគោរពតាមព្រះអម្ចាស់ និងពួកព្យាការីរបស់ទ្រង់ នោះអំណាចនៃព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញប្អូន ដោយសេចក្តីស្រឡាញ់របស់ព្រះ ហើយថ្លែងទីបន្ទាល់ដល់ប្អូនអំពីអត្តសញ្ញាណដ៏ទេវភាពរបស់ប្អូន ថាជាបុត្រា ឬបុត្រីរបស់ព្រះ ។ ពរជ័យទាំងនោះរីកចម្រើននៅពេលប្អូនព្យាយាមរស់នៅដោយសុចរិត ។ ព្រះអម្ចាស់ និងព្យាការីទុកចិត្តលើប្អូន ។ ទ្រង់ និងលោកស្រឡាញ់ប្អូន ។ យើងសន្យាថា ទំនុកចិត្ត ការធានាអះអាងដល់ខ្លួនឯង និងការលួងលោមដ៏អស្ចារ្យកើតមានឡើង នៅពេលប្អូនគោរព និងរក្សាបទបញ្ញត្តិ ។

## *ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ*

*ដោយគណៈប្រធានយុវជនទូទៅ*

តើប្អូនធ្លាប់គិតថា « តើខ្ញុំអាចបង្ហាញព្រះវរបិតាសួគ៌ថា ខ្ញុំពិតជាចង់ឲ្យទ្រង់ឆ្លើយតបការអធិស្ឋាន និងប្រទានពរដល់ខ្ញុំដោយរបៀបណា ? » ដែរឬទេ ? ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទបានប្រទានគន្លឹះមួយនៅពេលទ្រង់មានបន្ទូលថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ » ( យ៉ូហាន ១៤:១៥ ) ។

និយាយម្យ៉ាងទៀត គឺយើងបង្ហាញសេចក្តីស្រឡាញ់របស់យើងចំពោះព្រះវរបិតាសួគ៌ ដោយការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។

ជួលកាលចម្លើយពុំត្រូវបានឆ្លើយតបទៅតាមពេលវេលា ឬតាមរបៀបដែលយើងរំពឹងចង់បានឡើយ ហើយយើងអាចត្រូវបានល្បួងឲ្យបោះបង់ ឬឈប់គោរពប្រតិបត្តិ ។ ប៉ុន្តែប្រសិនបើយើងអត់ធ្មត់ ហើយស្តាប់ នោះព្រះអម្ចាស់នឹងឆ្លើយតបតាមពេលវេលា និងតាមរបៀបរបស់ទ្រង់ ។ ទ្រង់ឆ្លើយតបការអធិស្ឋានដ៏សុចរិតជានិច្ច ។ ទ្រង់ប្រទានពរដល់មនុស្សដែលគោរពប្រតិបត្តិជានិច្ច ( សូមមើល ម៉ូសាយ ២:២១–២៤ ) ។

ពិភពលោកបង្រៀនថា សេចក្តីស្រឡាញ់ពុំមានការទទួលខុសត្រូវឡើយ ។ ផ្ទុយទៅវិញ ការនោះមិនពិតទេ ។ សេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ត្រូវបានបង្ហាញតាមរយៈឆន្ទៈ និងភាពឧស្សាហ៍របស់យើងក្នុងការកាន់តាមបទបញ្ញត្តិរបស់ទ្រង់ ។

ព្រះអង្គសង្គ្រោះបានបង្រៀនថា « សេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច » ( យ៉ូហាន ៨:៣២ ) ។ ព្យាការីអាលម៉ាបានប្រកាសបន្ថែមថា « សេចក្តីទុច្ចរិតពុំដែលជាសុភមង្គលឡើយ » ( អាលម៉ា ៤១:១០ ) ។ ហើយតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ នោះព្រះអម្ចាស់បានបង្រៀនថា « មានក្រឹត្យវិន័យមួយដ៏ពុំអាចដកចេញបាន ដែលបានធ្វើនៅឋានសួគ៌ មុនកំណើតលោកិយមកម្ល៉េះ ដែលគ្រប់ព្រះពរទាំងអស់ផ្អែកទៅលើ—ហើយកាលណាយើងបានព្រះពរណាមួយពីព្រះ នោះគឺដោយសារការគោរពដល់ក្រឹត្យវិន័យនោះ ដែលព្រះពរនោះផ្អែកទៅលើ » ( គោលលទ្ធិ និងសេចក្តីសញ្ញា ១៣០:២០–២១ ) ។

សុភមង្គល ពរជ័យ និងការណែនាំកើតឡើងតាមរយៈការគោរពប្រតិបត្តិ ។ ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យអ្នករីករាយ ហើយមានសេរីភាព ដោយសារទ្រង់ស្រឡាញ់អ្នក ហើយថានោះជាមូលហេតុដែលទ្រង់បានប្រទានបទបញ្ញត្តិរបស់ទ្រង់ ។ ដើម្បីស្វែងរកភាពសុខសាន្តដែលពិភពលោកនេះគ្មាន យើងត្រូវតែរៀនថា ការចុះចូលទៅនឹងព្រះទ័យរបស់ព្រះវរបិតាសួគ៌គឺជារបៀបតែមួយគត់ឆ្ពោះទៅកាន់សុភមង្គល ។

ព្រះវរបិតាសព្វព្រះទ័យឲ្យប្អូនស្វែងរកសុភមង្គលអស់កល្បជានិច្ច ។ ពួកព្យាការីរបស់ទ្រង់ចង់ឲ្យប្អូនរកឃើញអំណរដ៏ច្រើនលើសលុប ។ យើងចង់ឲ្យប្អូនរកឃើញភាពសុខសាន្ត ដែលយើងបានរកឃើញនៅក្នុងការធ្វើតាមព្រះអង្គសង្គ្រោះ ។ ដើរលើផ្លូវដែលទ្រង់បានគូស ( សូមមើល « ខ្ញុំនឹងដើរតាមព្រះអង្គ » *ទំនុកតម្កើង* លេខ ១៣៥ ) ។ ចូរជ្រើសរើសគោរពប្រតិបត្តិ ឆន្ទៈរបស់ប្អូនដើម្បីគោរពប្រតិបត្តិនឹងដឹកនាំទៅរកសេរីភាព និងសុភមង្គល ។ ■

# យើស្រឡាញ់ទ្រង់

## ចម្រៀងបាវចនាម៉្យូតឆលប្រចាំឆ្នាំ ២០១៩

ទំនុកច្រៀង និងទំនុកភ្លេងដោយ នីខ ដេយ៍

*ដោយស្វាហាប់* ♩ = 96–108




© 2018 by Intellectual Reserve, Inc. All rights reserved.
បទចម្រៀងនេះ អាចថតចម្លងសម្រាប់ការប្រើប្រាស់ជាបន្ទាប់បន្សំ ការប្រើប្រាស់នៅព្រះវិហារ ឬនៅគេហដ្ឋានដែលពុំមានលក្ខណៈជាពាណិជ្ជកម្មឡើយ ។
សេចក្ដីប្រកាសនេះត្រូវបិទនៅលើសំណៅថតចម្លងនីមួយៗ ។


14
យើង ពេល យើង ដើរ តាម គំ រូ ទ្រង់ ៗ បើ ស្រ ឡាញ់
Gm Dm B♭
17
បើ ស្រ ឡាញ់ ទ្រង់ ត្រូវ ប ង្ហាញ ទ្រង់ ៗ
F Gm Dm
20
យើង នឹង ទៅ ហើយ ប ម្រើ អ្នក ជិត ខាង អស់ ពី ចិត្ត ព្យា
B♭ F Gm7
23
យាម ស្វែង រក ដៃ ដែល រោយ ហើយ ជួយ លើក ឡើង រស់ ឲ្យ ដូច ទ្រង់ ហើយ ធ្វើ តាម ការ
F B♭ F


ប ង្រៀន ទ្រង់ បើ ស្រ ឡាញ់ ទ្រង់ ។ បើ ស្រ ឡាញ់ ទ្រង់ ។ បើ ស្រ ឡាញ់
Gm7 F B♭
1.
2. 3.
ទ្រង់ ។ ទ្រង់ ។
F Gm Dm B♭ F
រំលងទៅខូដា
បើ ស្រ ឡាញ់ ទ្រង់ ។ ពេល ស្រ ឡាញ់
Gm7 Dm7 B♭ C
អ្វី គ្រប់ យ៉ាង ផ្លាស់ ប្តូរ ។ ទ្រង់ ស្រ ឡាញ់ គាំ ទ្រ ។ យើង នឹង យក
Dm B♭ F C


42
រាល់ ក្ដី ស្រ ឡាញ់ ទ្រង់ ប្រ ទាន ដែល ទ្រង់ ប្រ ទាន ហើយ នឹង
Dm
C7
45
ទៅ ហើយ ប ម្រើ អ្នក ជិត ខាង អស់ ពី ចិត្ត ព្យា យាម ស្វែង រក ដៃ ដែល ដោយ ហើយ
F
Gm
Dm
48
ជួយ លើក ឡើង រស់ ឲ្យ ដូច ទ្រង់ ហើយ ធ្វើ តាម ការ ប ង្រៀន ទ្រង់ បើ ស្រ ឡាញ់ ទ្រង់ ។
B♭
F
Gm
Dm
52
D.S. al Coda
យើង នឹង
B♭
53
CODA
rit.
B♭
F
Gm
Dm
rit.
B♭



កើតនៅ **អាមេរិកខេន ហ្វ៊ក រដ្ឋ យូថាហ៍** នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៤៥

បានធ្វើការជា **មេធាវី**

បានគាំទ្រជាសមាជិកក្នុង **កូរ៉ុមនៃពួកសាវកដប់ពីរនាក់** នៅខែ មេសា ឆ្នាំ ២០០៨

នៅអាយុ ១៣ ឆ្នាំ បានជួយ **ដុត នំប៉័ង** បន្ទាប់ពីម្ដាយរបស់លោកបានទទួលការវះកាត់ ។

លោកបានបន្តធ្វើកិច្ចការនោះរហូតដល់លោកបានចូលរៀនមហាវិទ្យាល័យ ។

បានរៀបអាពាហ៍ពិពាហ៍នឹង ខាធើរីន ជេកុប នៅឆ្នាំ ១៩៦៨ នៅ **ព្រះវិហារបរិសុទ្ធ សលត៍ លេក**

មាន **កូន ៥ នាក់** និង **ចៅ ១៦ នាក់**

# ពិធីសាក្រាម៉ង់ និងការប្រែឲ្យកាន់តែដូចព្រះគ្រីស្ទ

**ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

និមិត្តសញ្ញានៃពិធីសាក្រាម៉ង់ក្នុងពេលទទួលទានអាហារយប់ចុងក្រោយរបស់ព្រះអម្ចាស់ គឺជារឿងដ៏អស្ចារ្យដើម្បីសញ្ជឹងគិត ។ នំប៉័ង និងទឹកតំណាងឲ្យព្រះកាយ និងលោហិតរបស់ទ្រង់ដែលជានំប៉័ងជីវិត និងជាទឹករស់ ( សូមមើល យ៉ូហាន ៤:១០ ) ដែលរំឭកយើងយ៉ាងទន់ភ្លន់អំពីតម្លៃដែលទ្រង់បានបង់ថ្លៃក្នុងការប្រោសលោះយើង ។ នៅពេលកាច់នំប៉័ង នោះយើងចងចាំអំពីការទម្លុះសាច់របស់ព្រះអង្គសង្គ្រោះ ។ នៅពេលយើងផឹកទឹក នោះយើងគិតអំពីព្រះលោហិតដែលទ្រង់បានបង្ហូរនៅ សួនច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង និងអំណាចនៃការញែកជាបរិសុទ្ធ ( សូមមើល ម៉ូសេ ៦:៦០ ) ។

ប៉ុន្តែពាក្យប្រៀបធៀបអំពីការទទួលទានព្រះកាយរបស់ទ្រង់ ហើយផឹកលោហិតរបស់ទ្រង់មានអត្ថន័យបន្ថែម ហើយថាត្រូវដាក់គុណសម្បត្តិ និងចរិតលក្ខណៈរបស់ព្រះគ្រីស្ទ ។ នៅពេលយើងទទួលទានសាក្រាម៉ង់ នំប៉័ង និងទឹករាល់សប្ដាហ៍ នោះយើងនឹងធ្វើបានល្អក្នុងការពិចារណាថា តើយើងត្រូវតែដាក់បញ្ចូលចរិតលក្ខណៈរបស់ទ្រង់ និងគំរូនៃជីវិតគ្មានបាបរបស់ទ្រង់មកក្នុងជីវិត និងតួអង្គរបស់យើងឲ្យពេញលេញទាំងស្រុងរបៀបណា ។ ព្រះយេស៊ូវពុំអាចធ្វើដង្វាយធួនសម្រាប់អំពើបាបអ្នកដទៃបានទេ លុះត្រាតែទ្រង់ផ្ទាល់ពុំមានអំពើបាប ។ ដោយសារសេចក្ដីយុត្តិធម៌ពុំបានទាមទារអ្វីពីទ្រង់ នោះទ្រង់អាចប្រគល់ព្រះអង្គទ្រង់ជំនួសយើង ដើម្បីធ្វើឲ្យសេចក្ដីយុត្តិធម៌បានស្កប់ស្កល់ បន្ទាប់មកប្រទាននូវក្ដីមេត្តាករុណា ។ . . .

ការទទួលទានព្រះកាយ ហើយផឹកលោហិតរបស់ទ្រង់មានន័យថា បញ្ឈប់នូវអ្វីដែលពុំត្រូវនឹងចរិតលក្ខណៈដូចជាព្រះគ្រីស្ទក្នុងជីវិតយើងចោល ហើយយកអាកប្បកិរិយារបស់ទ្រង់ដាក់ក្នុងខ្លួនយើងវិញ ។ នេះគឺជាអត្ថន័យដ៏ធំអំពីការប្រែចិត្ត ៖ ពុំគ្រាន់តែងាកចេញពីអំពើបាបអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែ « ការបែរដួងចិត្ត និងឆន្ទៈទៅរកព្រះ » ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការប្រែចិត្ត » ) ។ ព្រះនឹងបង្ហាញដល់យើងនូវគុណវិបត្តិ និងការបរាជ័យនានា ប៉ុន្តែទ្រង់ក៏នឹងជួយយើងបង្វែរភាពទន់ខ្សោយទៅជាខ្លាំងផងដែរ ( សូមមើល អេធើរ ១២:២៧ ) ។ បើយើងសួរដោយស្មោះថា « តើខ្ញុំនៅខ្វះអ្វីទៀត ? » ( ម៉ាថាយ ១៩:២០ ) នោះទ្រង់នឹងពុំទុកឲ្យយើងសង្ស័យឡើយ ប៉ុន្តែទ្រង់នឹងឆ្លើយតបជាប្រយោជន៍សម្រាប់សុភមង្គលរបស់យើងដោយក្ដីស្រឡាញ់ ។ ហើយទ្រង់ប្រទានក្ដីសង្ឃឹមដល់យើង ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំ ២០១៧ ។*

រូបជញ្ជីង វេទិកា នំប៉័ង និងក្បាល រចនារូបភាពដោយ អែនឌ្រូ រ៉ូប៊ើត



បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ
ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំចុះ ។

យ៉ូហាន ១៤:១៥

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យុវមជ្ឈិមវ័យ

## តើមានភាពស្មុគស្មាញក្នុងជីវិតឬ ?

*វគ្គនៃខែនេះគឺជាការជួយដល់អ្នកឲ្យកែលម្អ សុខភាពផ្លូវចិត្ត និងអារម្មណ៍របស់អ្នក ។*

៤២



យ៉ូសែប ស្ម៊ីធ
ការប្រមូលផ្ដុំនៃសេចក្ដីល្អ និងអត្តចរិតរបស់ព្យាការី
២៨

យុវវ័យ
របៀបបួនយ៉ាងដើម្បីក្លាយដូច ព្រះយេស៊ូវគ្រីស្ទ
៥២

បាវចនាម៉្ងូតធលថ្មី
ការអញ្ជើញមួយមកពី ព្រះអង្គសង្គ្រោះ
៥៨

CAMBODIAN
4 02186 01258 5

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ប្រិយមិត្ត

ខែ មករា ឆ្នាំ ២០១៩



ផ្នែកកុមារ
សម្រាប់ប្អូន !

ទស្សនាវដ្ដី ផ្នែកកុមារ ចេញផ្សាយដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



ដោយប្រធាន
រ័សុល អិម ណិលសុន

# រៀនអំពី ព្រះយេស៊ូវ

ព្រះ បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទដើម្បីមកជួយយើង ។ អ្នកអាចមានអំណាចមកពីព្រះយេស៊ូវគ្រីស្ទ នៅពេលអ្នកធ្វើកិច្ចការទាំងនេះ ៖




**សិក្សា** « ព្រះគ្រីស្ទដ៏មានព្រះជន្មរស់ » ។ វាជាទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទមកពីពួកព្យាការី និងពួកសាវក ។



**ការរៀនសូត្រអំពីព្រះអង្គសង្គ្រោះ ។** ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានអាន ហើយគូសបន្ទាត់ពីក្រោម *ខគម្ពីរទីមួយៗ* នៅក្នុងព្រះគម្ពីរអំពីព្រះយេស៊ូវគ្រីស្ទ ។ ពេលខ្ញុំបានអានចប់ ខ្ញុំបានប្រាប់ភរិយារបស់ខ្ញុំថា « បងជាមនុស្សផ្សេងម្នាក់ ! »



**ចូរមានឆន្ទៈការពារ** បញ្ចេញមតិ ហើយធ្វើខុសពីមនុស្សនៃលោកិយ ។

**ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ! អំណាចរបស់ទ្រង់មានសម្រាប់ពួកអ្នកគ្រប់គ្នា ។**



**សូមព្យាយាមមើលទៅកាន់ទ្រង់** គ្រប់ ទាំង គំនិត ( សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៦:៣៦ ) ។ នៅពេលអ្នកធ្វើដូច្នោះ នោះភាពសង្ស័យ និងការភ័យខ្លាចរបស់អ្នកនឹងរលាយបាត់អស់ ។



**ចុះសេចក្ដីសញ្ញាពិសិដ្ឋ** និងរក្សាសេចក្ដីសញ្ញាទាំងនោះ ។

*ដកស្រង់មកពី « ការទាញយកព្រះចេស្ដានៃព្រះយេស៊ូវគ្រីស្ទមកក្នុងជីវិតរបស់យើង »* Liahona, *ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ៣៩–៤២ ។*

គំនូរដោយ ប្រេឌិន ជឹង

# សូមជួយឲ្យសួនដំណាំរបស់យើងលូតលាស់ឡើង !

កាលព្រះយេស៊ូវគ្រីស្ទគង់នៅលើផែនដី ទ្រង់មានព្រះទ័យសប្បុរសចំពោះមនុស្សដទៃជានិច្ច ។ នៅពេលយើងមានចិត្តសប្បុរស នោះយើងកំពុងធ្វើតាមទ្រង់ ។

ដូចជាដំណាំផ្សេងៗជាច្រើនទៀតដែរ ផ្កា និងបន្លែត្រូវបានដាំនៅក្នុងសួន នោះយើងអាចមានចិត្តសប្បុរសក្នុងរបៀបជាច្រើន ។

**ឆ្នាំនេះយើងកំពុងដាំដំណាំក្នុងសួននៃសេចក្ដីសប្បុរស** ! នៅពេលអ្នកបង្ហាញសេចក្ដីសប្បុរសដល់នរណាម្នាក់ សូមសរសេរវានៅលើរូបផ្កា ដើមដំបងយក្ស ស្លឹកឈើ ដំណាំ បន្លែ ឬសត្វល្អិតនៅក្នុងសួនដែលមានប្រយោជន៍ ! បន្ទាប់មកផ្ញើវាមកកាន់ពួកយើង ។ គម្របខាងក្រោយនឹងប្រាប់អ្នកអំពីរបៀបផ្ញើវា ។ ឬធ្វើសួនសប្បុរសដោយផ្ទាល់ដៃអ្នក ហើយផ្ញើរូបថតរបស់អ្នកដែល « កំពុងធ្វើការ » នៅក្នុងសួននោះមកកាន់ពួកយើង !






*យ៉ូហាន ១៥:១២

កុមារថ្នាក់អង្គការបឋមសិក្សានៅ អូសាន់ ស្តេត ប្រទេស នីស្សេរីយ៉ា បានធ្វើផ្កាដើម្បីដាក់ទៅក្នុងសួននៃសេចក្ដីសប្បុរស !



# ដំណាំនៃទីបន្ទាល់

*តើការមានទីបន្ទាល់មួយមានន័យដូម្ដេច ?*

ដោយ ម៉ារីសា ដេននីស
ទស្សនាវដ្ដី សាសនាចក្រ
ផ្អែកទៅលើដំណើររឿងពិត



អេលីសាបានដើរចូលទៅក្នុងថ្នាក់អង្គការបឋមសិក្សា ហើយអង្គុយនៅក្បែរមិត្តរបស់នាងឈ្មោះអាម៉ានដូ ។

បងស្រីរ៉ូសូបាននិយាយថា « សូមស្វាគមន៍ ! ។ សូមចាប់ផ្ដើមដោយការច្រៀងចម្រៀង » ។

អេលីសាបានច្រៀងជាមួយសិស្សក្នុងថ្នាក់ ។ « ជំនឿគឺដូចជាគ្រាប់ពូជ ៖ បើដាំ វានឹងដុះឡើង » (*សៀវភៅចម្រៀងកុមារ* លេខ ៥០) ។

បងស្រីរ៉ូសូបានចែកក្រដាស និងខ្មៅដៃ ។ គាត់បាននិយាយថា « សូមគិតអំពីអ្វីដែលយើងបានច្រៀង ។ នៅពេលប្អូនៗដាំគ្រាប់ពូជនៃសេចក្ដីជំនឿរបស់ប្អូនៗ នោះវានឹងដុះឡើងទៅជាទីបន្ទាល់មួយ ។ ឥឡូវនេះ សូមគូររូបភាពនៃទីបន្ទាល់របស់ប្អូនថា វាមានសភាពដូចម្ដេច ប្រសិនបើវាគឺជាដំណាំមួយ » ។

អេលីសាបានសម្លឹងមើលក្រដាសទទេ ស្អាតរបស់នាង ។ កុមារផ្សេងទៀតបានចាប់ផ្ដើមគូរគំនូរ ។ អេលីសាក្រឡេកមើលគំនូររបស់អាម៉ានដូ ។ ដំណាំរបស់គាត់មានគល់ត្រង់ដែលមានស្លឹកជាច្រើន ។ វាដូចជារូបដើមជីរនៅលើរាលហាលនៅផ្ទះរបស់នាង ។ ទីបន្ទាល់របស់នាងប្រហែលជាមានសភាពដូច្នេះផងដែរ ! នាងបានក្ដាប់ខ្មៅដៃ ហើយគូរគំនូរមួយដូចអាម៉ានដូផងដែរ ។

បងស្រីរ៉ូសូបាននិយាយថា « សូមបើកគម្ពីររបស់ប្អូនៗទៅ អាលម៉ា ៣២ » ។

ពួកគេបានអានអំពីការដាំគ្រាប់ពូជនៅក្នុងចិត្តរបស់អ្នក ហើយទទួលអារម្មណ៍នៃរីកលូតលាស់របស់វា ។ អេលីសាបានសម្លឹងមើលដំណាំនៃទីបន្ទាល់របស់នាង ។ *តើ* នាងមានទីបន្ទាល់ដែរឬទេ ? តើនោះមានន័យយ៉ាងណាដែរ ? នាងចង់សួរ ប៉ុន្តែមានអារម្មណ៍ខ្មាសអៀន ។

ពេលចប់ថ្នាក់ បងស្រីរ៉ូសូបានមករកអេលីសា ។

បងស្រីរ៉ូសូបានសួរថា « មើលទៅប្អូនដូចជាបែកអារម្មណ៍ ។ តើប្អូនមានរឿងអ្វីទៅ ? »

អេលីសាបានមើលទៅគំនូររបស់នាងម្ដងទៀត ។ « ខ្ញុំពុំប្រាកដចិត្តថា ខ្ញុំមានទីបន្ទាល់មួយឬអត់នោះទេ ។ ខ្ញុំពុំដឹងថា វាមានន័យយ៉ាងណានោះទេ » ។

បងស្រីរ៉ូសូបានញញឹមដាក់អេលីសា ។ « វាមិនអីនោះទេ ។ តើប្អូនចាំថា សេចក្ដីជំនឿជាអ្វីទេ ? »

អេលីសាបានងក់ក្បាល ។ « ការជឿទៅលើអ្វីមួយដែលយើងមើលមិនឃើញ ? »

បងស្រីរ៉ូសូបាននិយាយថា « ត្រឹមត្រូវហើយ ។ តើប្អូនជឿលើអ្វីខ្លះ ? »

នោះគឺជាសំណួរងាយស្រួលមួយ ។ « ខ្ញុំជឿទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ ខ្ញុំដឹងថា ពួកទ្រង់ស្រឡាញ់ខ្ញុំ » ។

បងស្រីរ៉ូសូបានញញឹម ។ « ប្អូនទើបតែចែកចាយទីបន្ទាល់របស់ប្អូន ! ទីបន្ទាល់គឺជាអ្វីដែលប្អូនជឿអំពីដំណឹងល្អ » ។

អេលីសាបានគិតអំពីរឿងនោះ ។ « ដូច្នេះខ្ញុំមានទីបន្ទាល់មួយរួចទៅហើយមែនទេ ? »

« ចាស៎ ! » បងស្រីរ៉ូសូបានជួយបើកខគម្ពីររបស់នាង ។ « តើប្អូនចាំពីអ្វីដែលយើងបានអាននៅថ្ងៃនេះទេ ? ប្អូនចិញ្ចឹមបីបាច់គ្រាប់ពូជតាមរយៈការធ្វើកិច្ចការដូចជា ការមកព្រះវិហារ ។ នោះទីបន្ទាល់របស់ប្អូននឹងរីកដុះដាលខ្លាំងឡើងៗ » ។

អេលីសាមានអារម្មណ៍ថា នាងដូចជាយល់ហើយ ។ « ដូច្នេះ នោះជាមូលហេតុដែលយើងគូររូបភាពនៃទីបន្ទាល់របស់យើងដូចជាដំណាំមួយមែនទេ ?

បងស្រីរ៉ូសូបាននិយាយថា « ប្រាកដណាស់ ។ ដោយសារដំណាំលូតលាស់ឡើងបន្តិចម្ដងៗ ។ ទីបន្ទាល់ក៏ដូចគ្នាផងដែរ ។ ទីបន្ទាល់ពុំកើតឡើងក្នុងពេលតែមួយឡើយ ។ ទីបន្ទាល់រីកលូតលាស់បន្តិចម្ដងៗ ។

អេលីសាមានអារម្មណ៍ល្អជាងមុនអំពីដំណាំដែលនាងបានគូរ ។ នៅពេលនាងទៅដល់ផ្ទះ នាងបានសរសេរថា « ដំណាំនៃទីបន្ទាល់របស់ខ្ញុំ » នៅជាប់នឹងគំនូររបស់នាង ។ នាងបានព្យួររូបគំនូរនោះនៅក្បែរគ្រែរបស់នាង ។ នាងបានដឹងថា ទីបន្ទាល់របស់នាងកំពុងតែលូតលាស់ ។ ហើយនាងចង់បន្តធ្វើតាមព្រះយេស៊ូវ ដើម្បីឲ្យវាអាចរីកលូតលាស់កាន់តែធំឡើងៗ ! ●

រចនារូបភាពដោយ ការ៉ូលីណា ហ្វាមៀរ


ការធ្វើឲ្យ **ទីបន្ទាល់** របស់អ្នក
លូតលាស់
ទីបន្ទាល់
គឺជាអ្វីដែលអ្នកជឿថាពិត ដូចជា
« ព្រះស្រឡាញ់ខ្ញុំ » ឬ « ខ្ញុំជឿថា ក្រុមគ្រួសារអាចរស់នៅ
ជាមួយជានិរន្តរ៍ » ។
ឫស
ធ្វើឲ្យដំណាំរឹងមាំ ។ សូមរក្សា
ទីបន្ទាល់របស់យើងឲ្យរឹងមាំ តាមរយៈការចងចាំ
ដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវរៀងរាល់ថ្ងៃ !
ដំណាំត្រូវការ
ទឹក និងពន្លឺព្រះអាទិត្យដើម្បីលូតលាស់ ។
ព្រះគម្ពីរ ការអធិស្ឋាន និងព្រះវិហារគឺដូចជាទឹក និងពន្លឺ
សម្រាប់ទីបន្ទាល់របស់អ្នក ។
ដូចជាដំណាំដែរ
ទីបន្ទាល់របស់មនុស្សគ្រប់គ្នានឹងលូតលាស់ក្នុងល្បឿន
មួយផ្សេងៗគ្នា ។ ព្រះវរបិតាសួគ៌សព្វព្រះទ័យ នៅពេលចំណេះដឹង
របស់អ្នកលូតលាស់សូម្បីតែតិចតួចក្តី ។

# គ្រាប់ពូជនៃសេចក្តីជំនឿ

ការីអាលម៉ាបានប្រៀបធៀបការរីកចម្រើននៃទីបន្ទាល់ទៅនឹងការដាំគ្រាប់ពូជមួយ ( សូមមើល អាលម៉ា ៣២ ) ។ នៅពេលអ្នកអធិស្ឋាន អានព្រះគម្ពីរ និងជួយមនុស្សដទៃ នោះសេចក្តីជំនឿរបស់អ្នកនឹងរីកដុះដាលឡើង ! សូមសាកល្បងការពិសោធន៍នេះដើម្បីមើលពន្លកនៃគ្រាប់ពូជ ។

**អ្វីដែលអ្នកនឹងត្រូវការ ៖**



គ្រាប់សណ្តែក ( ប្រភេទណាក៏បាន )

ក្រដាសជូត

ថង់ជ័រថ្លាដែលអាចបិទភ្ជិតបាន

១ សូមដាក់ក្រដាសជូតនៅក្នុងថង់ជ័រ ។ ដាក់គ្រាប់សណ្តែកនៅពីលើក្រដាសជូត ហើយបិទថង់នោះ ។

២ ដាក់ថង់នោះនៅកន្លែងមានពន្លឺព្រះអាទិត្យ ។ ប្រហែលជាមួយសប្តាហ៍ក្រោយមក គ្រាប់សណ្តែកចាប់ផ្តើមចេញពន្លក !

៣ សូមទុកឲ្យវាបន្តលូតលាស់មួយរយៈ ។ នៅពេលអ្នកឃើញវាមានឫស សូមយកវាទៅដាំនៅលើដី ។ សូមស្រោចទឹក និងដាក់វាឲ្យត្រូវពន្លឺព្រះអាទិត្យ ហើយមើលថា តើវានឹងលូតលាស់ប៉ុណ្ណា !



## ការផ្គូផ្គងដំណាំ

ទីបន្ទាល់របស់មនុស្សម្នាក់ៗរីកដុះដាលផ្សេងៗគ្នា ។ តើអ្នកអាចផ្គូផ្គងដំណាំនីមួយៗទៅនឹងស្រមោលរបស់វាបានដែរឬទេ ?



# ជំនឿ

និពន្ធទំនុកច្រៀង ៖ ប៊េតទ្រីស ហ្គោស ដេកសិន
និពន្ធបទភ្លេង ៖ ម៉ាយខល ហ្វីនលីសិន ម៉ូឌី

ដោយជឿជាក់ ♩ = ៨០–៩២




© 2019 by Intellectual Reserve, Inc. All rights reserved.
បទចម្រៀងនេះអាចថតចម្លងយកមកប្រើប្រាស់ម្ដងម្កាល តែពុំមែនសម្រាប់ធ្វើជាអាជីវកម្មនៅតាមផ្ទះ និងសាសនាចក្រឡើយ ។
សេចក្ដីប្រកាសនេះត្រូវបិទនៅលើសំណៅថតចម្លងនីមួយៗ ។

# សួស្ដី មកពី ប្រទេស ហ្វីលីពីន !






ឆ្នាំនេះយើងកំពុងធ្វើដំណើរជុំវិញពិភពលោកដើម្បីរៀនអំពីបុត្រាបុត្រីរបស់ព្រះ ។ សូមចូលរួមជាមួយពួកយើង ពេលយើងទៅលេងប្រទេសហ្វីលីពីន !



មានប្រជាជនប្រហែលជាមួយរយលាននាក់រស់នៅប្រទេសហ្វីលីពីន ដែលមានសត្វដ៏គួរឲ្យចាប់អារម្មណ៍ជាច្រើន !








មានភាសាធំៗចំនួនប្រាំបីត្រូវបាននិយាយនៅប្រទេសហ្វីលីពីន ។ ព្រះគម្ពីរមរមនត្រូវបានបោះពុម្ពជាភាសាមួយហៅថាសេប៊ូអាណូ ។




តើអ្នកទៅព្រះវិហារដោយរបៀបណា ? នៅប្រទេសហ្វីលីពីនគ្រួសារមួយចំនួនជិះឡានម៉ាកស៊ីបវែងជាយានជំនិះ !



នេះជាចិញ្ចៀន ជ.ផ.ត. ជាភាសាមួយរបស់ហ្វីលីពីនហៅថាតាកាឡុក ។ នេះជារបៀបនិយាយថា « ជ្រើសផ្លូវត្រូវ » ៖ *piliin ang tama* ។



នេះគឺជាព្រះវិហារបរិសុទ្ធនៅទីក្រុងសេប៊ូ និងម៉ានីល ។ ហើយសូមមើលមានអ្វីទៀត ? ព្រះវិហារបរិសុទ្ធទីពីរកំពុងសាងសង់នៅទីក្រុងម៉ានីល ! ហើយព្រះវិហារបរិសុទ្ធក៏កំពុងត្រូវបានសាងសង់នៅក្នុងទីក្រុងពីរបន្ថែមទៀតគឺទីក្រុងអ៊ូដានេតា និង កាយ៉ាយ៉ាន ឌឺ អូរ៉ូ ។



កុមារហ្វីលីពីនលេងល្បែងកម្សាន្តមួយហៅថា *luksong tinik* ឬ « ការលោតរំលងបន្លា » ។ កុមារម្នាក់ ឬពីរនាក់អង្គុយលើកម្រាលឥដ្ឋ ហើយដាក់ជើង និងដៃរបស់ពួកគេគរលើគ្នា ។ បន្ទាប់មកកុមារផ្សេងទៀតព្យាយាមលោតរំលងលើវាដោយពុំឲ្យប៉ះដៃ ឬជើងនោះឡើយ ។

## សូមជួបជាមួយមិត្តភក្តិមួយចំនួនរបស់យើងមកពីប្រទេសហ្វីលីពីន !



« ខ្ញុំទន្ទឹងចាំការអានព្រះគម្ពីររបស់យើងជាគ្រួសារនៅពេលល្ងាច ។ ខ្ញុំមានអារម្មណ៍ល្អជានិច្ច ពេលខ្ញុំអានព្រះគម្ពីរ » ។

**ឡានទៀ ឌី អាយុ ១០ ឆ្នាំ ទីក្រុងសេនត្រុល លូស្សូន ប្រទេសហ្វីលីពីន**



« នៅគ្រាដំបូងដែលខ្ញុំរៀនអានអក្សរ ខ្ញុំមានអារម្មណ៍កើតទុក្ខ ដោយសារខ្ញុំពុំអាចអានបានលឿនឡើយ ។ ឪពុកម្ដាយ និងបងស្រីខ្ញុំបានជួយខ្ញុំ ហើយឥឡូវនេះ ខ្ញុំរំភើបចិត្តនឹងអានព្រះគម្ពីរណាស់ » ។

**អាគូមែន អាយុ ៧ ឆ្នាំ ទីក្រុង សេនត្រុល លូស្សូន ប្រទេសហ្វីលីពីន**

តើប្អូនមកពីប្រទេសហ្វីលីពីនឬ ? សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូនៗ ។






រូបថតឡានស៊្រីបវែងមកពី GETTY IMAGES; រចនារូបភាពដោយ ខាទី ម៉ាក់ឌី

# មូលនិធិបេសកកម្ម ការ៉េមទឹកកក

**ដោយ ម៉ាកខេនណា ភ្លាក**

ផ្អែកទៅលើដំណើររឿងពិត



*« ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ចូរឲ្យចំណីដល់ហ្វូងចៀមខ្ញុំសុីផង » ( យ៉ូហាន ២១:១៧ ) ។*

យ៉ារេឌបានដើរពីព្រះវិហារទៅផ្ទះវិញនៅក្រោមកម្ដៅថ្ងៃដ៏ក្ដៅជាមួយម្ដាយ និងឪពុកគាត់ ។ គាត់បានគិតអំពីមេរៀនថ្នាក់អង្គការបឋមសិក្សារបស់គាត់ ។ ដោយសារតែគាត់ពុំអាចស្ដាប់ឮបានល្អ នោះយ៉ារេឌបានមើលយ៉ាងយកចិត្តទុកដាក់ទៅលើរូបភាពដែលគ្រូបង្រៀនរបស់គាត់បង្ហាញ និងអក្សរដែលគ្រូបង្រៀនបានសរសេរនៅលើក្ដារខៀន ។

នៅថ្ងៃនោះពួកគេបានរៀនថា ព្រះយេស៊ូវបានសូមឲ្យពួកសិស្សរបស់ទ្រង់ធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ យ៉ារេឌបានឆ្ងល់ថា តើគាត់អាចធ្វើអ្វីខ្លះដើម្បីចែកចាយដំណឹងល្អដូចព្រះយេស៊ូវបានសុំឲ្យធ្វើ ។ គាត់ដឹងថា គាត់មិនអាចបម្រើបេសកកម្មបាននៅឡើយទេ ។ ក្រោយមក គាត់មានគំនិតដ៏អស្ចារ្យមួយ ។ ប្រហែលជាគាត់អាចចាប់ផ្ដើមសន្សំប្រាក់សម្រាប់បេសកកម្ម !

ពេលគាត់ទៅដល់ផ្ទះ យ៉ារេឌបានរត់កាត់សត្វពពែចិញ្ចឹមដែលមានពណ៌ត្នោតរបស់គាត់ ហើយចូលទៅក្នុងផ្ទះ ។ គាត់បានយកក្រឡដ៏រធំមួយ ហើយគាត់បានចោះរន្ធមួយនៅខាងលើវាដោយប្រុងប្រយ័ត្ន ។ គាត់បានសរសេរថា « មូលនិធិបេសកកម្ម » នៅខាងកៀនៗ ។ បន្ទាប់មក គាត់បានទៅបន្ទប់របស់គាត់ ហើយយកប្រាក់គាត់ពីក្រោមគ្រែ ។ គាត់បានទម្លាក់កាក់ប្រាក់នោះម្ដងមួយៗ ។ ប៉ុន្តែកាក់ប្រាក់ទាំងអស់របស់គាត់ពុំពេញបាតក្រឡនោះទេ ។ តើគាត់អាចរកប្រាក់បន្ថែមទៀតតាមរបៀបណា ?

យ៉ារេឌបានគិតហើយគិតទៀត ។ គាត់បានក្រឡេកមើលទៅពន្លឺព្រះអាទិត្យនៅក្រៅបង្អួច ។ វាមានអាកាសធាតុក្ដៅណាស់នៅប្រទេសហ្វីលីពីន ។ យ៉ារេឌ និងមិត្ត



របស់គាត់បានញុំាការ៉េមទឹកកករសជាតិដូងស្ទើរតែរៀងរាល់រសៀលក្រោយចេញពីសាលារៀន ។ គាត់បានគិតថា « នោះហើយជារបៀបរកប្រាក់ ! » ប្រហែលជាគាត់អាចធ្វើការ៉េមទឹកកក ហើយលក់វាឲ្យមនុស្សដទៃទៀតដែលចង់ត្រជាក់ ។

យ៉ាវេឌបានរត់ទៅរកម្ដាយ ។ យ៉ាវេឌបានធ្វើកាយវិការ « តើម៉ាក់អាចបង្ហាញកូនអំពីរបៀបធ្វើការ៉េមទឹកកកបានទេ ? » ។ ពួកគេបានប្រើកាយវិការ កាយវិការគឺជាភាសាមួយដែលអ្នកនិយាយជាមួយដោយប្រើដៃរបស់អ្នក ។ ម៉ាក់បានញញឹម ហើយងក់ក្បាល ។

នៅថ្ងៃបន្ទាប់ យ៉ាវេឌ និងម៉ាក់បានដើរទៅផ្សារធំមួយ ហើយបានទិញគ្រឿងគ្រៅទាំងអស់ ។ ពេលពួកគេទៅដល់ផ្ទះវិញ យ៉ាវេឌបានដកយកចានគោមធំមួយ ហើយលាយខ្ទិះដូង ទឹកដោះគោខាប់ វ៉ាន់នីឡា និងចំណិតដូងជាមួយគ្នា ។ ម្ដាយ និងយ៉ាវេឌបានប្រើជីឡាវដើម្បីចាក់ល្បាយដែលបានលាយនោះទៅក្នុងថង់តូចៗ ។ ពួកគេបានដាក់ថង់ទាំងនោះចូលទៅក្នុងទូរទឹកកក ។ ម៉ាក់បានធ្វើកាយវិការ « អស្ចារ្យណាស់ ! » ។

ការ៉េមទឹកកកត្រូវចំណាយពេលយូរដើម្បីកក ។ ប៉ុន្តែនៅថ្ងៃបន្ទាប់ ក្រោយពីមកពីសាលាវិញ ការ៉េមបានកក ! យ៉ាវេឌបានឡើងលើកៅអី ហើយបានយកធុងទឹកកកពណ៌សពីលើដំបូលទូរទឹកកក ។ គាត់បានដាក់ក្រដាសមួយចំនួននៅបាតធុងទឹកកកនោះ ហើយតម្រៀបការ៉េមនៅពីលើវា ។ គាត់ទន្ទឹងរង់ចាំដើម្បីលក់វា ។

យ៉ាវេឌបានរត់ចេញទៅផ្លូវដែលមានដីហុយ ។ មិត្តរបស់គាត់កំពុងលេងខ្លែងដែលពួកគេធ្វើ និងលេងគប់កំប៉ុងដោយស្បែកជើងផ្ទាត់ ។

នៅចិញ្ចើមផ្លូវនោះ គាត់បានរៀបតុមួយដោយដាក់ស្លាកថា « ការ៉េមទឹកកក ១ ថ្លៃ ៥ ប៉េសូ » ។ មិត្តរបស់គាត់ឈ្មោះចូណែលបានរត់មក ហើយចង្អុលទៅធុងទឹកកកនោះ ។ គាត់បានឲ្យកាក់ប្រាក់ ៥ ប៉េសូទៅយ៉ាវេឌ ហើយយ៉ាវេឌបានឲ្យការ៉េមខ្លះទៅគាត់ ។ ពួកគេបានលើកដៃហាយហ្វាយ ។

មិនយូរប៉ុន្មានក្រោយមក មិត្តភក្ដិជាច្រើនទៀតរបស់យ៉ាវេឌបានមកទិញការ៉េមនោះដែរ ។ ពីរបីម៉ោងក្រោយមក ពេលម៉ាក់បានហៅយ៉ាវេឌញុំាអាហារពេលល្ងាចនោះនៅសល់ការ៉េមតែពីរបីថង់ប៉ុណ្ណោះ ។

យ៉ាវេឌបានលើកធុងទឹកកកដែលជិតអស់ការ៉េមនោះ និងកាក់ប្រាក់ ។ នៅក្នុងហោប៉ៅមួយរបស់គាត់ គាត់បានដាក់កាក់ប្រាក់មួយចំនួនសម្រាប់ថ្វាយដង្វាយមួយភាគក្នុងដប់របស់គាត់ ។ គាត់បានដាក់កាក់ប្រាក់ដែលនៅសល់ទៅក្នុងហោប៉ៅម្ខាងទៀតរបស់គាត់ ។ គាត់ទន្ទឹងរង់ចាំឃើញធនាគារមូលនិធិបេសកកម្មរបស់គាត់ពេញ ។

នៅផ្ទះ គាត់បានទម្លាក់កាក់ប្រាក់មូលនិធិបេសកកម្មរបស់គាត់លើគំនរកាក់ប្រាក់នៅបាតក្រឡនោះ ។ នៅមានកន្លែងច្រើនទៀតដែលត្រូវបំពេញ ! ប៉ុន្តែយ៉ាវេឌមានអារម្មណ៍កក់ក្ដៅក្នុងចិត្ត នៅពេលគាត់គិតអំពីការបម្រើបេសកកម្មនៅថ្ងៃខាងមុខ ។ គាត់បានសម្រេចចិត្តថា គាត់នឹងលក់ការ៉េមទឹកកករៀងរាល់ថ្ងៃរហូតដល់មានប្រាក់ពេញក្រឡរបស់គាត់ ។ វាជាអារម្មណ៍ល្អមួយដើម្បីរកប្រាក់ ដូច្នេះគាត់អាចក្លាយជាអ្នកផ្សព្វផ្សាយសាសនាដូចព្រះយេស៊ូវបានសូមឲ្យគាត់ធ្វើ ។ ●

*អ្នកនិពន្ធបានបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅប្រទេសហ្វីលីពីន ហើយឥឡូវនេះរស់នៅក្នុងរដ្ឋវឺជីញ៉ា ស.រ.អា. ។*




រចនារូបភាពដោយ ដាណា ប៊ុកវ៉ីន

# តារាងអំណានព្រះគម្ពីរសញ្ញាថ្មី





នៅឆ្នាំនេះ អ្នកអាចស្គាល់ព្រះយេស៊ូវកាន់តែច្បាស់ឡើង។ នៅពេលអ្នកអានព្រះគម្ពីរសញ្ញាថ្មី ! រៀងរាល់សប្ដាហ៍ អ្នកអាចត្រៀមខ្លួនរួចជាស្រេចសម្រាប់មេរៀនថ្នាក់អង្គការបឋមសិក្សារបស់អ្នក តាមរយៈការអានខគម្ពីរនានាដែលមាននៅលើទំព័រ ៦១៤ ។ សូមផាត់ពណ៌នៅក្នុងប្រលោះនានា បន្ទាប់ពីអ្នកអានរួច ។





រចនារូបភាពដោយ ជេមី ស្ទូ សាន់ឌឺរ

# តារាងអំណានព្រះគម្ពីរសញ្ញាថ្មី

ខគម្ពីរទាំងនេះត្រូវគ្នានឹងការអានប្រចាំសប្ដាហ៍សម្រាប់កម្មវិធីសិក្សាឆ្នាំ ២០១៩ ។

**១.** ម៉ាថាយ ២៥:១–៤, ៨–១៣

**២.** លូកា ១:៣០–៣៨

**៣.** លូកា ២:៤០–៤៩, ៥២

**៤.** យ៉ូហាន ១:១–៥

**៥.** ម៉ាថាយ ៣:១១–១៧

**៦.** ម៉ាថាយ ៤:១–១០

**៧.** យ៉ូហាន ៣:១–៥, ១៤–១៧

**៨.** ម៉ាថាយ ៥:១៤–១៦

**៩.** ម៉ាថាយ ៦:៥–៨

**១០.** ម៉ាកុស ៤:៣៥–៤១

**១១.** ម៉ាថាយ ១២:៦–១៣

**១២.** ម៉ាថាយ ១៣:១–៩

**១៣.** ម៉ាថាយ ១៤:២២–៣១

**១៤.** ម៉ាថាយ ១៦:១៣–១៩

**១៥.** ម៉ាថាយ ១៧:១៤–២០

**១៦.** យ៉ូហាន ២០:១០–១៨

**១៧.** លូកា ១០:៣០–៣៧

**១៨.** យ៉ូហាន ១០:៩–១៨

**១៩.** លូកា ១៧:១១–១៩

**២០.** ម៉ាកុស ១០:១៣–២២

**២១.** ម៉ាថាយ ២១:១២–១៧

**២២.** ម៉ាថាយ ២៥:៣១–៤០

**២៣.** យ៉ូហាន ១៣:៣៣–៣៥

**២៤.** ម៉ាកុស ១៤:២២–២៤

**២៥.** លូកា ២៣:៣២–៣៤, ៣៩–៤៣

**២៦.** យ៉ូហាន ២០:២៤–២៩

**២៧.** កិច្ចការ ៩:១–៦, ១៨–២០

**២៨.** កិច្ចការ ៣:១–១០

**២៩.** កិច្ចការ ១២:៥–១១

**៣០.** កិច្ចការ ១៧:២២–៣១

**៣១.** កិច្ចការ ២៦:១២–២០

**៣២.** រ៉ូម ៦:៣–១១

**៣៣.** រ៉ូម ១០:១៣–១៧

**៣៤.** កូរិនថូសទី ១ ២:១១–១៤

**៣៥.** កូរិនថូសទី ១ ១៣:១–៨

**៣៦.** កូរិនថូសទី ១ ១៥:១៣–២២

**៣៧.** កូរិនថូសទី ២ ១:៣–៧

**៣៨.** កូរិនថូសទី ២ ៩:៦–៩

**៣៩.** កាឡាទី ៦:១–១០

**៤០.** អេភេសូរ ២:៤–១០

**៤១.** អេភេសូរ ៦:១០–១៨

**៤២.** កូល៉ុស ២:២–៧

**៤៣.** ថែស្សាឡូនីចទី ២ ៣:៧–១៣

**៤៤.** ធីម៉ូថេទី ២ ៣:១៤–១៧

**៤៥.** ហេព្រើរ ១:២–១០

**៤៦.** ហេព្រើរ ៧:១–៦

**៤៧.** យ៉ាកុប ៣:១–១០

**៤៨.** ពេត្រុសទី ១ ៣:១២–១៨

**៤៩.** យ៉ូហានទី ១ ៥:២–៥

**៥០.** វិវរណៈ ៥:១–១០

**៥១.** លូកា ២:៤–១២

**៥២.** វិវរណៈ ១២:៧–១១

ខ្ញុំអាចអធិស្ឋានគ្រប់ពេលគ្រប់ទីកន្លែងអំពីអ្វីៗ
ទាំងអស់ ។ ព្រះវរបិតាសួគ៌ព្រះសណ្ដាប់ ហើយ
ឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ។



# ប្រធានបាឡឹដទស្សនកិច្ចនៅរដ្ឋតិចសាស ស.រ.អា

*ពួកសាវកធ្វើដំណើរជុំវិញពិភពលោក ដើម្បីផ្ដល់ការងារបម្រើដល់មនុស្ស ហើយបង្រៀនពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។*

នៅពេលព្យុះដ៏ខ្លាំងដែលហៅថា ហើរីខេន ហារី បានបោកបក់នៅទីក្រុងហូស្តុន រដ្ឋតិចសាស ស.រ.អា. មានផ្ទះរបស់មនុស្សជាច្រើនត្រូវបានជន់លិចលង់ ឬត្រូវបានបំផ្លាញ ។ ប្រធាន អិម រ័សុល បាឡឹដ បានធ្វើដំណើរទៅទីនោះដើម្បីជួយ !



១

មិនយូរប៉ុន្មានបន្ទាប់ពីយន្តហោះរបស់លោកបានចុះចត លោកបានទៅមជ្ឈមណ្ឌលមេបញ្ជាការភ្លាម ជាកន្លែងដែលសាសនាចក្រប្រមូលគ្រឿងបរិក្ខារនានា ហើយបញ្ជូនឲ្យទៅពួកស្ម័គ្រចិត្តដៃជំនួយមរមន ។



២

បន្ទាប់មក លោកបានទៅសួរសុខទុក្ខប្រជាជនដែលមានផ្ទះជាច្រើនត្រូវជន់លិចលង់ ។ មានផ្លូវមួយចំនួនត្រូវបានកកស្ទះ ដូច្នេះលោកបានដើរពីផ្ទះមួយទៅផ្ទះមួយទៀត ។ លោកបានស្ដាប់មនុស្សទាំងនោះ ហើយចែកចាយសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ជាមួយពួកគេ ។



៣

លោកបានជួបពួកអ្នកផ្សព្វផ្សាយសាសនា និងសមាជិកដទៃទៀតនៃសាសនាចក្រដែលកំពុងជួយ ។



រូបថតមកពី CHURCH NEWS





៤ លោកបានថ្លែងនៅក្នុងការប្រជុំធម្មនិដ្ឋានមួយ និងការប្រជុំសាក្រាម៉ង់ចំនួនបី ដូច្នេះលោកអាចចែកចាយសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ជាមួយមនុស្សជាច្រើន !

៥ ពេលលោកបានជួបបុរសចំណាស់ម្នាក់ ដែលផ្ទះរបស់គាត់ត្រូវបានបំផ្លិចបំផ្លាញ នោះប្រធានបាឡឺដបានថ្លែងថា ៖




## តើការងារបម្រើមានអត្ថន័យយ៉ាងណា ?

ព្រះយេស៊ូវគ្រីស្ទផ្ដល់ការងារដល់មនុស្សដទៃ ហើយពួកសាវករបស់ទ្រង់ក៏ដូច្នោះដែរ ។ សូមផ្គូផ្គងពាក្យទាំងនេះទៅនឹងរូបភាពដែលបង្ហាញអំពីរបៀបដែលមនុស្សផ្ដល់ការងារបម្រើនៅថ្ងៃនេះ !



ការជួយ



ការស្ដាប់



ការប្រសិទ្ធពរ



ការចែកចាយ



ការមានចិត្តល្អ

តើអ្នកអាចជួយនរណាម្នាក់នៅថ្ងៃនេះយ៉ាងដូចម្ដេច ?

# រតនសម្បត្តិដ៏ល្អឥតខ្ចោះ ដើម្បីចែកចាយ



« ខ្ញុំអាចយកឆ្កែទៅ ! »

ម៉ាក់បាននិយាយថា « ម៉ាក់គិតថា យើងពុំអាចយកឆ្កែទៅសាលាបានទេ ។ ប៉ុន្តែមានរតនសម្បត្តិពិសេសជាច្រើនផ្សេងទៀតដែលកូនអាចចែកចាយបាន » ។

មិនយូរប៉ុន្មានក្រោយមក ការតាមរករតនសម្បត្តិរបស់ឱអេហ្គោបានចាប់ផ្ដើម ! គាត់បានរកឃើញតុក្កតាស្វាមួយ ។ តើគាត់គួរតែយកវាទៅទេ ? ប៉ុន្តែឱអេហ្គោបានបន្តស្វែងរកមើលទៀត ។

**ដោយ អ៊ីរិក ប៊ី ម៉ដុក**

ផ្អែកទៅលើដំណើររឿងពិត

គ្រូបង្រៀនរបស់ឱអេហ្គោបាននិយាយថា « ថ្ងៃស្អែកគឺជាថ្ងៃពិសេសណាស់ ។ យើងនឹងមានកម្មវិធីការបង្ហាញនិងការប្រាប់ ! »

ឱអេហ្គោបានញញឹម ។ គាត់ចូលចិត្តកម្មវិធីការបង្ហាញនិងការប្រាប់ ! គាត់ទន្ទឹងរង់ចាំបង្ហាញអ្វីមួយពិសេសដល់មិត្តភក្តិរបស់គាត់ ។

បន្ទាប់ពីចេញពីរៀន ឱអេហ្គោបានប្រាប់ម៉ាក់អំពីដំណឹងដ៏អស្ចារ្យនេះ ។

គាត់បានសួរថា « តើកូនគួរតែយកអ្វីទៅបង្ហាញ ? »

ម៉ាក់គាត់បាននិយាយថា « អ្វីមួយដែលពិសេសចំពោះកូន » ។



រចនារូបភាពដោយ ស្វែហ្វា ឆាបភ៊ីប



ម៉ាក់បាននិយាយថា « នោះគឺជាវត្ថុមួយដ៏ពិសេសសម្រាប់កម្មវិធីការបង្ហាញ និងការប្រាប់ ។ តើកូននឹងប្រាប់ដល់សិស្សនៅថ្នាក់កូនអ្វីខ្លះអំពីព្រះយេស៊ូវ ? »

គាត់បាននិយាយថា « ដើម្បីឲ្យមនុស្សគ្រប់រូបអាចរីករាយបាន ។ ដោយសារព្រះយេស៊ូវស្រឡាញ់មនុស្សគ្រប់រូប ! » ●



គាត់បានរកមើលនៅខាងក្រោយកៅអីនៅផ្ទះបាយ ។ គាត់បានមើលលើធ្នើរដាក់សៀវភៅ ។ គាត់ពុំបានឈប់ឡើយ រហូតដល់គាត់រកឃើញអ្វីមួយដែលត្រឹមត្រូវ ។

បន្ទាប់មកគាត់បានរកមើលនៅក្បែរគ្រែរបស់គាត់ ។ គាត់បានរកឃើញអ្វីមួយដ៏ល្អឥតខ្ចោះ !

ឌីអេហ្គោបានរត់ទៅបង្ហាញម៉ាក់ ។ គាត់បានឱបរតនសម្បត្តិរបស់គាត់យ៉ាងណែន ។

គាត់បាននិយាយថា « ម៉ាក់ ! មើលនែ៎ ! កូនបានរកឃើញវត្ថុមួយដ៏ល្អបំផុត » ។

គាត់បានលើករូបភាពតូចមួយឲ្យម៉ាក់មើល ។ វាជារូបភាពរបស់ព្រះយេស៊ូវកាលទ្រង់នៅតូច ។ ឌីអេហ្គោមានអារម្មណ៍ល្អ នៅពេលគាត់បានមើលទៅរូបភាពនោះ ។ គាត់ចង់ឲ្យមិត្តរបស់គាត់នៅសាលារៀនមានអារម្មណ៍ល្អដែរ ។

# ព្រះយេស៊ូវបានរៀន ហើយចម្រើនវ័យធំឡើង

ដោយ ម៉ារីស្សា វីដឌីសុន
ទស្សនាវដ្ដីសាសនាចក្រ



ព្រះយេស៊ូវបានប្រសូតមកជា
ព្រះឱរសតូចមួយ ។ ខ្ញុំក៏ធ្លាប់
ជាទារកម្នាក់ផងដែរ !



ម៉ារា និងយ៉ូសែបបានជួយមើលថែ
ព្រះយេស៊ូវ ។ តើនរណាជួយខ្ញុំ ?



ព្រះយេស៊ូវបានចម្រើនវ័យធំឡើងតាម
របៀបដែលខ្ញុំធំឡើងផងដែរ ។ ទ្រង់បាន
មាន *ប្រាជ្ញាឡើង* ។ នោះមានន័យថា
ទ្រង់បានរៀនអ្វីថ្មីៗ ។

រចនារូបភាពដោយ អាបរីល ស្តុត



ទ្រង់បានមាន *ព្រះកាយធំឡើង* ។ នោះមានន័យថា រូបរាងរបស់ទ្រង់បានធំឡើង ។

ទ្រង់កើននូវទីគាប់ព្រះហឫទ័យ *ដល់ព្រះ* ។ នោះមានន័យថា ទ្រង់បានរៀនអំពីព្រះវរបិតាសួគ៌ ។ ទ្រង់បានរៀនអធិស្ឋាន ។ ទ្រង់បានអានព្រះគម្ពីរ ។





ទ្រង់កើននូវទីគាប់ចិត្ត *ដល់មនុស្ស* ។ នោះមានន័យថា ទ្រង់បានរាប់អានមិត្តភក្តិថ្មីៗ ។ ទ្រង់មានព្រះហឫទ័យល្អចំពោះមនុស្សដទៃ ។ ទ្រង់បានជួយគ្រួសាររបស់ព្រះអង្គ ។



ខ្ញុំអាចជួយឲ្យគំនិត និងរូបកាយខ្ញុំលូតលាស់បាន ។ ខ្ញុំអាចរៀនធ្វើតាមព្រះ ។ ខ្ញុំអាចក្លាយជាកល្យាណមិត្ត ល្អម្នាក់ ។ ខ្ញុំអាចរីកចម្រើនតាមរបៀបល្អៗ ដូចព្រះយេស៊ូវបានធ្វើដែរ ! ●

*សូមអានអំពីព្រះយេស៊ូវកាលនៅតូចនៅក្នុង លូកា ២:៤០–៥២ ។*

# ខ្ញុំធំពេញវ័យ




រចនារូបភាពដោយ អាបរីល ស្តុត

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះឪពុកម្ដាយ

យើងរីករាយដើម្បីណែនាំទស្សនាវដ្ដី *ប្រិយមិត្ត* ថ្មី ! ទស្សនាវដ្ដីនេះនឹងមានមកជាមួយ *លីអាហូណា* របស់អ្នក ។ ប្រសិនបើអ្នកពុំមានកូននៅផ្ទះទេនោះ យើងសង្ឃឹមថា អ្នកនឹងចែកចាយវាជាមួយចៅ អ្នកជិតខាង ឬកុមារនៅថ្នាក់អង្គការបឋមសិក្សា ។

នេះគឺជាអ្វីដែលអ្នកនឹងឃើញមាននៅក្នុងទស្សនាវដ្ដី *ប្រិយមិត្ត* ថ្មី ៖

- មានរឿង ចម្រៀង និងសកម្មភាពច្រើនជាង ២០ ទំព័រ
- ក្រដាសថ្មីដែលងាយស្រួលផាត់ពណ៌ គូររូប និងកាត់រូប
- សារលិខិតគណៈប្រធានទីមួយ
- រឿងនានាអំពីការងារបម្រើទូទាំងសាកលលោកមកពីកូរ៉ុមនៃពួកសាវកដប់ពីរនាក់
- រឿងនានាមកពីកុមារនៅជុំវិញពិភពលោក ។
- ធនធាននានាសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ និងការសិក្សាព្រះគម្ពីរជាគ្រួសារ ។

យើងចង់បានយោបល់របស់អ្នកស្ដីពី ៖

- បទពិសោធន៍របស់គ្រួសារអ្នកក្នុងការប្រើទស្សនាវដ្ដី *ប្រិយមិត្ត* ថ្មី ។
- បទពិសោធន៍របស់អ្នកចែកចាយជាមួយមនុស្សដទៃ ។
- យោបល់កែលម្អនានា ។

**New *Friend***
**50 E. North Temple Street, Room 2393**
**Salt Lake City, UT 84105 USA**
**liahona@ldschurch.org**

ដោយក្ដីស្រឡាញ់

ទស្សនាវដ្ដី *ប្រិយមិត្ត*



**សូមស្វែងរករូបលីអាហូណាដែលលាក់នៅខាងក្នុង !**

## មាតិកា


ខ២ សារលិខិតគណៈប្រធានទីមួយ: រៀនអំពីព្រះយេស៊ូវ
ខ៤ ដំណាំនៃទីបន្ទាល់
ខ៦ សកម្មភាព: គ្រាប់ពូជនៃសេចក្ដីជំនឿ
ខ៧ តន្ត្រី: ជំនឿ
ខ៨ សួស្ដីមកពីប្រទេសហ្វីលីពីន !
ខ១០ មូលនិធិបេសកកម្មការ៉េមទឹកកក
ខ១២ តារាងអំណានព្រះគម្ពីរសញ្ញាថ្មី
ខ១៥ ប័ណ្ណប្រកាសគំនិតឈ្នាសវៃការអធិស្ឋាន
ខ១៦ ពួកសាវកនៅជុំវិញពិភពលោក: ប្រធានបាឡឺដទស្សនកិច្ចនៅរដ្ឋតិចសាស ស.រ.អា
ខ១៨ រតនសម្បត្តិដ៏ល្អឥតខ្ចោះដើម្បីចែកចាយ
ខ២០ ការធ្វើតាមព្រះយេស៊ូវ: ព្រះយេស៊ូវបានរៀន ហើយចម្រើនវ័យធំឡើង
ខ២៣ ទំព័រផាត់ពណ៌: ខ្ញុំធំ ពេញវ័យ


នៅលើក្របទស្សនាវដ្ដី *ប្រិយមិត្ត*
រចនារូបភាពដោយ មេលីសា មែនវីល ។

© ២០១៩ BY INTELLECTUAL RESERVE, INC. ALL RIGHTS RESERVED.

CAMBODIAN
4 02186 01258 5